បច្ចេកទេសក្នុងការជីកយករ៉ែ ត្រូវធ្វើឡើងតាមអណ្តូងរ៉ែបើក ក្នុងជម្រៅរាក់ៗ។ វិធីសាស្រ្តនៃការជីករ៉ែ ធ្វើឡើងដោយគួបផ្សំនូវការជីកដោយម៉ាស៊ីន ការលើកដាក់ឡាន នឹងការដឹកជញ្ជូនតាមឡាន។ ស្រទាប់ថ្ម នឹងស្រទាប់រ៉ែដែលទន់ជ្រាយ ត្រូវបានជីកដោយម៉ាស៊ីនជីក រួចដឹកទៅកាន់ទីលានកាកសំណល់ថ្ម និង រោងចក្រជ្រើសរើសរ៉ែ។ ចំណែកឯស្រទាប់ថ្ម និងស្រទាប់រ៉ែរឹង ធ្វើឡើងតាមការបំផ្ទុះ រួចលើកដាក់ឡានដើម្បីដឹកជញ្ជូន។ នៅបាតរណ្តៅរ៉ែបំពាក់នៅប្រព័ន្ធបូមទឹកធុនធំ ក្នុងន័យធានានូវភាពប្រក្រតីនៃផលិតកម្ម។ យោងលើលក្ខណៈពិសេសនៃរដូវវស្សា នឹងរដូវប្រាំងក្នុងតំបន់រ៉ែ ការបំបែកកាកសំណល់ថ្មសំខាន់ៗធ្វើឡើងនៅរដូវវស្សាឯការជីកយករ៉ែធ្វើឡើងនៅរដូវប្រាំង។

#### ៤.៦.៣ បរិមាណថ្មដែលជីកបាន

ចុងឆ្នាំ២០១៤ ក្រុមហ៊ុនយើងខ្ញុំ បានជីកយករ៉ែថ្ម ប្រមាណជា ៨០០០តោន។ ក្នុងថ្មរ៉ែគេសង្កេតឃើញថាមានសមាសធាតុទង់ដែង ខណៈដែលសមាសធាតុលោហៈដទៃទៀតមានតិចតួច។



Draft

### ៤.៦.៤ គ្រឿងចក្រ គ្រឿងម៉ាស៊ីន និងបរិក្ខារសម្រាប់សកម្មភាពជីកយករ៉ែ

ក្រុមហ៊ុនបានប្រើប្រាស់ គ្រឿងចក្រ គ្រឿងម៉ាស៊ីន និងបរិក្ខារគ្រប់ប្រភេទ ដើម្បីបំពេញតម្រូវការ ក្នុងដំណើរការជីកយករ៉ែ។ សម្ភារបរិក្ខាទាំងនោះមានដូចជាម៉ាស៊ីនជីក ម៉ាស៊ីនជីក ម៉ាស៊ីនខួង ម៉ាស៊ីនលើកដាក់ឥវ៉ាន់ ឡានដឹកដី ម៉ាស៊ីនបូមទឹក។ សរុបប្រហែល ៦៤គ្រឿង។

### ៤.៦.៥ មធ្យោបាយដឹកជញ្ជូន

ការរៀបចំមធ្យោបាយដឹកជញ្ជូននៅក្នុង និងខាងក្រៅការដ្ឋានរ៉ែដោយ រថយន្តបែន ឡានដឹក (Dump truck) ចំណុះ ២០តោន។ មធ្យោបាយចម្បងនៃការដឹកជញ្ជូនតាមផ្លូវជម្រាលគឺ ប្រើប្រាស់រថយន្តបែន ជាប្រភេទរថយន្តសម្រាប់ដឹករ៉ែចំណុះ ២០តោន សមត្ថភាពដឹកគឺ ៦៦ម៉ឺនតោនក្នុងមួយឆ្នាំ និងតម្រូវការរថយន្តចំនួន ២០គ្រឿង ទើបអាចបំពេញតម្រូវការដឹកជញ្ជូន។

### ៤.៦.៦ ការគ្រប់គ្រងសំណល់ក្នុងដំណើរការផលិតកម្មរ៉ែ

សំណល់រ៉ែ សំណល់រាវ សំណល់រឹង និងសំណល់ភក់ មានផែនការគ្រប់គ្រងយ៉ាងត្រឹមត្រូវស្របទៅតាមលក្ខណៈបច្ចេកទេស ដោយមានអ្នកជំនាញធ្វើការអង្កេត និងវាយតំលៃ ដើម្បីបញ្ចៀសរាល់ការប៉ះពាល់ទៅលើបរិស្ថាន។

### ៤.៧ អាគារការិយាល័យ

ក្នុងតំបន់គម្រោងមានអគារការិយាល័យ ០១កន្លែង ដែលមានទីឆ្ងាយពីទីតាំងជីករ៉ែ និងតំបន់ម៉ាស៊ីនចម្រាញ់រ៉ែ។ ការគ្រប់គ្រងការដ្ឋានសាងសង់ទាំងអស់ចាំបាច់ណាស់ត្រូវមានអគារការិយាល័យ សម្រាប់សម្រួលដល់ការងារក្នុងការដ្ឋាន។

### ៤.៨ ផ្ទះបុគ្គលិក និងកម្មករ

សម្រាប់កម្មករក្នុងតំបន់គម្រោងនេះ មានពីរប្រភេទគឺកម្មករដែលមកពីតំបន់ឆ្ងាយៗ និងកម្មករដែលរស់នៅភូមិក្បែរតំបន់គម្រោង។ ចំពោះកម្មករដែលនៅក្បែរតំបន់គម្រោងមិនស្នាក់នៅក្នុងទីតាំងគម្រោងទេគឺគាត់ត្រលប់ទៅស្នាក់នៅផ្ទះវិញនៅពេលបញ្ចប់ការងារ។

### ៤.៩ ឃ្លាំង និងរោងជាងគ្រឿងចក្រ

ឃ្លាំង និងរោងជាងគ្រឿងចក្រដែលមានទីតាំងស្ថិតនៅក្បែររោងម៉ាស៊ីនចម្រាញ់រ៉ែពាក់កណ្ដាលសម្រេច។ ឃ្លាំងត្រូវបានរៀបចំឡើងដើម្បីទុកដាក់សម្ភារៈ និងឧបករណ៍ ដើម្បីបំពេញ

តម្រូវការក្នុងដំណើរការផលិតកម្មនេះ។ ចំណែករោងជាងក៏ត្រូវបានរៀបចំឡើងក្នុងការដ្ឋាននេះផងដែរ ដើម្បីជួសជុលគ្រឿងចក្រ ម៉ាស៊ីន និងឧបករណ៍ផ្សេងៗ ដោយខ្លួនឯងនៅពេលគ្រឿងចក្រ និងម៉ាស៊ីនខូច។

### ៤.១០ ចំណតរថយន្ត និងគ្រឿងចក្រ

ចំណតរថយន្ត និងគ្រឿងចក្រត្រូវបានរៀបចំឡើងលើផ្ទៃដីប្រហែល ១ហិកតាដែលជាទំហំធំទូលាយអាចចតរថយន្ត និងគ្រឿងចក្របានគ្រប់គ្រាន់។

### ៤.១១ តម្រូវការកំលាំងពលកម្ម

ដំណាក់កាលសាងសង់ត្រូវការ បុគ្គលិក និងកម្មករចំនួន ៥០នាក់ (ជនជាតិចិន ១៥នាក់ និងជនជាតិខ្មែរ ៣៥នាក់)។ ដំណាក់កាលប្រតិបត្តិគម្រោងត្រូវការបុគ្គលិក និងកម្មករសរុប ២៦០នាក់។

## ៥. ការពិពណ៌នាធីធនធានបរិស្ថានដែលមានស្រាប់

### ៥.១ ធនធានរូបសាស្ត្រ

ការសិក្សាពីគុណភាពខ្យល់ត្រូវបានធ្វើឡើងលើទីតាំងចំនួន ០២ ដែលទីតាំងទី ០១ត្រូវបានធ្វើឡើងនៅក្នុងការដ្ឋានសាងសង់ (X: 440611, Y: 1489000) និងទី ០២នៅក្នុងការដ្ឋានជីកយកថ្មរ៉ែ (X: 442150, Y: 1487093)។ ប៉ារ៉ាម៉ែត្រសំខាន់ចំនួន ០៤ត្រូវបានយកមកធ្វើការវិភាគរួមមាន កាបូនម៉ូណូអុកស៊ីត (CO) នីត្រូសែនឌីអុកស៊ីន ($NO_2$) ស៊ុលផួឌីអុកស៊ីត ($SO_2$) និងភាគល្អិតអណ្តែតសរុប (TPS)។ តាមលទ្ធផលនៃការសិក្សាលើទីតាំងទាំង ០២ខាងលើបានបង្ហាញថាសកម្មភាពអាជីវកម្ម និងរុករករ៉ែទង់ដែង ពុំបានបង្កអោយមានផលប៉ះពាល់ដល់គុណភាពខ្យល់នៅក្នុងទីតាំងគម្រោង និងក្បែរគម្រោងអាជីវកម្ម។ ផ្អែកលើលទ្ធផលពិសោធន៍ប៉ារ៉ាម៉ែត្រសំខាន់ទាំង ០៤ បានឲ្យដឹងថា កំហាប់ដែលអាចនាំឲ្យប៉ះពាល់ដល់គុណភាពខ្យល់ស្ថិតនៅក្រោមស្តង់ដារគុណភាពខ្យល់ ដែលកំណត់ដោយក្រសួងបរិស្ថាន។

ការសិក្សាពីកម្រិតសំលេង ត្រូវបានធ្វើឡើងលើទីតាំងដូចគ្នានឹងការសិក្សាគុណភាពខ្យល់ដែរ។ ទិន្នន័យនៃការកត់ត្រាសំលេងរយៈពេល ២៤ម៉ោង បានឱ្យដឹងថាកម្រិតសំឡេងជាមធ្យមទាំងពីរកន្លែង ដែលត្រូវបានវាយនៅចន្លោះពីម៉ោង៦ព្រឹក ដល់ម៉ោង ២៣ ស្មើនឹង៧0dB នៅពេលថ្ងៃ និង៦៥dB នៅពេលល្ងាច ដែលស្ថិតនៅក្រោមស្តង់ដារនៃកម្រិតសំឡេងដែលកំណត់ដោយក្រសួងបរិស្ថាន។ ចំពោះកម្រិតសំឡេងនៅពេលទាបក្លី មានកម្រិតប្រហាក់

ប្រហែលនឹងស្តង់ដារថ្នាក់ជាតិនៅវេលាម៉ោង ៥:០០ ដល់ ម៉ោង៦:០០ទាបភ្លឺ។ តាមទិន្នន័យបាន បង្ហាញថា កម្រិតបទដ្ឋានដែលអនុញ្ញាតគឺ ៥០dB តែការបញ្ចេញសំឡេងមានកម្រិត ៥១,៦dB និង៥១.៥dB។

ប្រព័ន្ធជលសាស្ត្រនៅក្នុងតំបន់គម្រោងរួមមាន អូរខ្វារ បឹងឈ្នួន/ត្រពាំងឈ្នួន អូរបើក អូរស្រែដម អូរបាក់នោស់ និងស្ទឹងជីក្រែង។

សំណាកទឹកទឹកចំនួន ១១កន្លែង (ទឹកលើដី ០៩ទីតាំង និងទឹកក្រោមដី ០២ទីតាំង) ត្រូវបានជ្រើសរើសសម្រាប់វិភាគលើគុណភាពទឹកក្នុងតំបន់គម្រោង។ ប៉ារ៉ាម៉ែត្រគុណភាពទឹក សំខាន់ចំនួន ២២ត្រូវបានជ្រើសរើសមកវិភាគ ដើម្បីកំណត់នូវហេតុប៉ះពាល់លើគុណភាពទឹក ពីសកម្មភាពគម្រោង។ តាមលទ្ធផលនៃការវិភាគពីក្រសួងបរិស្ថាន បានបង្ហាញថាប៉ារ៉ាម៉ែត្រ ដែលបានជ្រើសរើសសម្រាប់ការវិភាគ ស្ទើរតែទាំងអស់ស្ថិតក្រោមស្តង់ដារគុណភាពទឹករបស់ ក្រសួងបរិស្ថាន។ ក្នុងនោះ ប៉ារ៉ាម៉ែត្រមួយចំនួនដូចជា pH, Total Phosphorus, Total Nitrogen, Lead, Mercury, Total Coliform និង Iron មានកំហាប់លើសតិចតួចពីស្តង់ដារគុណភាពទឹក របស់ក្រសួងបរិស្ថាន។

តាមរយៈការសិក្សាអំពីសីតុណ្ហភាព នៅស្ថានីយ៍ខេត្តសៀមរាបឆ្នាំ ២០០៩-២០១៣ បាន ឲ្យដឹងថា សីតុណ្ហភាពអតិបរមាគិតជាមធ្យមប្រចាំខែ ក្នុងរយៈពេល៥ឆ្នាំគឺ ៣២.៨-៣៨.៨ អង្សា សេ។ ចំពោះខែ ដែលមានសីតុណ្ហភាពក្តៅជាងគេគឺ ខែមីនា មេសា និងឧសភា ដែលមាន សីតុណ្ហភាពជាមធ្យម ៣៧.៤២-៣៧.៨អង្សាសេ។ ចំនែក ខែដែលមានសីតុណ្ហភាពត្រជាក់ជាង គេគឺខែ វិច្ឆិកា ធ្នូ និងមករា ដែលមានសីតុណ្ហភាពមធ្យមជាអប្បរមា ១៨.២ អង្សាសេ។ យោងតាមទិន្នន័យនៃការវាស់កម្រិតទឹកភ្លៀងនៅខេត្តសៀមរាបបានឱ្យដឹងថា កម្រិតកម្ពស់ទឹក ភ្លៀងជាមធ្យមប្រចាំឆ្នាំ ក្នុងរយៈពេល ៥ឆ្នាំពី ២០០៩-២០១៣គឺ ១៧០៣,៦២៤mm ហើយ កម្រិតទឹកភ្លៀងអតិបរមា ១៨៦០,៧mm គឺនៅឆ្នាំ២០១៣ និងកម្រិតទឹកភ្លៀងអប្បរមាគឺ ១១៥៥៩,៥mm គឺនៅឆ្នាំ២០១០។ ខែដែលមានកម្ពស់ទឹកភ្លៀងច្រើនជាងគេគឺនៅចន្លោះខែកញ្ញា មានកម្ពស់ ៣១៨,៨៦៤mm និងខែតុលា មានកម្ពស់ទឹកភ្លៀង៣៥៧,៩mm ។ ចំពោះខែ ដែល មានកម្ពស់ទឹកភ្លៀងតិចជាងគេ គឺខែមករាមានកម្ពស់មធ្យមត្រឹមតែ ៥,០៨mm និងខែកុម្ភៈមាន កម្ពស់មធ្យមត្រឹមតែ ៦,១២mm។ យោងតាមទិន្នន័យនៃការវាស់កម្រិតសំណើម ក្នុងកំឡុងពេល ៨ឆ្នាំ (២០០៥-២០១២) បានឱ្យដឹងថា នៅខេត្តសៀមរាប មានកម្រិតសំណើមជាមធ្យមប្រចាំឆ្នាំ ៧៥,៥%។ ខែតុលាមានកម្រិតសំណើមអតិប្បរមាខ្ពស់ជាងគេគឺ៩៦%។ យោងតាមទិន្នន័យ នេះដដែល បញ្ជាក់ឱ្យដឹងថាកម្រិតសំណើមភាគច្រើនកើនឡើងខ្ពស់ស្របពេលនៅរដូវភ្លៀងធ្លាក់។

## ៤.២ ធនធានជីវសាស្ត្រ

នៅក្នុងតំបន់គម្រោងមានផ្ទៃដីសរុប **៣៦០០ហិកតា** រួមមាន ព្រៃស្រោង **៦៣២ហិកតា** ព្រៃពាក់កណ្តាលស្រោង **៣១ហិកតា** ព្រៃល្បោះ **២២៤៣ហិកតា** និងដីគ្មានគម្របព្រៃ **៦៩៤ហិកតា**។ ឡូត៍ និងអនុ-ឡូត៍ ១៣ (ព្រៃស្រោង ០៦ឡូត៍ និងព្រៃល្បោះ ០៧ឡូត៍) ត្រូវបានជ្រើសរើសសម្រាប់ការសិក្សាពីសារព័ន្ធរុក្ខជាតិ។ តាមរយៈការសិក្សា បានបង្ហាញថាតំបន់នេះមានវត្តមានសារព័ន្ធរុក្ខជាតិប្រមាណជា **១២៤ប្រភេទ** ដែល **១០២ប្រភេទ** ជារុក្ខជាតិឈើ និង **២២ប្រភេទ** ជារុក្ខជាតិគ្មានជាតិឈើ។ រុក្ខជាតិគ្មានជាតិឈើរួមមានពពួកមើមមានចំនួន **០៥ប្រភេទ** ពពួកវល្លិមានចំនួន **១២ប្រភេទ** ស្មៅ និង ព្រិចមានចំនួន **៥ប្រភេទ**។ ដោយឡែកប្រភេទឈើចំនួន **១០២ប្រភេទ**នេះ មាន**៧៥ប្រភេទ** មានវត្តមានក្នុងព្រៃស្រោង ចំនួន **៣៣ប្រភេទ** មានវត្តមានក្នុងព្រៃពាក់កណ្តាលស្រោង និងចំនួន **៤០ប្រភេទ** មានវត្តមានក្នុងព្រៃល្បោះ។ ប្រភេទឈើ **៣៤ប្រភេទ** ក្នុងចំណោម **១០២ប្រភេទ** ត្រូវបានការពារដោយ ប្រកាសលេខ ០៨៩ប្រ.ក/ក.ស.ក ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពី"ផលអនុផលព្រៃឈើដែលត្រូវហាមឃាត់ ប្រមូលផល" នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងចាត់ទុកថាជាប្រភេទឈើមានគុណភាពរឹងមាំរួមមាន៖ ឈើប្រណិតចំនួន **៦ប្រភេទ** ឈើលេខ១ ចំនួន **១០ប្រភេទ** ឈើលេខ២ ចំនួន **៩ប្រភេទ** និង ឈើលេខ៣ ចំនួន **៩ប្រភេទ**។

ការសិក្សាពីវត្តមានសត្វព្រៃ ផ្អែកលើការសម្ភាសន៍ និងការដាក់គន្លងឆ្លងកាត់។ ការសម្ភាសន៍ធ្វើឡើងតាមរយៈការសាកសួរប្រជាជនមូលដ្ឋាន អ្នកបរបាញ់សត្វ និងអ្នកដាក់អន្ទាក់។ គន្លងឆ្លងកាត់ចំនួន ០៥ត្រូវបានធ្វើឡើង សរុបប្រវែង **១៣គីឡូម៉ែត្រ**។ លទ្ធផលពីការកត់ត្រាទិន្នន័យនៅទីវាលបានបង្ហាញថា ប្រភេទថនិកសត្វមានចំនួន **៦ប្រភេទ** ស្មើនឹងរបាយសត្វសរុបចំនួន **៨ក្បាល** ប្រភេទសត្វល្មូន មានចំនួន **២ប្រភេទ** ស្មើនឹងរបាយសត្វសរុបចំនួន **៣ក្បាល** និងប្រភេទ បក្សីមានចំនួន **២៤ប្រភេទ** ស្មើនឹងរបាយ សត្វសរុបចំនួន **៧៤ក្បាល**។

## ៤.៣ ធនធានសង្គម-សេដ្ឋកិច្ច

ការសិក្សាពីសង្គម-សេដ្ឋកិច្ច ត្រូវបានធ្វើការសិក្សាលើភូមិចំនួន ០៣ (ភូមិខ្វាវ ភូមិចុងស្ពាន និងភូមិរវៀង)។ ក្នុងនោះប្រជាជនចំនួន ៩២គ្រួសារ ត្រូវបានសម្ភាសន៍។ ក្នុងចំណោម អ្នកឆ្លើយចំនួន ៩២នាក់ មានបុរស ២៤នាក់ និងស្ត្រី ៦៨នាក់។ សមាជិកសរុបក្នុងគ្រួសារ ជាមធ្យមស្មើនឹង ៥នាក់។ ប្រភេទលំនៅដ្ឋានដែលសាងសង់នៅក្នុងឃុំខ្វាវ ភាគច្រើនជា ផ្ទះប្រក់ស័ង្កសី និងប្រក់ក្បឿង។ ដីត្រូវបានប្រើប្រាស់សម្រាប់ សាងសង់លំនៅដ្ឋាន ធ្វើស្រែ និងចំការ។ កម្រិតនៃការអប់រំនៅមិនទាន់មានលក្ខណៈប្រសើរឡើយ។ ផ្អែកលើការសិក្សា បានបង្ហាញថាអ្នកដែលមិនចេះអក្សរមានចំនួនច្រើន បើប្រៀបធៀបទៅនឹងអ្នកដែលទទួលបានការអប់រំកម្រិតវិទ្យា

ល័យ។ មុខរបរចម្បង គឺការធ្វើកសិកម្ម ឯមុខរបរបន្ទាប់បន្សំ រួមមាន អាជីវករ កម្មករ សិប្បករ ជាដើម។ ប្រាក់ចំណូលគឺខុសគ្នាទៅតាមប្រភេទមុខរបរ និងចំនួនអ្នករកប្រាក់ចំណូលតាមគ្រួសារនីមួយៗ។ ការសិក្សាបានបង្ហាញថា ប្រាក់ចំណូលទាបបំផុតតិចជាង ២៥ម៉ឺន មធ្យម ២៥-៨០ម៉ឺន និងខ្ពស់បំផុត ៨០ម៉ឺន-២លានរៀល។ ការចំណាយផ្អែកលើចំនួនសមាជិកក្នុងគ្រួសារ និងទំហំការងាររបស់គ្រួសារនីមួយ។ ការសិក្សាបានបង្ហាញថា ក្នុងមួយខែការចំណាយអាចមានរហូតដល់ ៥០-៨០ម៉ឺនរៀល។ នៅក្នុងឃុំមានអគ្គីសនីប្រើប្រាស់ ដែលគ្រប់គ្រងដោយឯកជន។ ទោះបីជាមានអគ្គីសនីប្រើប្រាស់ ក៏ប្រជាជនមួយចំនួននៅតែប្រើប្រាស់ប្រភពបំភ្លឺផ្សេងៗ ដូចជា ចង្កៀងប្រេងការ ទៀន អាគុយ និងម៉ាស៊ីនភ្លើង ដោយសារតំលៃប្រើប្រាស់ថាមពលអគ្គីសនីខ្ពស់ពេក។ អុស និងធ្យូង ជាប្រភពថាមពលសំខាន់សម្រាប់ការចំអិនអាហារ។

ការសិក្សាបានបង្ហាញថា នៅរដូវប្រាំងប្រជាជនប្រើប្រាស់ទឹកទុយយោ (បណ្តាញទឹកស្អាត) និងប្រភពទឹកក្រោមដីដូចជា៖ ទឹកអណ្តូងស្នប់ ទឹកអណ្តូងលូ និងទឹកអណ្តូងជីកដោយដៃ ចំណែកឯនៅរដូវវស្សា ប្រជាជននិយមប្រើប្រាស់ប្រភពទឹកលើដីដូចជា៖ ទឹកភ្លៀង ទឹកបឹង/ស្រះ និងទឹកស្ទឹង/អូរជាដើម។ តាមលទ្ធផលនៃការសិក្សាបានបង្ហាញថា គ្រួសារចំនួន ៧៣,៩% មិនបានធ្វើការសម្អាតទឹកសម្រាប់បរិភោគប្រចាំថ្ងៃនោះទេ នៅខណៈដែលគ្រួសារចំនួន ១៩,៦% ដែលបរិភោគទឹកដាំពុះ និង ៦,៥% ប៉ុណ្ណោះដែលចម្រោះទឹកមុនពេលបរិភោគ។ គ្រួសារដែលមានបង្គន់អនាម័យប្រើប្រាស់ប្រចាំថ្ងៃមានត្រឹមតែ ៥,៤% (ប្រភេទបង្គន់ចាក់ទឹក) ខណៈដែលគ្រួសារដែលគ្មានបង្គន់អនាម័យប្រើប្រាស់មានរហូតដល់ ៩៤,៦% នៃ៩២គ្រួសារដែលបានធ្វើបទសម្ភាសន៍។ ចំពោះគ្រួសារដែលគ្មានបង្គន់អនាម័យប្រើប្រាស់ទាំងអស់ ពួកគាត់ភាគច្រើនទៅបន្ទោរបង់នៅក្នុងព្រៃជិតផ្ទះ (៣៩%) ជីកកប់ (៥៩,៤%) និងប្រើប្រាស់បង្គន់ជាមួយអ្នកជិតខាង (១,៦%)។ ចំពោះការគ្រប់គ្រងសំណល់រឹង-រាវ មិនត្រូវបានបញ្ចេញចោលក្នុងបរិមាណលើសលប់ទេ ដោយសារសំណល់ទាំងនោះគ្រាន់តែជាសំណល់គេហដ្ឋាន។ តាមការសាកសួរបានបង្ហាញថា ប្រជាជនភាគច្រើនមានជម្ងឺផ្តាសាយ (៣០,៥%) ជម្ងឺគ្រុនក្តៅ (២៣,៧%) និងជម្ងឺរាគរូស (១០,៩%) នៃប្រជាជនដែលបានសម្ភាសន៍។ ស្ត្រីបានរួមចំណែកយ៉ាងសំខាន់ក្នុងសកម្មភាពប្រចាំថ្ងៃ។ តាមការសិក្សាបានបង្ហាញថា ស្ត្រីបានចូលរួមចំនួន ៦៨% នៅក្នុងការសិក្សា។

## ៦. ការចូលរួមជាសាធារណៈ

ការពិគ្រោះយោបល់ត្រូវបានធ្វើឡើងចំនួន ០២លើក។ លើកទី ០១ត្រូវបានធ្វើឡើងតាមរយៈការសម្ភាសដាច់ដោយឡែកទៅតាមស្ថាប័នជំនាញ និងពាក់ព័ន្ធរបស់មន្ទីរខេត្ត-ក្រុង រួមមាន សាលាខេត្តសៀមរាប នាយកដ្ឋានភូគព្ភសាស្ត្រ (រាជធានីភ្នំពេញ) មន្ទីររ៉ែ និងថាមពល មន្ទីរបរិស្ថាន មន្ទីរធនធានទឹក និងឧតុនិយម មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់

មន្ទីរទេសចរណ៍ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ នាយខណ្ឌរដ្ឋបាលព្រៃឈើ និងសាលាស្រុកជីក្រែង ។ ជាលទ្ធផលនៃការពិគ្រោះយោបល់លើកទី ០១ បានផ្តល់នូវអនុសាសន៍ សំណូមពរ និងមតិល្អៗដូចជា ក្រុមហ៊ុនត្រូវធ្វើរបាយការណ៍ជាប្រចាំស្តីពីសកម្មភាពអាជីវកម្ម យកចិត្តទុកដាក់កុំមានផលប៉ះពាល់ដល់សេដ្ឋកិច្ច-សង្គមនៅជុំវិញតំបន់គម្រោង ស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត បញ្ចៀសនូវហេតុប៉ះពាល់បរិស្ថានជាអប្បបរមា (ធនធានរូបសាស្ត្រ ជីវសាស្ត្រ និងសង្គម-សេដ្ឋកិច្ច) គោរពនូវច្បាប់ការងារ និងគោលការណ៍អភិវឌ្ឍន៍របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អនុវត្តការងារអាជីវកម្ម និងរុករកទៅតាមស្តង់ដារបច្ចេកទេសត្រឹមត្រូវ មានវិធានការស្តារ និងដាំដើមឈើឡើងវិញបន្ទាប់ពីអាជីវកម្មបានបញ្ចប់ និងត្រូវបង្កើតភ្នាក់ងារសម្រាប់ផ្តល់ព័ត៌មានទៅកាន់ស្ថាប័នពាក់ព័ន្ធ។ ជាផ្លែផ្កាក្នុងការពិភាក្សា និងពិគ្រោះយោបល់លើទី ០១ បានបង្ហាញថា ស្ថាប័នពាក់ព័ន្ធទាំងអស់មានការគាំទ្រចំពោះគម្រោងអាជីវកម្មរ៉ែទង់ដែង ស្របពេលដែលការធ្វើការអាជីវកម្មនោះមិនប៉ះពាល់ដល់ប្រយោជន៍សង្គម និងសេដ្ឋកិច្ចជាតិ ជាពិសេសជួយបង្កើនតំលៃសេដ្ឋកិច្ចក្នុងតំបន់។

ការពិគ្រោះយោបល់ និងពិភាក្សាលើកទី ០២ ត្រូវបានធ្វើឡើងនៅសាលប្រជុំ ខេត្តសៀមរាប ដោយមានការចូលរួមពីស្ថាប័នជំនាញ និងពាក់ព័ន្ធ រួមមាន សាលាខេត្តសៀមរាប ក្រសួងបរិស្ថាន (នាយកដ្ឋានអង្កេត ត្រួតពិនិត្យ និងវាយតំលៃហេតុប៉ះពាល់បរិស្ថាន) មន្ទីររ៉ែ និងថាមពល មន្ទីបរិស្ថាន មន្ទីធនធានទឹក និងឧតុនិយម មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មន្ទីរទេសចរណ៍ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ នាយខណ្ឌរដ្ឋបាលព្រៃឈើ និងសាលាស្រុកជីក្រែង។ លទ្ធផលនៃការធ្វើបទបង្ហាញស្តីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ បានបង្ហាញតាមរយៈការផ្តល់អនុសាសន៍ ចំណាប់អារម្មណ៍ និងមតិយោបល់ រួមមាន៖

- ក្រុមហ៊ុនទីប្រឹក្សាត្រូវបង្ហាញពីទីតាំងមីន ទីតាំងប្រាសាទបុរាណ និងទីតាំងស្ពានបុរាណនៅលើផែនទី។ ប្រសិនបើមានបេតិកភ័ណ្ឌប្រវត្តិសាស្ត្រនៅក្នុងទីតាំងគម្រោង ម្ចាស់គម្រោងត្រូវមានផែនការគ្រប់គ្រងថែរក្សា ដោយធ្វើការកាត់ចេញមិនឲ្យមានការប៉ះពាល់។
- ចំពោះផែនការនៃការគ្រប់គ្រងសំណល់រឹង-រាវ ត្រូវកំណត់ឲ្យបានច្បាស់លាស់ ដើម្បីជៀសវៀងរាល់ការបំពុលនានាទៅលើបរិស្ថាន និងប្រជាពលរដ្ឋដែលនៅក្នុង និងក្បែរតំបន់គម្រោង។

- ការធ្វើអាជីវកម្មរ៉ែដោយប្រើប្រាស់វិធីសាស្ត្របើកចំហរនេះ អាចធ្វើឲ្យមានការប៉ះពាល់ដល់ព្រៃឈើ និងសត្វព្រៃក្នុងតំបន់គម្រោង ហេតុដូចនេះក្រុមហ៊ុនត្រូវសហការណ៍ជាមួយរដ្ឋបាលព្រៃឈើដើម្បីធ្វើសារពើភ័ណ្ឌព្រៃឈើបង់ពន្ធជូនរដ្ឋ។
- នៅក្នុងទីតាំងគម្រោងមិនមានដីប៉ះពាល់ ឬពាក់ព័ន្ធជាមួយប្រជាពលរដ្ឋ តែទោះជាយ៉ាងណាក៏ធ្លាប់មានដីស្រែចំការពនេតចររបស់ប្រជាជនមួយចំនួនខ្លះដែរ ហេតុដូចនេះក្រុមហ៊ុនត្រូវមានវិធានការដោះស្រាយដើម្បីកុំឲ្យមានបញ្ហាទៅថ្ងៃក្រោយ។
- ឃើញថាក្រុមហ៊ុនបានជួយអភិវឌ្ឍន៍ភូមិឃុំបានច្រើនដូចជា សាលារៀន មន្ទីរពេទ្យ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តជាច្រើនទៀត។ គម្រោងនេះក៏បានជួយកាត់បន្ថយរាល់បទល្មើសកាប់បំផ្លាញព្រៃឈើបានមួយចំនួនផងដែរ។
- ចុងក្រោយអាជ្ញាធរខេត្តសៀមរាប សូមធ្វើការគាំទ្រ និងជួយជំរុញការអភិវឌ្ឍន៍លើគម្រោងធ្វើអាជីវកម្មរ៉ែនេះ ឲ្យដំណើរការបានរហ័ស។

## ៧. ហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ

គ្រប់ដំណាក់កាលរបស់គម្រោង (ដំណាក់កាលប្រតិបត្តិ រុករក និងអាជីវកម្ម) តែងតែបង្កឲ្យមានចំណុចអវិជ្ជមានទៅលើធនធានរូបសាស្ត្រ ជីវសាស្ត្រ និងសេដ្ឋកិច្ច-សង្គម ដែលមិនអាចជៀសផុត។ ដើម្បីបញ្ចៀសរាល់ផលប៉ះពាល់បរិស្ថាន និងសង្គមនៅក្នុងតំបន់គម្រោងអាជីវកម្មក្រុមហ៊ុនត្រូវមានវិធានការកាត់បន្ថយដូចខាងក្រោម៖

- ធ្វើការឈូសឆាយ និងជីករណ្ដៅរ៉ែទៅតាមលក្ខណៈបច្ចេកទេស និងពិនិត្យ តាមស្ថានភាពជាក់ស្តែងនៃខ្សែរ៉ែ ទៅតាមស្ថានភាពសណ្ឋានដីក្នុងតំបន់។
- កំណត់ទីតាំងច្បាស់លាស់ សម្រាប់ការស្តុកទុកអាចម៍ដីមុននឹងយកមកចាក់បំពេញក្នុងរណ្តៅដែលបានបញ្ចប់ការជីកកាយយករ៉ែ។ បច្ចេកទេសក្នុងការចាក់បំពេញ គឺការយកអាចម៍ដីចាក់ជាស្រទាប់មុន បន្ទាប់មកយកសំណល់អាចម៍រ៉ែមកចាក់បន្ថែម រួច ចាក់អាចម៍ដីចុងក្រោយ។
- ធ្វើការឈូសឆាយទៅតាមប្លង់មេ ដោយបញ្ចៀសនូវការឈូសឆាយខុសបច្ចេកទេស មិនត្រឹមតែប៉ុណ្ណោះក្រុមហ៊ុននឹងលុបរណ្តៅបន្ទាប់ធ្វើការជីកយករ៉ែរួចរាល់។
- រៀបចំទុកដាក់ថ្មរ៉ែ និងអាចម៍រ៉ែឲ្យបានត្រឹមត្រូវ ដើម្បីការពារការហូរច្រោះចូលទៅក្នុងប្រព័ន្ធផ្លូវទឹក ក៏ដូចជាដីស្រែចំការរបស់ប្រជាពលរដ្ឋរស់នៅក្បែរតំបន់គម្រោង។
- រៀបចំ និងត្រួតពិនិត្យមើលចុងទុយោរបស់ប្រព័ន្ធបង្ហូរភក់ ដើម្បីធានាថាមិនមានគ្មានការលេចធ្លាយ ដែលជាហេតុបង្កឲ្យមានការច្រោះដី។

Draft

- បង្កើតកន្លែងស្តុកសំណល់រឹង ដោយមានការគ្រប់គ្រងយ៉ាងត្រឹមត្រូវ ធ្វើការបែងចែកសំណល់ និងកំណត់ពេលវេលានៃការដឹកជញ្ជូនយ៉ាងច្បាស់លាស់ ព្រមទាំងសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីយកទៅដាក់ក្នុងទីតាំងកំណត់
- ប្រើប្រាស់បច្ចេកទេសគ្រប់គ្រងនៅចុងបំពង់ផ្សែងទំនើប ដើម្បីគ្រប់គ្រងនូវកម្រិតសំណើមនៅគ្រប់បំពង់ផ្សែងទាំងអស់ ក្នុងគោលបំណងកាត់បន្ថយនូវបរិមាណផ្សែងដែលភាយចេញ។
- កំណត់ល្បឿនក្នុងការដឹកជញ្ជូនសំណល់អាចម៍ដី ថ្មរ៉ែ ដើម្បីកាត់បន្ថយការហុយ
- រៀបចំកន្លែងទុកដាក់ម៉ាស៊ីនភ្លើងនៅក្នុងបន្ទប់បិទជិត និងបំពាក់ឧបករណ៍ចម្រោះខ្យល់នៅហ្វឹងម៉ាស៊ីន ឬនៅត្រង់បំពង់ផ្សែងតែម្តង។
- រៀបចំទីតាំងសម្រាប់ស្តុកទុកថ្មរ៉ែមុនចម្រាញ់ឲ្យបានត្រឹមត្រូវ និងស្របតាមបច្ចេកទេសដើម្បីកាត់បន្ថយការបំពុលខ្យល់
- សាងសង់អាងប្រព្រឹត្តកម្មសំណល់រាវ ដើម្បីសំអាតសារធាតុពុល និងកខ្វក់ពីក្នុងទឹកចំរាញ់យករ៉ែទង់ដែង តាមរយៈការធ្វើឲ្យរងកករ ឬអណ្តែត ព្រមទាំងត្រូវដាក់ក្នុងបន្ទប់បិទជិត និងមានការគ្រប់គ្រងត្រឹមត្រូវ ដើម្បីទាញយកមកប្រើប្រាស់ឡើងវិញ។
- ធ្វើការគ្រប់គ្រងព្រៃឈើនៅក្នុងតំបន់គម្រោងឲ្យបានប្រសើរ ដោយមិនឲ្យមានការកាប់ព្រៃឈើខុសច្បាប់ ក្នុងគោលបំណងរក្សាព្រៃឈើដើម្បីបន្សុទ្ធខ្យល់ក្នុងតំបន់គម្រោង។
- ក្រុមហ៊ុននឹងកំណត់ម៉ោងធ្វើការយ៉ាងច្បាស់លាស់ (ម៉ោងចេញ-ម៉ោងចូល)។
- បំពាក់ឧបករណ៍កាត់បន្ថយសម្លេង និងកម្រិតរំញ័រនៅតាមម៉ាស៊ីនចម្រាញ់រ៉ែដើម្បីកម្រិតសម្លេង ដូចមានចែងក្នុងអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុល និងរំខានដោយសំលេង
- ជីកស្រះសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនដើម្បីផ្គត់ផ្គង់សង្វាក់ផលិតកម្ម និងការប្រើប្រាស់ក្នុងតំបន់ធ្វើអាជីវកម្ម។
- មិនប្រើប្រាស់សារធាតុគីមីគ្រោះថ្នាក់ក្នុងដំណើរការចម្រាញ់រ៉ែឡើយ សារធាតុសំខាន់តែពីរប្រភេទគត់ដែលត្រូវបានដាក់ក្នុងពេលចម្រាញ់ គឺកំបោរស និងអំបិល ដោយបរិមាណនៃការដាក់ស្របទៅតាមបច្ចេកទេស។
- ប្រើប្រាស់ទឹកឡើងវិញឲ្យអស់សមត្ថភាព ដោយទាញយកទឹកដែលធ្វើប្រព្រឹត្តិកម្មរួចហើយចូលក្នុងវដ្តនៃដំណើរការចម្រាញ់រ៉ែ។
- សាងសង់ប្រព័ន្ធលូព័ទ្ធជុំវិញទីតាំងធ្វើអាជីវកម្ម ដូចជាទីតាំងផ្ទះបុគ្គលិក កម្មករ ទីតាំងចម្រាញ់រ៉ែ ទីតាំងជីកយករ៉ែ ដើម្បីការពារការហូរច្រោះឆ្ពោះទៅកាន់ប្រព័ន្ធទឹកជុំវិញតំបន់គម្រោងធ្វើអាជីវកម្ម
- សំណល់ភក់ចេញពីអាងប្រព្រឹត្តិកម្មសំណល់រាវ នឹងបញ្ជូនបន្តទៅកាន់អាងប្រព្រឹត្តកម្មហើយស្តុកទុកក្នុងអាងបិទជិត។

- រក្សាទុកព្រៃចម្ងាយ ១០០ម៉ែត្រសងខាងមាត់អូរ បឹង និងធ្វើការជីករ៉ែដោយប្រុងប្រយ័ត្ន បើអាចជៀសវាងការប៉ះពាល់ដល់ព្រៃឈើបាន ក្រុមហ៊ុននឹងបញ្ចៀសរាល់ការប៉ះពាល់
- បន្តអនុញ្ញាតឲ្យប្រជាពលរដ្ឋ ដែលធ្លាប់ទៅស្វែងរកអនុផលព្រៃឈើនៅក្នុងតំបន់គម្រោង ចូលទៅស្វែងរកតាមធម្មតា ដោយមានការអនុញ្ញាតត្រឹមត្រូវពីក្រុមហ៊ុន ពីព្រោះខ្លាចមានមនុស្សខិលខូចមួយចំនួនតូចចូលកាប់ឈើ ឬបរបាញ់សត្វខុសច្បាប់ ឬក៏ទៅលួចយកសារធាតុរ៉ែដែលផលិតបានដោយក្រុមហ៊ុនវិនិយោគ។
- រៀបចំផ្គត់ផ្គង់ទឹកស្អាត (អណ្តូងស្នប់) ដល់កម្មករ និងផ្តល់សេវាសុខភាពដល់កម្មករតាមរយៈពិនិត្យ និងព្យាបាលជំងឺ
- រៀបចំសំអាតបរិស្ថាននៅក្នុងបរិវេណទីស្នាក់ការ និងកន្លែងស្នាក់នៅ ព្រមទាំងសាងសង់បង្គន់អនាម័យ
- ធ្វើការអប់រំណែនាំដល់បុគ្គលិក-កម្មករឲ្យយល់ដឹងពីរបៀបអនុវត្តអនាម័យ និងគោលការណ៍ណែនាំក្នុងការទុកដាក់សំណល់គ្រប់ប្រភេទ ឲ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស
- ផ្គត់ផ្គង់សម្ភារៈ និងឧបករណ៍ការពារសុវត្ថិភាព ដល់កម្មករដែលធ្វើការក្នុងការដ្ឋាន ដោយធ្វើការពន្យល់ណែនាំពីរបៀបប្រើប្រាស់ឧបករណ៍ និងណែនាំពីការការពារសុវត្ថិភាពពេលកំពុងធ្វើការ ដើម្បីជៀសវាងករណីយថាហេតុណាមួយ។
- មានគោលនយោបាយដោះស្រាយណាមួយ ឲ្យបានសមស្របជាមួយម្ចាស់ដីដែលជាមួយជនរងគ្រោះលើដំណាំ និងទិន្នផលដែលពួកគាត់ទទួលបានក្នុងមួយឆ្នាំៗសម្រាប់ស្រែចំការអចិន្ត្រៃយ៍ និងប៉ះប៉ូវជាថវិកាសម្រាប់កម្លាំងពលកម្មដែលបានកាប់ឆ្ការរួចចំពោះស្រែចំការពនេចរ ហើយថវិកានេះនឹងប្រគល់ដល់ប្រជាជនដោយផ្ទាល់ ដោយមានការដឹងលឺពីអាជ្ញាធរដែនដី។
- ចំពោះរណ្តៅដែលលុបដីរួច ក្រុមត្រូវផ្ទេរទៅឲ្យម្ចាស់ដើមវិញ ឬជាសាធារណៈវិញ។
- ចំពោះផលប៉ះពាល់លើដីដែលមានដើមឈើ ឬទីសក្ការៈបូជា (អារក្ស-អ្នកតា) ក្រុមហ៊ុននឹងធ្វើការពិភាក្សាជាមួយអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋមូលដ្ឋាន ដើម្បីសុំយោបល់ និងសម្រេចចិត្តពីសំណាក់រដ្ឋាភិបាល។
- ចូលរួមសាងសង់ និងជួសជុលផ្លូវលំក្នុងសហគមន៍ ដើម្បីសំរួលដល់ការធ្វើចរាចរណ៍នៅក្នុងតំបន់
- ធ្វើអាជីវកម្មរ៉ែដោយប្រុងប្រយ័ត្នអំពីបញ្ហាអគ្គិភ័យ ដែលអាចកើតឡើងជាយថាហេតុ ដោយត្រូវបំពាក់នូវបំពង់ពន្លត់អគ្គិភ័យ និងឧបករណ៍សុវត្ថិភាពផ្សេងៗនៅគ្រប់ទីតាំងធ្វើអាជីវកម្ម និងការដ្ឋាន។
- បំពាក់ឧបករណ៍ ឬតាមដានកម្រិតរញ្ជួយដីនៅតាមរណ្តៅនីមួយៗ ដើម្បីបញ្ចៀសការបាក់ស្រុតដីដោយប្រការចៃដន្យណាមួយ។

• ធ្វើការណែនាំដល់បុគ្គលិក-កម្មករឲ្យយល់ដឹងពីបញ្ហាភ្លើងឆេះព្រៃ និងគ្រោះអាសន្ននានា ព្រមទាំងបង្កើតស្លាកសញ្ញាប្រាប់ដំណឹង និងហាមឃាត់នៅទីតាំងព្រៃសំខាន់ក្នុងតំបន់គម្រោង។

## ៨ ផែនការគ្រប់គ្រងបរិស្ថាន

ផែនការគ្រប់គ្រងបរិស្ថានធ្វើឡើង ដើម្បីធ្វើការតាមដានទៅលើការអនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ដើម្បីឱ្យប្រាកដថារាល់វិធានការទាំងអស់ ដែលបានលើកឡើងត្រូវបានអនុវត្ត ដោយម្ចាស់គម្រោងនៅរាល់ដំណាក់កាល ដែលគេរកឃើញថាមានហេតុប៉ះពាល់។ ផែនការគ្រប់គ្រងបរិស្ថានត្រូវ កំណត់ឱ្យបានច្បាស់លាស់ទៅលើហេតុប៉ះពាល់ទីតាំងដែលត្រូវត្រួតពិនិត្យ តាមដាន និងសមាសភាពអ្នកចូលរួមត្រួតពិនិត្យ។

ក្រុមហ៊ុនត្រៀមថវិកាមួយផ្នែកតូច ដែលបានមកពីប្រាក់ចំណេញសម្រាប់មូលនិធិបរិស្ថាន និងសង្គម ដោយមូលនិធិបរិស្ថានត្រូវចំណាយប្រមាណ **៣០.០០០(បីម៉ឺន)** ដុល្លាសហរដ្ឋអាមេរិក ក្នុងរយៈពេល ១ឆ្នាំ ដើម្បីប្រើប្រាស់សម្រាប់ការស្តារបរិស្ថានឡើងវិញ ដូចជាការដាំដើមឈើ និងការការពារគុណភាពបរិស្ថាន។ ចំណែក មូលនិធិសង្គម ក្រុមហ៊ុនត្រៀមថវិកាចំនួន **៣០.០០០ (បីម៉ឺន)** ដុល្លាសហរដ្ឋអាមេរិក សម្រាប់រយៈពេល ១ឆ្នាំ ដើម្បីប្រើប្រាស់ក្នុងការបណ្តុះបណ្តាលជំនាញផ្សេងៗ ការទ្រទ្រង់សាសនាតាមរយៈវិស័យទេសចរណ៍ និងកសាងហេដ្ឋារចនាសម្ព័ន្ធនៅក្នុង និងក្បែរតំបន់គម្រោង។

## ៩ ការវិភាគសេដ្ឋកិច្ច និងតំលៃបរិស្ថាន

ការវិនិយោគអាជីវកម្មវ៉ែទង់ដែងរបស់ **ក្រុមហ៊ុន ម៉េងស៊ីនហុងហ្វា (ខេមបូឌា) រីសស៌ អ៊ិនវេសមេន** លើផ្ទៃដីទំហំ **៣៦០០ហិកតា** មិនត្រឹមតែផ្តល់ផលចំណេញទាំងផ្នែកសេដ្ឋកិច្ចរបស់ក្រុមហ៊ុនផ្ទាល់ប៉ុណ្ណោះទេ ថែមទាំងចូលរួមផ្តល់ផលចំណេញដល់សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាផងដែរតាមរយៈការយកពន្ធ និងជួលដី។ លើសពីនេះទៀត ការវិនិយោគលើអាជីវកម្មរ៉ែមួយនេះ ក៏បានរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ដែលរស់នៅក្បែរតំបន់គម្រោងតាមរយៈបង្កើតការងារឲ្យប្រជាជនធ្វើ និងបង្កើនកាលានុវត្តន៍ភាពទីផ្សារសេដ្ឋកិច្ចក្នុងតំបន់គម្រោង និងភូមិនៅជុំវិញគម្រោងទៀតផង។ មួយវិញទៀត ក្រុមហ៊ុនអាជីវកម្មរ៉ែមួយនេះ ក៏បានរៀបចំកញ្ចប់ថវិកាបានពីការចំណេញ ដើម្បីជួយទ្រទ្រង់ដល់ការអភិវឌ្ឍន៍សង្គមតាមរយៈការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធនៅក្នុង និងក្បែរតំបន់អភិវឌ្ឍន៍ផងដែរ និងទ្រទ្រង់ដល់ការស្តារធនធានព្រៃឈើឡើងវិញតាមរយៈសកម្មភាពដាំដើមឈើ និងសកម្មភាពអភិរក្សធនធានមានស្រាប់ជាដើម។ យោងតាមការវិភាគប្រសិទ្ធិភាពសេដ្ឋកិច្ចនៃការអភិវឌ្ឍន៍ លើគម្រោងអាជីវកម្មរ៉ែទង់ដែងបានបង្ហាញថាសន្ទស្សន៍នៃផលចំណេញ-ខាត (Cost Benefit Ratio) ក្នុងរយៈពេល១០ឆ្នាំនៃការ វិនិយោគស្មើនឹង១,២៥ ដែលមានតំលៃធំជាង១

នោះបញ្ជាក់អំពីលក្ខណៈល្អប្រសើរ និងចំណេញច្រើនរបស់ក្រុមហ៊ុនវិនិយោគ។ មានន័យថា ក្រុមហ៊ុនវិនិយោគលើអាជីវកម្មរ៉ែអាចមានលទ្ធភាពទទួលបានផលចំណេញ ស្មើតែមួយភាគបួន (១/៤) នៃការចំណាយសរុបរបស់ក្រុមហ៊ុន។ រីឯភាគីរដ្ឋាភិបាលក៏អាចទទួលបានផលចំណេញពីគម្រោងវិនិយោគនេះច្រើនគួរសមដែរ ដែលរដ្ឋាភិបាលអាចទទួលបានចំណូល (Total PV Benefit) ចូលរដ្ឋរហូតដល់ **៨៩,៥៧ លានដុល្លា** ក្នុងរយៈពេល១០ឆ្នាំ ក្នុងនោះរាប់បញ្ចូលទាំងចំណូលពីពន្ធដឹកជញ្ជូនក្នុងការលក់ ពន្ធលើតំលៃបន្ថែម និងពន្ធផ្សេងៗ ពន្ធលើចំណូល និងចំណូលពីការជួលដីទំហំ **៣៦០០ហិកតា** ឲ្យក្រុមហ៊ុន។

## ១០ សន្និដ្ឋាន និងអនុសាសន៍

ស្របតាមវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថានទៅលើហេតុប៉ះពាល់អវិជ្ជមាន ដែលកើតឡើងដោយសារគម្រោងអាជីវកម្ម ការសិក្សាបានបង្ហាញឲ្យឃើញថា ផលប៉ះពាល់ទាំងអស់នេះសុទ្ធតែអាចមានវិធានការគ្រប់គ្រង និងកាត់បន្ថយបានមួយចំនួនធំតាមរយៈការអនុវត្តន៍វិធានការកាត់បន្ថយ និងផែនការគ្រប់គ្រងបរិស្ថានដ៏មានប្រសិទ្ធិភាព និងត្រឹមត្រូវដូចជា៖

→ ការរក្សាទុកតំបន់បៃតងឲ្យបានច្រើននៅក្នុងតំបន់គម្រោងតាមដែលអាចធ្វើទៅបាន ជាក់ស្តែងតំបន់ព្រៃរក្សាទុក ដូចជាព្រៃទ្រនាប់ជងអូរ ជាដើម។

→ កិច្ចសហការជាមួយក្រសួង/ស្ថាប័នជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានឲ្យដល់កំរិតអប្បបរមា

→ រៀបចំផ្នែក ឬក្រុមទទួលខុសត្រូវសម្រាប់អនុវត្តផែនការគ្រប់គ្រងបរិស្ថាន។

→ រៀបចំរបាយការណ៍ដែលជាលទ្ធផលនៃការត្រួតពិនិត្យ តាមដានលើធនធានរូបសាស្ត្រ ជីវសាស្ត្រ និងបរិស្ថានសង្គម។

→ រៀបចំបំពាក់ឧបករណ៍សុវត្ថិភាព និងគ្រឿងស្របចក្រតាមលក្ខណៈបច្ចេកទេសក្នុងការប្រតិបត្តិការងារ។

→ គ្រប់គ្រងសំណល់រាវ និងការបំពុលទឹកនៅតំបន់ជិតខាង ដោយបានបង្កើតបង្គន់អនាម័យ និងអាងប្រព្រឹត្តិកម្មសំណល់រាវចេញពីខ្សែសង្វាក់ផលិតកម្មការងាររបស់ខ្លួន។

→ គ្រប់គ្រងសំណល់រឹង ដែលរៀបចំឲ្យមានការប្រមូលផ្តុំរួមចូលក្នុងធុងសំរាមនៅក្នុងប្រតិបត្តិការអាជីវកម្មទាំងមូល ដើម្បីប្រមូលយកទៅទុកក្នុងទីតាំងស្តុកត្រឹមត្រូវ ដែលត្រូវបានកំណត់ដោយអាជ្ញាធរមូលដ្ឋាន។

→ គ្រប់គ្រងលើសុវត្ថិភាព (គ្រោះថ្នាក់ដែលកើតឡើងជាយថាហេតុ) និងសន្តិសុខដូចជា៖

 – កន្លែងស្តុកប្រេងឥន្ធនៈ៖ ត្រូវដាក់ស្ថិតនៅដាច់ឆ្ងាយពីអ្នកដែលគ្មានសមត្ថកិច្ច ហើយរៀបចំកសាងឲ្យបានរឹងមាំ ដោយមានក្រាលទំរអំពីបេតុងឲ្យបានសមស្របតាម

Draft

លក្ខណៈបច្ចេកទេស និងមានប្រើក្រណាត់ជក់ប្រេង ដើម្បីការពារការកំពប់ធ្លាយប្រេង ដែលធ្វើឲ្យប៉ះពាល់ដល់បរិស្ថានជុំវិញ ហើយត្រូវត្រៀមការពារជានិច្ចនូវអគ្គីភ័យដោយរក្សាទុកជាប្រចាំនូវបំពង់ពន្លត់អគ្គីភ័យនៅក្បែរធុងស្តុកប្រេង។

- ម៉ាស៊ីនភ្លើងត្រូវរៀបចំទុកដាក់ឲ្យបានត្រឹមត្រូវ ហើយថាមពលអគ្គីសនីនឹងត្រូវបានចែកចាយយកទៅប្រើប្រាស់ក្នុងការដ្ឋានទាំងមូល ដោយធ្វើការរៀបចំ និងប្រើខ្សែភ្លើងតាមស្តង់ដារត្រឹមត្រូវ និងមានការត្រួតពិនិត្យជាប្រចាំ។
- រៀបចំឧបករណ៍សុវត្ថិភាពដូចជា៖ ស្បែកជើង.កវែង មួកការពារក្នុងការដ្ឋាន វ៉ែនតាសុវត្ថិភាព ម៉ាស់ការពារមុខ ប្រដាប់ការពារត្រចៀក និងស្រោមដៃជាដើម។
- ក្នុងការដ្ឋានតែងតែមានការយាមកាមតឹងរ៉ឹង ដោយក្រុមសន្តិសុខរបស់ក្រុមហ៊ុន ដើម្បីការពារនូវការបាត់បង់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន និងបុគ្គលិក-កម្មករ ដោយអំពើចោរកម្ម។
- គម្រោងនឹងធ្វើសហប្រតិបត្តិការ ជាមួយស្ថាប័នជំនាញក្នុងការត្រួតពិនិត្យសកម្មភាពគម្រោង និងទទួលយកនូវការកែប្រែបច្ចេកទេសណាមួយដែលជំនាញតម្រូវឲ្យកែ។
- ក្រុមហ៊ុនអាជីវកម្ម នឹងត្រៀមរៀបចំនូវថវិកាបម្រុងទុកសម្រាប់ការប្រតិបត្តិផែនការគ្រប់គ្រងបរិស្ថាន ដោយការចំណាយគិតតាមស្ថានភាពជាក់ស្តែង។

ទន្ទឹមនឹងនេះដែរ ការធ្វើគម្រោងអាជីវកម្មរ៉ែនេះនឹងអាចជួយសម្រួលដល់សេដ្ឋកិច្ចរបស់ប្រជាជននៅក្នុងតំបន់ និងនាំមកនូវផលប្រយោជន៍ជាច្រើនដូចជា៖

១- ជួយកាត់បន្ថយនូវរាល់សកម្មភាពប្រព្រឹត្តបទល្មើសព្រៃឈើ សត្វព្រៃនានា និងការនេសាទខុសច្បាប់នៅក្នុងតំបន់ភ្នំរុនដោយសកម្មភាពជនខិលខូចមួយចំនួន

២- បង្កើនមុខរបរ និងប្រាក់ចំណូលដល់ប្រជាពលរដ្ឋក្នុងតំបន់ ពិសេសប្រជាពលរដ្ឋរស់នៅក្នុងស្រុកជីក្រែង តាមរយៈការជ្រើសរើសឲ្យចូលបំរើការងារនៅក្នុងគម្រោង

៣- ជួយបង្កើនប្រាក់ចំណូលជាតិ តាមរយៈការបង់ពន្ធផ្សេងៗដល់រដ្ឋាភិបាល នៅក្នុង កំឡុងពេលដាក់ឲ្យដំណើរការគម្រោង ដែលជាការរួមចំណែកមួយជួយទ្រទ្រង់ដល់សេដ្ឋកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា

៤- គម្រោងនេះ នឹងជួយដល់ការសម្រេចនូវគោលនយោបាយចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍ប្រទេសជាតិប្រកបដោយនិរន្តរភាពជាក់ជាពុំខាន។

អនុសាសន៍មួយចំនួន ដែលក្រុមហ៊ុនវិនិយោគត្រូវអនុវត្តនៅក្នុងដំណាក់កាលមុនសាងសង់ ដំណាក់កាលសាងសង់ និងដំណាក់កាលប្រតិបត្តិគម្រោង ដូចមានរៀបរាប់ដូចខាងក្រោម៖

Draft

១. រាល់លក្ខខណ្ឌក្នុងការរៀបចំគម្រោង និងការសាងសង់ត្រូវគោរពតាមគោលការណ៍ ណែនាំ និងបទដ្ឋានបច្ចេកទេសអាជីវកម្មរ៉ែរបស់ប្រទេសកម្ពុជា ឬអន្តរជាតិ។

២. ត្រូវមានការសហការល្អជាមួយគ្រប់ក្រសួង/ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងអ្នកពាក់ព័ន្ធនានានៅក្នុងគ្រប់ដំណាក់កាលសាងសង់ និងការដាក់ឲ្យ ដំណើរការដូចជា ការជូនដំណឹង ការផ្សព្វផ្សាយស្តីពីកម្មវិធីសាងសង់ សុវត្ថិភាព ការពារគ្រោះថ្នាក់ទៅដល់ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន។

៣. ម្ចាស់គម្រោង ក្រុមហ៊ុនទីប្រឹក្សាសាងសង់ អ្នករៀបចំគម្រោងប្លង់ និងអ្នកម៉ៅការត្រូវអនុវត្តឲ្យបានត្រឹមត្រូវតាមវិធានការកាត់បន្ថយហេតុប៉ះពាល់ និងកម្មវិធីត្រួតពិនិត្យដូចដែលបានកំណត់ក្នុងផែនការគ្រប់គ្រងបរិស្ថាន កិច្ចសន្យាការពារបរិស្ថាន កិច្ចសន្យាសាងសង់ និងឯកសារបច្ចេកទេសផ្សេងៗទៀតដែលទាក់ទងនឹងគម្រោងវិនិយោគទាំងមូល។

Draft

# ជំពូកទី១៖

# សេចក្តីផ្តើម

Draft

# ជំពូក១៖ សេចក្តីផ្តើម

## ១.១- សេចក្តីផ្តើម

តាមរយៈការសិក្សាលើលក្ខណៈភូមិសាស្ត្រនៃព្រះរាជាណាកច្រកម្ពុជា បានបញ្ជាក់ថា ប្រទេសកម្ពុជាគឺ ជាប្រទេសដែលសំបូរទៅដោយសម្បត្តិធម្មជាតិដូចជា ព្រៃភ្នំដ៏ធំធេង ធនធានរ៉ែដ៏មហាសាល ប្រាង្គប្រាសាទ ប្រវត្តិសាស្ត្រដ៏ល្អប្រណិត។ល។ រ៉ែត្រូវបានចាត់ទុកជាមហាសម្បត្តិធម្មជាតិទី២ បន្ទាប់ពីព្រៃឈើដែលមាននៅក្នុងប្រទេស។

ធនធានរ៉ែក្នុងប្រទេសកម្ពុជា ត្រូវបានធ្វើការសិក្សាស្រាវជ្រាវតាំងពីជាងពាក់កណ្តាលសតវត្សន៍ទី១៩មកម្លេះ ដោយអ្នកភូមិសាស្ត្រវិទូជនជាតិបារាំង និងជនជាតិចិន។ ការសិក្សានោះ ផ្តោតសំខាន់លើទីតាំងភូមិសាស្ត្រ និងវិភាគពីធនធានរ៉ែ ហើយបានបញ្ជាក់ពីសក្តានុពលដ៏សំខាន់នៃកំណប់ធនធានរ៉ែក្នុងប្រទេសកម្ពុជាដោយរួមមាន រ៉ែមាស រ៉ែដែក រ៉ែបុកស៊ីត រ៉ែមេកានីស (manganese) ខ្សាច់ស៊ីលីការ (silica sand) កៅលាំង (kaolin) ថ្មកំបោរ (limestone) ផូស្វាត សារព្រៀ (sapphires) រូបី (rubies) ធ្យូងថ្ម ធនធានសម្រាប់ធ្វើសំណង់ និង ធនធានរ៉ែ ច្រើនសន្ធឹកសន្ធាប់ផ្សេងទៀត (gold, iron, bauxite, manganese, silica sand, kaolin, limestone, phosphate, sapphires, rubies, coal, construction materials and other minerals)។ ក៏ប៉ុន្តែរហូតមកដល់បច្ចុប្បន្ននេះ ធនធានរ៉ែទាំងនោះ ពុំទាន់មានការសិក្សាវាយតម្លៃបានច្បាស់លាស់ដើម្បីធ្វើការអភិវឌ្ឍន៍ និងធ្វើអាជីវកម្មឲ្យបានទូលំទូលាយនៅឡើយ។

រាជរដ្ឋាភិបាល ដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញនូវ ផែនការយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣ (នៃរដ្ឋសភានិតិកាលទី ៥)[1] ក្នុងរយៈពេល ៥ឆ្នាំពីឆ្នាំ ២០១៣ ដល់ ឆ្នាំ ២០១៨ ដោយក្នុងនោះ យុទ្ធសាស្ត្រទី២ ឆ្លុះបញ្ចាំងឲ្យឃើញថា ការជំរុញការអភិវឌ្ឍលើវិស័យវិនិយោគ ឧស្សាហកម្ម គឺជាជំនួយកំនើនសេដ្ឋកិច្ចជាតិ។ ក្នុងនោះដែរ វិស័យអទិភាពចំបងទី៤ ត្រូវបាន ផ្តោតសំខាន់លើ ការកែលម្អបរិយាកាសវិនិយោគ តាមរយៈការបង្កើនភាពទាក់ទាញចំពោះការវិនិយោគក្នុងនោះមានការកាត់បន្ថយថ្លៃដើម និងរបាំងធុរៈកិច្ច, ការពិនិត្យឡើងវិញនូវរបបលើកទឹកចិត្តដល់ការវិនិយោគ, ការពង្រឹងភាពជឿទុកចិត្ត និងភាពអាចប៉ាន់ប្រមាណក្នុងការធ្វើធុរកិច្ច ព្រមទាំងការផ្តោតការយកចិត្តទុកដាក់លើកិច្ចដំណើរការនៃតំបន់សេដ្ឋកិច្ចពិសេស។ ដើម្បីឆ្លើយតបទៅនឹងការអភិវឌ្ឍសង្គមជាតិ និងផែនការយុទ្ធសាស្ត្រថ្មី រដ្ឋាភិបាលកម្ពុជា បាននឹងកំពុងសហការយ៉ាងមុតមាំ ជាមួយក្រុមហ៊ុនឯកជនលើវិស័យធនធានធម្មជាតិដ៏សម្បូរបែបក្នុង ប្រទេសកម្ពុជាយើង។ ក្នុងនោះរ៉ែ គឺត្រូវបាន

សម្លឹងឃើញជាធនធានដ៏មានតម្លៃ និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិ តាមរយៈការវិនិយោគទាំងក្នុង និងក្រៅប្រទេស។ គិតត្រឹមឆ្នាំ ២០១៣ ការផ្តល់អាជ្ញាប័ណ្ណស្វែងរុករកធនធានរ៉ែក្នុងប្រទេសកម្ពុជាយើងមាន **ចំនួន ១៣៩** ស្មើនិង **៩១ក្រុមហ៊ុន** (មកពីប្រទេសអូស្ត្រាលី ប្រទេសចិន ប្រទេសវៀតណាម ប្រទេសថៃ និងក្នុងស្រុក) ត្រូវបានអនុញ្ញាតនៅតាមបណ្តាខេត្តនៅភូមិភាគឦសាននៃប្រទេស ដូចជាខេត្ត រតនៈគិរី មណ្ឌលគិរី ព្រះវិហារ ស្ទឹងត្រែង ក្រចេះ និងសៀមរាបជាដើម។ ក៏ប៉ុន្តែគម្រោងសិក្សាស្វែងរុករកតែ **១៧ គម្រោង** ប៉ុណ្ណោះ ដែលបានបង្ហាញលទ្ធផលជាវិជ្ជមាន។ ក្រសួងបានចេញអាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មរ៉ែជូនដល់ក្រុមហ៊ុន **ប្រមាណ ១៣** ក្នុងការធ្វើអាជីវកម្ម ក្នុងនោះមាន **៥** ក្រុមហ៊ុនមកពីប្រទេសចិន **៣** ក្រុមហ៊ុនមកពីប្រទេសថៃ និង **៥** ក្រុមហ៊ុនជាក្រុមហ៊ុនក្នុងស្រុក ដោយ **៤** ក្រុមហ៊ុនធ្វើអាជីវកម្មរ៉ែមាស **១** ក្រុមហ៊ុនធ្វើអាជីវកម្មរ៉ែដែក **១** ក្រុមហ៊ុនធ្វើអាជីវកម្មរ៉ែត្បូងថ្ម **៥** ក្រុមហ៊ុនធ្វើអាជីវកម្មរ៉ែកំបោរ និង **១** ក្រុមហ៊ុនធ្វើអាជីវកម្មរ៉ែថ្មស្វាត (យោងតាមវេបសាយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងរបាយការណ៍ស្តីពីស្ថានភាពបច្ចុប្បន្ននៃឧស្សាហកម្មរ៉ែក្នុងប្រទេសកម្ពុជា ឆ្នាំ២០១៣)។

តម្រូវការធនធានរ៉ែ កំពុងកើនឡើងយ៉ាងខ្លាំងសម្រាប់ផ្គត់ផ្គង់ការផលិតទំនិញ សម្ភារៈ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដូច្នេះការធ្វើអាជីវកម្មធនធានរ៉ែក្នុងស្រុកពិតជាមានសារៈសំខាន់ក្នុងការកាត់បន្ថយថ្លៃនាំចូលធនធានពីក្រៅប្រទេស។ ជាមួយគ្នានេះការធ្វើ អាជីវកម្មធនធានរ៉ែមិនត្រឹមតែ ជួយរកប្រាក់ចំណូលជូនរដ្ឋតាមរយៈការបង់ពន្ធប៉ុណ្ណោះទេ តែវាថែមទាំងបានជួយបង្កើតការងារជូនប្រជាពលរដ្ឋនៅក្នុងតំបន់ បញ្ចៀសលំហូរចូលប្រជាជនពីជនបទទៅទីក្រុង បង្កើតចំណូលការងារ និងបង្កើតឲ្យមានហេដ្ឋារចនាសម្ព័ន្ធនៅតំបន់ដាច់ស្រយាល បើយោងតាមសុន្ទរកថាក្នុងឆ្នាំ២០១០ របស់ឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការធ្វើអាជីវកម្មរ៉ែក្នុងប្រទេសកម្ពុជា។

## ១.២- សេចក្តីថ្លែងបញ្ហានៃគម្រោងអាជីវកម្មរ៉ែខ្សាច់ដែក

គេសង្កេតឃើញថា តម្រូវការធនធានរ៉ែមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដោយសារកំណើនប្រជាជន ជាពិសេសបំរែបំរួលកំរិតស្តង់ដានៃជីវភាពរស់នៅរបស់ប្រជាជននៅលើសកលលោក។ ដូចគ្នានេះ ក្នុងតំបន់អាស៊ី តម្រូវការធនធានរ៉ែក៏មានសន្ទុះយ៉ាងខ្លាំងដែរ ផ្តោតលើវិស័យហេដ្ឋារចនាសម្ព័ន្ធ និងសំណង់ ក្នុងរយៈពេល ពីរទៅបីទសវត្សន៍ កន្លងមកនេះ (Kesler, n.d)។ ជាក់ស្តែងតំរូវការក្នុងប្រទេសកម្ពុជាយើង ក៏មានការកើនឡើងគួរឲ្យកត់សំគាល់ដែរ ក្នុងប្រមាណទសវត្សន៍ចុងក្រោយនេះ ដោយសារកំនើនកំរិតជីវភាពទាំងក្នុងទីក្រុង និងជនបទ។ ម្យ៉ាងវិញទៀត ដោយសារវិស័យអាជីវកម្មធនធានរ៉ែក្នុងស្រុក នៅមិនទាន់មានការអភិវឌ្ឍបានទូលំទូលាយនៅឡើយ ហើយក្រុមហ៊ុនវិនិយោគខាងវិស័យនេះមានទំហំតូច បើប្រៀបធៀបជាមួយប្រទេសជិតខាង។

ដូច្នេះដើម្បីបំពេញសេចក្តីត្រូវការក្នុងស្រុក និងក្រៅស្រុក ក៏ដូចជាជំនួយកំនើនសេដ្ឋកិច្ចក្នុងគោលបំណងកាត់បន្ថយភាពក្រីក្រ យើងគួរតែបង្វែរចក្ខុវិស័យមកការទាញយកធនធាន ធម្មជាតិឲ្យអស់លទ្ធភាពប្រកបដោយចីរភាព។

ស្របតាមគោលនយោបាយឈ្នះឈ្នះរបស់រាជរដ្ឋាភិបាល ដែលដឹកនាំដោយ **សម្តេចអគ្គមហាសេនាតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា បានកំពុងធ្វើឲ្យប្រទេសកម្ពុជា ឈានឆ្ពោះទៅយ៉ាងរឹងមាំប្រកបដោយភាពសុទិដ្ឋិនិយម និងការប្តេជ្ញាខ្ពស់ក្នុងការអភិវឌ្ឍនប្រទេសជាតិ ដើម្បីកែប្រែមុខមាត់ និងលើកស្ទួយកិត្តិសព្ទប្រទេសកម្ពុជាឲ្យបានល្អប្រពៃ។ ដើម្បីជំរុញការអភិវឌ្ឍប្រទេសឲ្យបានជឿនលឿន ប្រមុខរាជរដ្ឋាភិបាលបានដាក់ចេញនូវ យុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី ៣ សំដៅលើកទឹកចិត្តដល់វិស័យឯកជន ក្នុងការទាក់ទាញវិនិយោគទាំងក្នុង និងក្រៅប្រទេស។ ដោយមើលឃើញអំពីសក្តានុពលនៃវិស័យវិនិយោគនៅក្នុងខេត្តសៀមរាប ជាពិសេសភាពអំណោយផលនៃធនធានធម្មជាតិ និងការវិនិយោគលើ វិស័យឧស្សាហកម្ម រួមទាំងគោលនយោបាយបើកចំហរទីផ្សារសេរី **ក្រុមហ៊ុន ម៉េង ស៊ីន ហុង ហ្វា (ខេមបូឌា) រីសស៍ អ៊ិនវេសមេន** (MENG XIN HONG FA (CAMBODIA) RESOURCES INVESTMENT CO., LTD) ដែលជាក្រុមហ៊ុនមានបទពិសោធផ្នែកអាជីវកម្មទង់ដែង និងមានរោងចក្រចំរាញ់ទង់ដែងនៅប្រទេសចិន បានស្នើសុំការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា ក្នុងការធ្វើអាជីវកម្មរ៉ែទង់ដែង និងសាងសង់រោងចក្រចម្រាញ់យកទង់ដែង (Cu) កាលពីពាក់កណ្តាលឆ្នាំ ២០១០ មានទីតាំងនៅតំបន់ឃុំខ្វាវ ស្រុកជីក្រែង ទីក្រុងសៀមរាប។

ទោះបីជាការធ្វើអាជីវកម្មធនធានរ៉ែ ផ្តល់ផលចំណេញដ៏ច្រើនចំពោះសេដ្ឋកិច្ចជាតិ ប៉ុន្តែផលប៉ះពាល់លើបរិស្ថានធម្មជាតិ និងបរិស្ថានសង្គម-សេដ្ឋកិច្ចដែលមានស្រាប់នៅតំបន់គម្រោង ពិតជាមិនអាចជៀសផុត។ ដើម្បីឆ្លើយតបនឹងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ក្នុងការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងការកាត់បន្ថយផលប៉ះពាល់បរិស្ថានឲ្យបានកំរិតអប្បបរមា ការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ គួរត្រូវបានអនុវត្តន៍ឲ្យបានម៉ត់ចត់។ ហេតុនេះ ក្រុមហ៊ុន **ម៉េង ស៊ីន ហុង ហ្វា (ខេមបូឌា) រីសស៍ អ៊ិនវេសមេន (MENG XIN HONG FA (CAMBODIA) RESOURCES INVESTMENT CO., LTD.)** បានសហការណ៍ជាមួយ ក្រុមហ៊ុន **គ្រីអេធីវ ហ្គ្រីនឌីហ្សាញ (CREATIVE GREEN DESIGN CO., LTD. (CGD))** រៀបចំការសិក្សាវាយតម្លៃពេញលេញលើហេតុប៉ះពាល់បរិស្ថាន និងសង្គមនេះឡើង ក្រោមការត្រួត ពិនិត្យយ៉ាងត្រឹមត្រូវម៉ត់ចត់ពីក្រសួងបរិស្ថាន និងបណ្តាក្រសួងពាក់ព័ន្ធនានា។

## ១.៣- ការទាញរកមូលហេតុនៃបញ្ហាដែលកើតចេញពីគម្រោងអាជីវកម្មរ៉ែ

ឈរលើមូលដ្ឋាននៃគោលគំនិត ***អភិវឌ្ឍន៍ដើម្បីអភិរក្ស អភិរក្សដើម្បីនិរន្តរភាព*** ការសិក្សាវាយតម្លៃហេតុប៉ះពាល់នៃគម្រោង ពិតជាមានសារសំខាន់ ខណៈគម្រោងអភិវឌ្ឍន៍នីមួយៗ

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

អាចនឹងបង្កហេតុប៉ះពាល់អវិជ្ជមានចំពោះមជ្ឈដ្ឋានជុំវិញ។ មូលហេតុនៃបញ្ហា និងផលប៉ះពាល់ទាំងឡាយរបស់វា គឺជាចំណុចចម្បងនៃការសិក្សា ក្នុងគោលបំណងធានាកម្រិតអប្បបរមានៃផលប៉ះពាល់អវិជ្ជមានចំពោះបរិស្ថាន សង្គម និងសេដ្ឋកិច្ច។




ដ្យាក្រាម១.១៖ គំនូសបំព្រួញនៃគោលគំនិតពីផលប៉ះពាល់នៃការធ្វើអាជីវកម្មរ៉ែទង់ដែង

## ១.៤- គោលបំណងនៃការសិក្សា

ការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញនេះ មានគោលបំណងរួមមួយគឺវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៅក្នុងតំបន់គម្រោងអភិវឌ្ឍន៍អាជីកម្មរ៉ែទង់ដែងលើផ្ទៃដី៣.៦០០ហិកតា និងជុំវិញតំបន់គម្រោង ដើម្បីឱ្យដឹងច្បាស់ថាមុនប្រតិបត្តិគម្រោង កំឡុងពេលប្រតិបត្តិគម្រោង និងក្រោយពេលគម្រោងត្រូវបានបញ្ចប់ ដែលអាចធ្វើឱ្យមានផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន-សង្គមយ៉ាងតិចបំផុត។ ដើម្បីសម្រេចបានគោលបំណងខាងលើ ការសិក្សាមានគោលបំណងជាក់លាក់មួយចំនួនដូចខាងក្រោមៈ

១. សិក្សាលំអិតពីសង្វាក់ផលិតកម្មនៃការធ្វើអាជីវកម្មរ៉ែទង់ដែង

២. សិក្សា និងវិភាគលើហេតុប៉ះពាល់ធនធានរូបសាស្ត្រ ជីវសាស្ត្រ និងសង្គម

៣. កំណត់វិធានការកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន និងរៀបចំផែនការគ្រប់គ្រងបរិស្ថាន

## ១.៥- វិសាលភាព និងដែនកំណត់សិក្សា

ការសិក្សានេះត្រូវផ្តោតសំខាន់លើទីតាំងផ្ទាល់នៃគម្រោងអាជីវកម្មរ៉ែទង់ដែង របស់ក្រុមហ៊ុនលើផ្ទៃដីទំហំ៣៦០០ហិកតា ដូចជាការសាងសង់ហេដ្ឋារចនាសម្ព័ន្ធក្នុងទីតាំងគម្រោង ដំណើរការទាញយករ៉ែទង់ដែង ការដឹកជញ្ជូន ការស្តុកទុក និងការទុកដាក់សំណល់គ្រប់ប្រភេទពីសកម្មភាពគម្រោង។ ការសិក្សាក៏ផ្តោតសំខាន់លើប្រជាជនដែលស្ថិតក្នុង និងជុំវិញតំបន់អាជីវកម្មរ៉ែទង់ដែងក្នុងភូមិចំនួន ០៣ គឺ ភូមិខ្វាវ ភូមិចុងស្ពាន និងភូមិរវៀង ស្ថិតក្នុងឃុំខ្វាវ ក្នុងស្រុកជីក្រែង ខេត្តសៀមរាម។ ការវាយតម្លៃនេះត្រូវបានធ្វើឡើងក្នុងរយៈពេល ០៦ខែ គឺចាប់ពី១៥ ខែ កញ្ញា ដល់ ១៥ ខែ កុម្ភៈ ឆ្នាំ២០១៥ ដោយក្រុមហ៊ុន **ម៉េង ស៊ីន ហុង ហ្វា (ខេមបូឌា) រីសស៍ អ៊ិនវេសមេន** **(MENG XIN HONG FA (CAMBODIA) RESOURCES INVESTMENT CO., LTD.)** សហការណ៍ជាមួយក្រុមហ៊ុន **គ្រីអេធីវ ហ្គ្រីនឌីហ្សាញ** **(CREATIVE GREEN DESIGN CO., LTD.)** ដែលមានបទពិសោធន៍ក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។

## ១.៦- មាតិកាសង្ខេប

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ" មានចំនួន ១០ជំពូកគឺៈ

១. សេចក្តីផ្តើម

២. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

៣. ក្របខណ្ឌច្បាប់ដែលពាក់ព័ន្ធ

៤. ការពិពណ៌នាអំពីគម្រោង

៥. ការពិពណ៌នាអំពីស្ថានភាពបរិស្ថានដែលមានស្រាប់

៦. ការចូលរួមជាសាធារណៈ

៧. ហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ
៨. ផែនការគ្រប់គ្រងបរិស្ថាន
៩. ការវិភាគសេដ្ឋកិច្ច និងតម្លៃបរិស្ថាន
១០. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

Draft

Creative Green Design Co., Ltd
Social-Environmental Researchs
Quality Researchers

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

# ជំពូកទី២៖
# វិធីសាស្ត្រនៃការសិក្សា

Draft

# ជំពូក២៖ វិធីសាស្ត្រនៃការសិក្សា

## ២.១ សេចក្តីផ្តើម

ជំពូកនេះគឺជា ជំពូកនៃវិធីសាស្ត្រស្រាវជ្រាវដែលត្រូវបានរៀបចំឡើង ដើម្បីបង្ហាញពីវិធីសាស្ត្រស្រាវជ្រាវទាំងមូលក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញរបស់គម្រោង **ធ្វើអាជីវកម្មរ៉ែទង់ដែង** របស់ក្រុមហ៊ុន **ម៉េង ស៊ីន ហុងហ្វា**។ ជំពូកនេះបានរៀបរាប់អំពីវិធីសាស្ត្រស្រាវជ្រាវទៅលើធនធានរូបសាស្ត្រ ជីវសាស្ត្រ ស្ថានភាពសង្គមសេដ្ឋកិច្ច វិធីសាស្ត្រការចូលរួមជាសាធារណៈ វិធីសាស្ត្រវិភាគសេដ្ឋកិច្ច និងតំលៃបរិស្ថាន វិធីសាស្ត្រកំណត់ហេតុប៉ះពាល់បរិស្ថាន ជាដើម។

## ២.២ វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យ

ចំពោះវិធីសាស្ត្រក្នុងការប្រមូលទិន្នន័យត្រូវបានបែងចែកជាពីរផ្នែកគឺ ទិន្នន័យបឋម និងទិន្នន័យបន្ទាប់បន្សំ។

### ២.២.១ ទិន្នន័យបឋម

ការចុះសិក្សាផ្ទាល់ដល់ទីតាំងធ្វើអាជីវកម្មមានដូចជា៖

→ ការប្រើប្រាស់ដីក្នុងតំបន់ និងស្ថានភាពបរិស្ថាន
→ ការសិក្សាដោយផ្ទាល់ទៅលើធនធានរូបសាស្ត្រ ជីវសាស្ត្រ និងស្ថានភាពសង្គមសេដ្ឋកិច្ច
→ ការពិសោធន៍ ការវិភាគដោយផ្ទាល់ទៅលើធនធានបរិស្ថាន
→ សកម្មភាពជីករ៉ែ ដំណើរការដឹកជញ្ជូន ស្តុកទុក ប្រព័ន្ធសុវត្ថិភាពការងារក្នុងទីតាំងអាជីវកម្ម
→ ការសម្ភាសន៍ផ្ទាល់ជាមួយម្ចាស់ក្រុមហ៊ុនអាជីវកម្ម អាជ្ញាធរ ស្ថាប័នដែលពាក់ព័ន្ធ និងប្រជាជន

#### ២.២.២ ទិន្នន័យបន្ទាប់បន្សំ

ការចុះយកទិន្នន័យពីស្ថាប័នពាក់ព័ន្ធនានាដូចជាៈ

→ ឯកសារព័ត៌មានតាមក្រសួង មន្ទីរ សាលាសង្កាត់-ខណ្ឌ និងក្រុមហ៊ុនអភិវឌ្ឍន៍ដូចជាច្បាប់ពាក់ព័ន្ធ គោលនយោបាយ បទបញ្ញាត្តិ ផែនការអភិវឌ្ឍន៍ និងទិន្នន័យ ផ្សេងៗ ពាក់ព័ន្ធនឹងគម្រោងអភិវឌ្ឍន៍

→ ឯកសារតាមបណ្ណាល័យ បណ្ណាគារ

→ ការស្រាវជ្រាវតាមប្រព័ន្ធអ៊ិនធឺណែត។ល។

## ២.៣ វិធីសាស្ត្រក្នុងការសិក្សាស្រាវជ្រាវ

### ២.៣.១ វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យបរិស្ថានរូបសាស្ត្រ

#### ២.៣.១.១- ការវិភាគគុណភាពទឹក

ក្នុងតំបន់ធ្វើអាជីវកម្មរ៉ែទង់ដែង លើផ្ទៃដីទំហំ៣៦គីឡូម៉ែត្រក្រឡា មានប្រភពទឹកឆ្លងកាត់សំខាន់ចំនួន ០៣គឺអូរបើក អូរដៃស្ទឹងជីក្រែង និង ដៃអូរខ្វាវ ហើយនៅក្នុងការដ្ឋានធ្វើអាជីវកម្មមានអណ្តូងជីករ៉ែបើកចំនួន៣កន្លែង។ ក្រៅពីនោះនៅក្បែរ និងជុំវិញតំបន់គម្រោងក៏មានប្រភពទឹកផ្សេងទៀតដូចជា បឹងឆ្នូន អូរស្រែជមជាដើម។ ដូច្នេះការសិក្សាហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញបានជ្រើសរើសសំណាក ដើម្បីវិភាគគុណភាពទឹកចំនួន២ប្រភេទគឺ ទឹកលើដី និងក្រោមដី។ ចំពោះចំនួនសំណាក និងប៉ារ៉ាម៉ែត្រដែលជ្រើសរើសដើម្បីវិភាគ មានបញ្ជាក់ និងរៀបរាប់ខាងក្រោមៈ

##### ក- ទឹកលើដី

ក្រុមហ៊ុនបានជ្រើសរើសទីតាំងយកសំណាកទឹកលើដីចំនួន **៩កន្លែង** សម្រាប់វិភាគគុណភាពទឹក។ ប្រភពទឹកដែលជ្រើសរើសនេះជាដៃអូរតូចៗហូរកាត់តំបន់គម្រោង ប្រព័ន្ធបឹង អូរក្រៅតំបន់គម្រោង និងអណ្តូងរ៉ែបើក។ ទីតាំងយកសំណាកទឹកមានបញ្ជាក់ក្នុងតារាងខាងក្រោមៈ

តារាង២.១៖ ចំណុច និងទីតាំងយកសំណាកទឹកលើដី ត្រូវបានកំណត់ដូចខាងក្រោមៈ

| សំណាកទឹក | ប្រភេទសំណាក | ទីតាំង | ចំនួនសំណាក |
|---|---|---|---|
| ទី១ | ទឹកអូរ | អូរចាក់មុខ | ១សំណាក |

Draft

| | | | |
|---|---|---|---|
| ទី២ | ទឹកអូរ | ដៃស្ទឹងជីក្រែង | ១សំណាក |
| ទី៣ | ទឹកអូរ | ដៃអូរខ្ទារ | ១សំណាក |
| ទី៤ | ទឹកស្ទឹង | ចំនុចប្រសព្វនៃអូរបើក និងស្ទឹងជីក្រែង | ១សំណាក |
| ទី៥ | ទឹកអូរ | អូរស្រែដម | ១សំណាក |
| ទី៦ | ទឹកបឹង | បឹងធ្នូន | ១សំណាក |
| ទី៧ | ទឹកចេញពីអណ្តូងជីករ៉ែ | រណ្តៅជីករ៉ែទី១ | ១សំណាក |
| ទី៨ | ទឹកចេញពីអណ្តូងជីករ៉ែ | រណ្តៅជីករ៉ែទី២ | ១សំណាក |
| ទី៩ | ទឹកចេញពីអណ្តូងជីករ៉ែ | រណ្តៅជីករ៉ែទី៣ | ១សំណាក |

ខ- ទឹកក្រោមដី

ចំពោះគុណភាពទឹកក្រោមដី ការសិក្សាបានយកសំណាកទឹកចំនួន **២កន្លែង** ដែលសំណាកទី១គឺទឹកអណ្តូងស្នប់ក្នុងការដ្ឋានក្រុមហ៊ុន និងសំណាកទី២គឺទឹកអណ្តូងស្នប់ក្នុងភូមិខ្ទារ។

តារាង២.២៖ ចំណុច និងទីតាំងយកសំណាកទឹកក្រោមដី ត្រូវបានកំណត់ដូចខាងក្រោម៖

| សំណាកទឹក | ប្រភេទសំណាក | ទីតាំង | ចំនួនសំណាក |
|---|---|---|---|
| ទី១ | ទឹកក្រោមដី | ទឹកអណ្តូងស្នប់ក្នុងទីតាំងគម្រោង | ១ |
| ទី១ | ទឹកក្រោមដី | ទឹកអណ្តូងស្នប់ក្នុងភូមិខ្ទារ | ១ |

គ- ប៉ារ៉ាម៉ែត្រ និងវិធីសាស្ត្រវិភាគគុណភាពទឹក

ការវិភាគគុណភាពទឹកនេះត្រូវបានជ្រើសរើសប៉ារ៉ាម៉ែត្រចំនួន **២៤ ប៉ារ៉ាម៉ែត្រ** ដើម្បីវិភាគ ដែលមានបង្ហាញឈ្មោះប៉ារ៉ាម៉ែត្រ និងវិធីសាស្ត្រវិភាគដូចខាងក្រោម៖

តារាង២.៣៖ ប៉ារ៉ាម៉ែត្រ និងវិធីសាស្ត្រសម្រាប់វិភាគគុណភាពទឹក

| ល.រ | ប៉ារ៉ាម៉ែត្រ | វិធីសាស្ត្រវិភាគ | ល.រ | ប៉ារ៉ាម៉ែត្រ | វិធីសាស្ត្រវិភាគ |
|---|---|---|---|---|---|
| ១ | pH | Method MAJI Meter | ១៣ | Total Nitrogen | Method JIS K 0102 45 |
| ២ | Turbidity | Method MAJI Meter | ១៤ | Total Phosphorus | Method JIS K 0102 46 |

| ល.រ | ប៉ារ៉ាម៉ែត្រ | វិធីសាស្ត្រវិភាគ | ល.រ | ប៉ារ៉ាម៉ែត្រ | វិធីសាស្ត្រវិភាគ |
|---|---|---|---|---|---|
| ៣ | Total Dissolved Solid | Method MAJI Meter | ១៥ | Arsenic | Method 3500-As D |
| ៤ | Dissolved Oxygen | Method MAJI Meter | ១៦ | Copper | Method 3500-Cu C |
| ៥ | Total Suspended Solid | Method 2540 D | ១៧ | Iron | Method 3500-Fe C |
| ៦ | Ammonium | Method ICs 90 | ១៨ | Lead | Method 3500-Pb C |
| ៧ | Chloride | Method4500-Cl F | ១៩ | Mercury | Method ICP-MS |
| ៨ | Nitrade | Method 4500-NO3 C | ២០ | Zinc | Method 3500-Zn C |
| ៩ | Phosphate | Method ICs 90 | ២១ | Total Coliform | Method NF T90-413 (37 °C) |
| ១០ | Sulphate | Method 4500-$SO4^{2-}$ B | ២២ | E-Coli | Method NF T90-413 (44 °C) |
| ១១ | Biochemical Oxygen Demand | Method 5210 B | ២៣ | Salinity | Method MAJI Meter |
| ១២ | Chemical Oxygen Demand | Method JIS K 0102 | ២៤ | Temperature | Method MAJI Meter |

### ២.៣.១.២- ការវិភាគគុណភាពខ្យល់

នៅក្បែរតំបន់ទីតាំងអាជីវកម្មមានភូមិចំនួន៣ ដូចជាភូមិខ្វាវ ភូមិចុងស្ពាន និងភូមិរវៀង ប៉ុន្តែភូមិដែលស្ថិតនៅជិតបំផុតមានចម្ងាយប្រមាណ០៥គីឡូម៉ែត្រ ពីទីតាំងអាជីវកម្ម។ ដោយសារទីតាំង ធ្វើអាជីវកម្មរ៉ែទង់ដែងនេះ មានទីតាំងឆ្ងាយពីទីតាំងភូមិប្រជាជនរស់នៅ ហេតុដូចនេះ ការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញនៃគម្រោងបានកំណត់ជ្រើសរើសទីតាំងសម្រាប់វិភាគគុណភាពខ្យល់ចំនួន ២កន្លែងគឺទីតាំងទី១ ស្ថិតនៅក្នុងការដ្ឋានជីកយករ៉ែ និងទីតាំងទី២ ស្ថិតនៅក្នុងការដ្ឋានរោងចក្រប្រព្រឹត្តិកម្មរ៉ែ។

តារាង២.៤៖ ទីតាំង និងចំនួនសំណាកត្រូវយក

| ល.រ | ទីតាំង | ចំណុចនិយាមការ | ចំនួនសំណាក |
|---|---|---|---|
| ១ | ការដ្ឋានជីករ៉ែ | X=០៤៤០៦១១<br>Y= ១៤៤៩០០០ | ១ |
| ២ | រោងចក្រចម្រាញ់រ៉ែ | X=០៤៤២១៥០<br>Y= ១៤៤៧០៩៣ | ១ |
| សរុប | | | ២សំណាក |

Draft

ការកត់ត្រាកម្រិតគុណភាពខ្យល់ ត្រូវបានធ្វើឡើងក្នុងរយៈពេល២៤ម៉ោង ចំពោះសំណាក $NO_2$ $SO_2$ TSP និងCO ក្នុងរយៈពេល៨ម៉ោង។ ចំពោះវិធីសាស្ត្រ ឬឧបករណ៍សម្រាប់វិភាគគុណភាពខ្យល់ មានរៀបរាប់ក្នុងតារាងខាងក្រោម៖

តារាង២.៥៖ សំណាក និងឧបករណ៍/វិធីសាស្ត្រប្រើប្រាស់

| ល.រ | ឈ្មោះសំណាក | ឧបករណ៍/វិធីសាស្ត្រ |
|---|---|---|
| ១ | CO | Detetion Tube |
| ២ | $NO_2$ | Saltzman Method |
| ៣ | $SO_2$ | Pararosaniline Method |
| ៤ | TSP | Low Valume Sampler Method |

### ២.៣.១.៣- ការវិភាគកម្រិតសំលេង

ការសិក្សានេះនឹងធ្វើការវិភាគសំលេង ដែលនឹងកំណត់យកសំណាក **០២កន្លែង** ដូចគ្នាទៅនឹងការវិភាគគុណភាពខ្យល់ផងដែរ ដែលទីតាំងទី១ ស្ថិតនៅក្នុងការដ្ឋានជីកយករ៉ែ និងទីតាំងទី២ ស្ថិតនៅក្នុងការដ្ឋានរោងចក្រប្រព្រឹត្តិកម្មរ៉ែ ការវិភាគសំលេងនេះ ត្រូវបានប្រើឧបករណ៍ Sound Level Meter NL-21 ដោយធ្វើការកត់ត្រារយៈពេល ២៤ម៉ោង។ ចំពោះការកត់ត្រា កម្រិតសំលេងនេះ ត្រូវមានធ្វើឡើងក្នុងរយៈពេល ១ម៉ោងម្តង។

តារាង២.៦៖ សំណាក និងឧបករណ៍/វិធីសាស្ត្រប្រើប្រាស់

| ល.រ | ទីតាំង | ចំណុចនិយាមការ | ចំនួនសំណាក |
|---|---|---|---|
| ១ | ការដ្ឋានជីករ៉ែ | X=០៤៤២១៥០<br>Y= ១៤៨៧០៩៣ | ១ |
| ២ | រោងចក្រចម្រាញ់រ៉ែ | X=០៤៤០៦១១<br>Y= ១៤៨៩០០០ | ១ |
| សរុប | | | ២ |

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

### ២.៣.២ វិធីសាស្ត្រក្នុងប្រមូលទិន្នន័យបរិស្ថានជីវសាស្ត្រ

#### ២.៣.២.១ វិធីសាស្ត្រក្នុងការសិក្សាព្រៃឈើ

##### ក. ការកំណត់ប្រភេទព្រៃ

ការកំណត់ចំនួនឡូត៍-អនុឡូត៍គំរូ គឺផ្អែកលើរូបមន្តជ្រើសរើសចំនួនសំណាក តាមគោលការណ៍ណែនាំសម្រាប់វាយតម្លៃជីវម៉ាស់ព្រៃឈើរបស់រដ្ឋបាលព្រៃឈើ និង អង្គការ Winrock។ តាមការគណនាតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្របានបង្ហាញថា ទីតាំងគម្រោងមានប្រភេទព្រៃបីប្រភេទ រួមមានព្រៃស្រោងទំហំ **៦៣២ហិកតា** ព្រៃពាក់កណ្ដាលស្រោង **៣១ហិកតា** និងព្រៃល្បោះទំហំ **២.២៤៣ហិកតា** និងដីពុំមានគម្របព្រៃឈើទំហំ **៦៩៤ហិកតា**។ ដូច្នេះការកំណត់ចំនួនឡូត៍ ត្រូវបានគណនាទៅតាមទំហំនៃប្រភេទព្រៃ**នី**មួយៗដែលទំហំប្រភេទព្រៃនីមួយៗ ដោយប្រើប្រាស់ផែនទីគម្របព្រៃឈើឆ្នាំ ២០១០ របស់រដ្ឋបាលព្រៃឈើជាមូលដ្ឋាន។

ការសិក្សាលើសារព័ន្ធរុក្ខជាតិក្នុងតំបន់គម្រោងនេះបានកំណត់យកឡូត៍អនុឡូត៍គំរូចំនួន ១៣ ឡូត៍មកសិក្សាក្នុងកំរិតលម្អៀង ១០% ដែលនឹងដាក់តាំងទៅតាមប្រភេទព្រៃដូចខាងក្រោម៖

តារាង**២.៧**៖ ឡូត៍-អនុឡូត៍គំរូសម្រាប់សិក្សាសារព័ន្ធរុក្ខជាតិ

| ល.រ | ឡូត៍-អនុឡូត៍គំរូ | x | y | សំគាល់ |
|---|---|---|---|---|
| 1 | Plot 1 | 440987 | 1486346 | ព្រៃស្រោង |
| 2 | Plot 2 | 441760 | 1486475 | ព្រៃស្រោង |
| 3 | Plot 3 | 440746 | 1489580 | ព្រៃស្រោង |
| 4 | Plot 4 | 441357 | 1489580 | ព្រៃស្រោង |
| 5 | Plot 5 | 443175 | 1489564 | ព្រៃស្រោង |
| 6 | Plot 6 | 443208 | 1488856 | ព្រៃស្រោង |
| 7 | Plot 7 | 438832 | 1487311 | ព្រៃល្បោះ |
| 8 | Plot 8 | 438767 | 1486523 | ព្រៃល្បោះ |
| 9 | Plot 9 | 440810 | 1487778 | ព្រៃល្បោះ |
| 10 | Plot 10 | 441727 | 1487714 | ព្រៃល្បោះ |
| 11 | Plot 11 | 442484 | 1485542 | ព្រៃល្បោះ |
| 12 | Plot 12 | 443336 | 1484898 | ព្រៃល្បោះ |
| 13 | Plot 13 | 440762 | 1485188 | ព្រៃល្បោះ |

Draft

**ផែនទីបង្ហាញទីតាំងឡូតិ៍-អនុឡូតិ៍គម្រូសិក្សាសារ ព័ន្ធរុក្ខជាតិក្នុង តំបន់គម្រោងរបស់ក្រុមហ៊ុន**
Meng Xin Hong FA ( Cambodia ) Resources Investment Co., Ltd **ស្រុកជីក្រែង ខេត្តសៀមរាប**




| ឡូតិ៍-អនុឡូតិ៍ | x | y | សំគាល់ |
|---|---|---|---|
| Plot 1 | 440987 | 1486346 | EF |
| Plot 2 | 441760 | 1486475 | EF |
| Plot 3 | 440746 | 1489580 | EF |
| Plot 4 | 441357 | 1489580 | EF |
| Plot 5 | 443175 | 1489564 | EF |
| Plot 6 | 443208 | 1488856 | EF |
| Plot 7 | 438832 | 1487311 | DF |
| Plot 8 | 438767 | 1486523 | DF |
| Plot 9 | 440810 | 1487778 | DF |
| Plot 10 | 441727 | 1487714 | DF |
| Plot 11 | 442484 | 1485542 | DF |
| Plot 12 | 443336 | 1484898 | DF |
| Plot 13 | 440762 | 1485188 | DF |

រូបភាព២.១៖ បង្ហាញទីតាំងឡូតិ៍ អនុឡូតិ៍គំរូសិក្សាសារព័ន្ធរុក្ខជាតិក្នុងតំបន់គម្រោង

ខ. កំណត់ប្រភេទប្លង់ជំផិស

ក្នុងការគណនាចំនួនឡូត៍-អនុឡូត៍គំរូ សម្រាប់ធ្វើសារពើភ័ណ្ឌវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើ គឺ ផ្អែកលើគោលការណ៍ណែនាំសម្រាប់ធ្វើសារពើភ័ណ្ឌរបស់រដ្ឋបាលព្រៃឈើ។ ឡូត៍អនុឡូត៍គំរូ សម្រាប់ធ្វើសារពើភ័ណ្ឌវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើនៅក្នុងតំបន់ធ្វើអាជីវកម្មរ៉ែទង់ដែង ដោយសារផ្ទៃដីមានទំហំ៣.៦០០ហិកតា ដែលគ្របដណ្តប់ដោយព្រៃល្បោះ ។

ដូចនេះក្រុមការងារសម្រេចដាក់តាំងឡូត៍អនុឡូត៍គំរូសិក្សាតាមលំដាប់ថ្នាក់អង្កត់ផ្ចិតដូចខាងក្រោម៖

- អង្កត់ផ្ចិត ចាប់ពី ៥-១៤សម សិក្សាចំនួន ១០ឡូត៍គំរូ
- អង្កត់ផ្ចិត ចាប់ពី១៥-៣០សម សិក្សាចំនួន ១០ឡូត៍គំរូ
- អង្កត់ផ្ចិត ធំជាង៣០សម សិក្សាចំនួន ១០ឡូត៍គំរូ

ចំពោះឡូត៍-អនុឡូត៍គំរូ ដែលបានដាក់តាំងសម្រាប់ការសិក្សាវាយតម្លៃធនធានព្រៃឈើ និងសត្វព្រៃនៅក្នុងតំបន់ គម្រោងអាជីវកម្មរបស់ក្រុមហ៊ុន **ម៉េង ស៊ីន ហុង ហ្វា (ខេមបូឌា) រីសស៍ អ៊ិនវេស មេន** គឺបានដាក់តាំងលក្ខណៈជាប្រព័ន្ធ ដែលខ្សែវាស់រាប់មួយ ទៅខ្សែវាស់រាប់មួយទៀតមានគំលាត ១០០ម៉ែត្រស្មើៗគ្នា។ ដោយឡែកចន្លោះឡូត៍មួយទៅឡូត៍មួយទៀតមាន គំលាត១០០ម៉ែត្រ (ដូចរូបក្រាម២.១) ។មុននឹងដាក់តាំងឡូត៍-អនុឡូត៍គំរូសិក្សានេះក្រុមការងារធ្វើការ ជ្រើសរើសទីតាំង សមស្របមួយ សម្រាប់ដាក់តាំងឡូត៍គំរូសិក្សាវាយតម្លៃ ដោយធ្វើយ៉ាងណាឲ្យឡូត៍-អនុឡូត៍គំរូគ្របដណ្តប់បានគ្រប់ប្រភេទព្រៃ ដែលមាននៅក្នុងតំបន់គម្រោង។

តារាង២.៨៖ ទំហំឡូត៍ និងអនុឡូត៍គំរូ

| ថ្នាក់អង្កត់ផ្ចិត | ទំហំឡូត៍ | ផ្ទៃដី | ចំនួនឡូត៍គំរូ |
|---|---|---|---|
| ០៥ទៅ ១៤ស.ម | ៣០ម X ២៥ម | ០.០៧៥ ហិកតា | ១០ |
| ១៥ទៅ ៣០ ស.ម | ៣០ម X ៥០ម | ០.១៥០ ហិកតា | ១០ |
| ធំជាង ៣០ស.ម ឡើងទៅ | ៣០ X ១០០ម | ០.៣០០ ហិកតា | ១០ |

គ. ការប្រើប្រាស់ឧបករណ៍វាស់វែង

→ វាស់ទំហំអង្កត់ផ្ចិត៖ ប្រើខ្សែម៉ែត្រវាស់អង្កត់ផ្ចិត (Diameter tap)

→ វាស់កំពស់៖ ប៉ាន់ស្មានដោយភ្នែកទទេ។




| | ថ្នាក់អង្កត់ផ្ចិត | ទំហំឡូត៍-អនុឡូត៍ |
|---|---|---|
| (ផ្ទៃងងឹត) | 05-14ស.ម | 30ម*25ម = 0.075 ហ.ត |
| (ផ្ទៃស) | 15-30ស.ម | 30ម*50ម = 0.15 ហ.ត |
| (ផ្ទៃងងឹត) | >30ស.ម | 30ម*100ម = 0.300 ហ.ត |

ដ្យាក្រាម២.១៖ទំហំឡូត៍គំរូ

Draft

ឃ. ការរៀបចំការងារសារពើភ័ណ្ឌ

→ **ការរៀបចំព្រំប្រទល់អនុតំបន់៖** លាបថ្នាំពណ៌ក្រហមតាមបណ្តោយព្រំប្រទល់ដែលបានកាប់ឆ្ការ ឬមានដោយធម្មជាតិ។

→ **ការរៀបចំខ្សែប្រឡោះព្រៃ៖** ត្រើយបើកប្រឡោះព្រៃដែលមានទទឹងពី ១ម៉ែត្រ ឬ២ម៉ែត្រ និងបោះបង្គោល ពីមួយទៅមួយប្រវែង ២៥ម៉ែត្រ ដោយមានការបាញ់ថ្នាំពណ៌ ក្រហមទៅបង្គោល ឬដើមឈើនៅក្បែរនោះ។ ចំងាយពីខ្សែប្រលោះព្រៃមួយទៅខ្សែមួយទៀតប្រវែង ៣០០ម៉ែត្រ និងធ្វើអត្តសញ្ញាណនៅនឹងគល់ខ្សែ ដោយដាក់ជាលេខសម្រាប់សំគាល់តាមលំដាប់លំដោយ។

ង. ចាត់តាំងការងារអនុវត្តន៍ជាក់ស្តែងលើទីវាល

❖ **សមាសភាពក្រុមរៀបចំព្រំប្រទល់ និង ប្រឡោះព្រៃសារពើភ័ណ្ឌ** មានសមាជិកចំនួន ៥នាក់ ក្នុងនោះ ៖

→ ១នាក់ (អ្នកបច្ចេកទេស) ប្រធានក្រុមជាអ្នកប្រើឧបករណ៍ GPS និងកាន់ត្រីវិស័យ តំរង់ទិស

→ ២នាក់(កម្មករ) ជាអ្នកត្រាយបើកប្រឡោះព្រៃ

→ ៣នាក់(កម្មករ) ជាអ្នកទាញខ្សែម៉ែត្រវាស់ចំងាយរត់បង្គោលវាយស្លាក និងលាបថ្នាំពណ៌

❖ **សមាសភាពក្រុមវាស់រាប់** មានសមាជិកចំនួន ៧នាក់ ក្នុងនោះ៖

→ ១នាក់(អ្នកបច្ចេកទេស) ប្រធានក្រុមដឹកនាំក្រុម និងកត់ត្រាលទ្ធផលវាស់រាប់

→ ២នាក់ (អ្នកបច្ចេកទេស) វាស់អង្កត់ផ្ចិត ប៉ាន់ស្មានកំពស់ កំណត់គុណភាព និងហៅឈ្មោះឈើ

→ ២នាក់(កម្មករ) ត្រាយព្រៃ លាបថ្នាំសំគាល់ ធ្វើព្រំប្រទល់ឡូតិ៍ និង អនុឡូតិ៍គំរូ

→ ២នាក់(កម្មករ) ជំនួយការវាស់អង្កត់ផ្ចិត ប៉ាន់ស្មានកំពស់ កំណត់គុណភាព និងហៅឈ្មោះឈើ (ជាអ្នកស្គាល់ឈ្មោះឈើច្បាស់លាស់)

## ២.៣.២.២ វិធីសាស្ត្រក្នុងការសិក្សាសត្វព្រៃ

### ក. ការសម្ភាស

ការសិក្សាលើវត្តមានសត្វព្រៃ គឺធ្វើតាមរយៈការសម្ភាស ជាមួយប្រជាពលរដ្ឋមូលដ្ឋាន និងអ្នកបរបាញ់ ឬអ្នកដាក់អន្ទាក់ដែលធ្លាប់ចូលទៅប្រើប្រាស់ ផល-អនុផលព្រៃឈើ បរបាញ់ និងដាក់អន្ទាក់

ក្នុង ឬក្បែរទីតាំងគម្រោង។ការសម្ភាសគឺធ្វើឡើងជាលក្ខណៈមិនផ្លូវការ ដោយគ្រាន់តែពិភាក្សា ឬសាកសួរព័ត៌មានវត្តមានសត្វព្រៃក្នុងតំបន់របស់គាត់ ក្នុងកំឡុងពេល ១០ឆ្នាំចុងក្រោយ។

### ខ. ការដាក់តាំងត្រង់ស៊ិក

បន្ថែមលើព័ត៌មាន ដែលទទួលបានពីការសម្ភាសប្រជាពលរដ្ឋ នៅក្នុងតំបន់គម្រោង ក្រុមការងារសិក្សាវត្តមាន សត្វព្រៃនឹងធ្វើការអង្កេតវត្តមានសត្វព្រៃនៅតាមបន្ទាត់ត្រង់ស៊ិក ចំនួន **៥ត្រង់ស៊ិក** ចម្ងាយសរុបប្រមាណជា **១៣ គីឡូម៉ែត្រ** ដែលនឹងដាក់អង្កេតនៅទីតាំងផ្សេងៗគ្នាក្នុងតំបន់គម្រោង (ដូចផែនទី៤.២៣ បង្ហាញទីតាំងត្រង់ស៊ិកសិក្សាវត្តមានសត្វព្រៃ)។ នៅតាមបណ្តោយ និងសងខាងបន្ទាត់ត្រង់ស៊ិក ក្រុមការងារអង្កេត និងកត់ត្រាលើសម្លេង ដានជើង លាមក រោម ឬស្លាកស្នាមផ្សេងៗ ដែលបានលឺ ឬជួបនៅទីវាល។

ការសិក្សាស្រាវជ្រាវ និងការកត់ត្រាទិន្នន័យ គឺធ្វើឡើងនៅក្នុងកំឡុងពេលនៃការដើរអង្កេតនៅលើបន្ទាត់ត្រង់ស៊ិក តាមរយៈការពិនិត្យមើលដោយភ្នែកផ្ទាល់ទៅលើវត្តមានសត្វសងខាង (ទាំងខាងឆ្វេង និងស្តាំនៃ បន្ទាត់ត្រង់ស៊ិក) សម្លេង ដានជើង លាមក រោម ឬសញ្ញានៃក្រញ៉ៅលើសំបកឈើ ឬសញ្ញាណផ្សេងៗ ដែលអាចកំណត់ពីវត្តមានរបស់សត្វ ដែលត្រូវកត់ត្រាបញ្ចូលទៅក្នុងតារាងទិន្នន័យ (Worksheet)។

តារាង២.៩ លេខត្រង់ស៊ិច និងប្រវែង

| **លេខត្រង់ស៊ិច** | **ប្រវែង (ម៉ែត្រ)** |
|---|---|
| ត្រង់ស៊ិច ១ | ២.៣៩០ |
| ត្រង់ស៊ិច ២ | ២.៧៨៨ |
| ត្រង់ស៊ិច ៣ | ២.៩៩៧ |
| ត្រង់ស៊ិច ៤ | ២.៧៦៩ |
| ត្រង់ស៊ិច ៥ | ២.១៩១ |
| សរុប | ១៣.១៣៥ ម៉ែត្រ |

Draft




រូបភាព២.២៖ ត្រង់ស៊ិកសម្រាប់សិក្សាវត្តមានសត្វព្រៃ

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

### គ. ការអង្កេតផ្ទាល់

ការអង្កេតផ្ទាល់នៅទីវាលជាក់ស្តែងត្រូវបានប្រើវិធីសាស្ត្រដូចខាងក្រោមៈ

- **ថនិកសត្វៈ** អង្កេតលើដាន សម្លេង លាមក ដានជើង (លើដី ស្លឹកឈើ រឺ លើសំបកឈើ) រន្ធនៅលើ ដើមឈើជាដើម ស្ថានភាពជម្រកនិងការបរបាញ់ រឺ ការដាក់អន្ទាក់
- **បក្សី ៈ** សិក្សាពេលព្រឹក និងពេលល្ងាច វាយតម្លៃលើជម្រក និងការសង្កេតផ្សេងៗទៀត
- **ឧរង្គសត្វរីល្អូនៈ** ស្លាកស្នាមបន្សល់ទុកលើសំបកឈើ ដាន រឺភស្តុតាងផ្សេងៗទៀតដែលបន្សល់

ការអង្កេតត្រូវបានធ្វើឡើង នៅក្នុងទីតាំងដែលបានដាក់តាំងឡូត៍-អនុឡូត៍គំរូសិក្សាវាយតម្លៃធនធានដើមឈើ និងការដើរអង្កេត ដោយលៃយ៉ាងណាឲ្យគ្របដណ្តប់ទូទាំងតំបន់សិក្សាស្រាវជ្រាវ។ ក្រុមការងារដើរអង្កេតសត្វព្រៃ ត្រូវបានចែកជាពីរក្រុម ហើយដើរក្នុងគំលាតពីគ្នា ២គីឡូម៉ែត្រ និងដើរក្នុងកំរិតល្បឿន ៥០០ម៉ែត្រ/ម៉ោង ក្នុងគោលបំណងឃ្លាំមើលសត្វ ស្តាប់សំលេង ថតរូបភាព និងកត់ត្រាចំនុចនិយាមការ ដើម្បីរៀបចំផែនទីរបាយសត្វព្រៃ ឬទីជំរកក្នុងទីតាំងសិក្សាស្រាវជ្រាវ។

ប្រភពៈ (Alan Rabinowitz, 2000, ឯកសារបណ្តុះបណ្តាលការអភិរក្ស និងស្រាវជ្រាវសត្វព្រៃនៅលើភូមិសាស្ត្រ)។

Draft

### ឃ. ក្រុមសិក្សាវត្តមានសត្វព្រៃ

ការសិក្សាវត្តមានសត្វនៃគម្រោងធ្វើអាជីវកម្មរ៉ែនេះ មានសមាជិកចំនួន ៥នាក់ ដែលមានដូចខាងក្រោមៈ

- ១នាក់ (អ្នកបច្ចេកទេស) ប្រធានក្រុមដឹកនាំក្រុម និងកត់ត្រាលទ្ធផល។
- ២នាក់ (ជំនួយការអ្នកបច្ចេកទេស) ស្តាប់សម្លេងសត្វ ផ្ទៀងផ្ទាត់ដាន និងកំណត់អត្តសញ្ញាណសត្វ។
- ២នាក់ (អ្នកភូមិ) ជំនួយការនាំផ្លូវ ស្តាប់សម្លេងសត្វ ផ្ទៀងផ្ទាត់ដាន (ជាអ្នកស្គាល់ឈ្មោះសត្វ)។

## ២.៣.៣ វិធីសាស្ត្រក្នុងការសិក្សាលើស្ថានភាព-សេដ្ឋកិច្ច

### ២.៣.៣.១-ការជ្រើសរើសសំណាកប្រជាជន

ដោយសារការធ្វើអាជីវកម្មរ៉ែទង់ដែង ស្ថិតក្នុងតំបន់ភ្នំរុន ឃុំខ្នារ ស្រុកជីក្រែង ខេត្តសៀមរាប វាអាចមានផលប៉ះពាល់ចំពោះប្រជាជនរស់ក្នុង និងក្បែរតំបន់អាជីវកម្មនេះ។ ដូច្នេះ ប្រជាជនក្នុងភូមិចំនួន ០៣ គឺ ភូមិខ្នារ ភូមិចុងស្ពាន ភូមិរវៀង ដែលកំពុងរស់នៅតំបន់ខាងលើ ត្រូវបានសម្រេចជ្រើសរើសសម្រាប់ការសិក្សាអំពីបរិស្ថាន សេដ្ឋកិច្ច និងសង្គម ក៏ដូចជាមតិយល់ឃើញចំពោះផលប៉ះពាល់នៃ

គម្រោង មុនចាប់ផ្តើម និងក្រោយបញ្ចប់ការអភិវឌ្ឍ។ ដើម្បីប្រមូលព័ត៌មានពីប្រជាជនឲ្យមានប្រសិទ្ធភាព និងគ្រប់គ្រាន់ វិធីសាស្ត្រគំរូសំណាកចៃដន្យ (Random Sampling) ត្រូវបានអនុវត្តក្នុងការសិក្សាស្រាវជ្រាវនេះ។ ការជ្រើសរើសចំនួនសំណាកប្រជាជនត្រូវបានប្រើរូបមន្ត ថារ៉ូ (Taro Yamane) ដែលកំណត់យកកម្រិតលម្អៀង១០%។ សំណាកប្រជាជនសរុបសម្រាប់ការជួបសម្ភាសន៍គឺ ៩២គ្រួសារ ដោយត្រូវបានគណនាពីចំនួនប្រជាជនសរុបក្នុងភូមិទាំងបីខាងលើ និងបង្ហាញដូចខាងក្រោម៖

តាមរូបមន្តថារ៉ូ៖

$$n = \frac{N}{1 + Ne^2}$$

ដែល៖

- n : ចំនួនសំណាកគំរូ
- N : ចំនួនគ្រួសារសរុប
- e : កំរិតលម្អៀង = ១០%

$$nx = \frac{125}{956} \times 92 \cong 62$$

ចំនួនសំណាកតាមភូមិនីមួយៗ ត្រូវបានបង្ហាញដូចក្នុងតារាងខាងក្រោម៖

តារាង២.១០៖ សំណាកតាមភូមិនីមួយៗ

| ល.រ | ឈ្មោះភូមិ | ចំនួនគ្រួសារសរុប | ចំនួនសំណាក |
|---|---|---|---|
| ១ | ខ្វាវ | ៦៤៦ | ៦២ |
| ២ | ចុងស្ពាន | ១២៥ | ១២ |
| ៣ | រវៀង | ១៨៥ | ១៨ |
| **សរុប** | | **៩៥៦** | **៩២** |

### ២.៣.៣.២-ការវិភាគទិន្នន័យ

ក្នុងការវិភាគទិន្នន័យនៃការសិក្សាអំពីស្ថានភាពសង្គមសេដ្ឋកិច្ចនេះ ត្រូវបានប្រើប្រាស់កម្មវិធី SPSS ដើម្បីវិភាគទិន្នន័យ និងប្រើប្រាស់ កម្មវិធី Microsoft Excel 2010 សម្រាប់បកស្រាយទិន្នន័យជាតារាង ដ្យាក្រាម ក្រាហ្វិក ជាដើម។

### ២.៣.៤ វិធីសាស្ត្រចូលរួមជាសាធារណៈ

ការប្រឹក្សាពិគ្រោះយោបល់ជាសាធារណៈចែកចេញជាបីផ្នែកគឺ ប្រឹក្សាយោបល់ជាមួយអាជ្ញាធរថ្នាក់ខេត្ត ប្រឹក្សាយោបល់ជាមួយអាជ្ញាធរថ្នាក់ឃុំ និងប្រឹក្សាយោបល់ជាមួយប្រជាពលរដ្ឋមូលដ្ឋាន។ វិធីសាស្ត្រនៃការសិក្សាទាំងនេះ មានរៀបរាប់ដូចខាងក្រោម៖

ការប្រឹក្សាយោបល់ជាមួយអាជ្ញាធរថ្នាក់ខេត្ត ត្រូវបានរៀបចំឡើង២លើកគឺ លើកទី១ ត្រូវបានធ្វើឡើងដើម្បីស្នើរសុំអាជ្ញាធរខេត្ត សុំចុះសិក្សាវាយតំលៃ តាមវិធីសាស្ត្រដោយធ្វើការប្រជុំ ដោយមានក្រុមហ៊ុនទីប្រឹក្សាធ្វើបទបង្ហាញអំពីការអភិវឌ្ឍន៍គម្រោង និងមានមន្ទីរ និងស្ថាប័នដែលពាក់ព័ន្ធជាច្រើនទៀត ដែលបានចូលរួម។ ចំពោះការប្រជុំលើកទី២ ត្រូវបានធ្វើឡើងនៅពេលក្រុមហ៊ុនទីប្រឹក្សាបានសិក្សា និងរៀបចំរបាយការណ៍ចប់សព្វគ្រប់ ដោយក្រុមហ៊ុនទីប្រឹក្សា ត្រូវធ្វើបទបង្ហាញអំពីលទ្ធផលនៃរបាយការណ៍ដែលបានសិក្សាកន្លងមក ជូនដល់អាជ្ញាធរខេត្ត ស្រុក មន្ទីរ និងស្ថាប័នដែលពាក់ព័ន្ធ។

សមាសភាពអ្នកដែលបានចូលរួម ការប្រជុំពិភាក្សា មានដូចខាងក្រោម៖

១. សាលាខេត្តសៀមរាប

២. អភិបាលស្រុកជីក្រែង

៣. មន្ទីរបរិស្ថានខេត្តសៀមរាប

៤. មន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តសៀមរាប

៥. មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្តសៀមរាប

៦. មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តសៀមរាប

៧. មន្ទីររ៉ែ និងថាមពលខេត្តសៀមរាប

៨. មន្ទីរធនធានទឹក និងឧត្តុនិយមខេត្តសៀមរាប

៩. អាជ្ញាធរអប្សរាខេត្តសៀមរាប

១០. ខណ្ឌរដ្ឋបាលព្រៃឈើខេត្តសៀមរាប

១១. ខណ្ឌរដ្ឋបាលជលផលខេត្តសៀមរាប

ចំណែកអាជ្ញាធរមូលដ្ឋាន ប្រើប្រាស់វិធីសាស្ត្រប្រជុំពិភាក្សា និងពិគ្រោះយល់បល់ នៅសាលាឃុំខ្វាវ ដែលមានការចូលរួមសំណាក់ប្រធានឃុំខ្វាវ និងមេភូមិទាំង៣ ដែលពាក់ព័ន្ធនឹងតំបន់គម្រោង។

សមាសភាពអ្នកដែលចូលរួមការប្រជុំមានដូចខាងក្រោម៖

១. មេឃុំខ្វាវ

២. មេភូមិខ្វាវ

៣.មេភូមិចុងស្ពាន

៤. មេភូមិរវៀង

រីឯប្រជាពលរដ្ឋត្រូវបានប្រើប្រាស់វិធីសាស្ត្រសម្ភាសន៍តាមគេហដ្ឋាន ដោយជ្រើសរើសប្រជាជនតំណាងទាំង ៣ភូមិ ចេញពីភូមិខ្វាវ ចុងស្ពាន និងភូមិរវៀង។ ការពិគ្រោះយោបល់ជាមួយប្រជាជនបានប្រើប្រាស់កម្រងសំនួរដើម្បីសាកសួរ ប្រជាជន ដោយកំណត់យកប្រជាជនតំណាងចេញពីភូមិទាំង ៣ ចំនួន៩២គ្រួសារ។

## ២.៣.៥ វិធីសាស្ត្រក្នុងការសិក្សាដីប៉ះពាល់

ការសិក្សាពីផ្ទៃដីប៉ះពាល់របស់ប្រជាជនពិតជាមានការលំបាកក្នុងការសិក្សា ដោយសារតែតំបន់គម្រោងមិនទាន់បានកំណត់ព្រំនៅលើដីនៅឡើយ ម្យ៉ាងទៀតអាជ្ញាធរថ្នាក់ឃុំបានអាចក្តាប់បាននូវចំនួនប្រជាជនដែលបានចូលតាំងលំនៅដ្ឋាន និងធ្វើស្រែចំការនៅក្នុងតំបន់គម្រោងនេះ។ ក្រុមហ៊ុនបានកំណត់វិធីសាស្ត្រ ដោយធ្វើការសហការជាមួយអាជ្ញាធរ ដោយចុះសិក្សាដីប៉ះពាល់ដល់ទីតាំងជាក់ស្តែង ដោយថតយករូបភាពជាក់ស្តែង កំណត់ចំណុចនិយាម សិក្សាទំហំ និងប្រវត្តិម្ចាស់ដី។

## ២.៣.៦ វិធីសាស្ត្រក្នុងការវិភាគសេដ្ឋកិច្ច និងតំលៃបរិស្ថាន

ការវិភាគប្រសិទ្ធិភាពសេដ្ឋកិច្ចគឺផ្តោតលើកត្តាពីរសំខាន់ៗគឺ ការវិភាគហិរញ្ញវត្ថុ (Financial analysis) និងការវិភាគសេដ្ឋកិច្ច (Economic analysis) នៃគម្រោងវិនិយោគនិមួយៗ។ ការវិភាគសេដ្ឋ

កិច្ចនៃគម្រោងវិនិយោគ គឺស្រដៀងគ្នានឹងការវិភាគហិរញ្ញវត្ថុ ដែលការវិភាគទាំងពីរនេះ ក្នុងគោលបំណងកំណត់អំពីកម្រិតនៃផលចំណេញរបស់គម្រោង។ ប៉ុន្តែ គំនិតសំខាន់នៃផលចំណេញផ្នែកហិរញ្ញវត្ថុរបស់គម្រោងមិនដូចគ្នានឹងផលចំណេញផ្នែកសេដ្ឋកិច្ចរបស់គម្រោងទេ។ ការវិភាគហិរញ្ញវត្ថុ (Financial analysis) របស់គម្រោង គឺធ្វើឡើងដើម្បីប៉ាន់ស្មានផលចំណេញ ដែលទទួលបានពីការប្រតិបត្តិគម្រោងរបស់ក្រុមហ៊ុនវិនិយោគ។ ដោយឡែក ការវិភាគសេដ្ឋកិច្ច (Economic analysis) របស់គម្រោងគឺដើម្បីវាស់វែងផលប៉ះពាល់នានានៃគម្រោងលើសេដ្ឋកិច្ចជាតិ។ គម្រោងមួយដែលអាចដំណើរការទៅបាន គឺត្រូវមាននិរន្តរភាពហិរញ្ញវត្ថុរបស់ខ្លួន ផ្គួបផ្សំនឹងប្រសិទ្ធិភាពផ្នែកសេដ្ឋកិច្ចនៃការប្រតិបត្តិគម្រោង។ ផ្ទុយទៅវិញ ប្រសិនបើគម្រោងនោះពុំមាននិរន្តរភាពហិរញ្ញវត្ថុទេ នោះផលចំណេញផ្នែកសេដ្ឋកិច្ចនៃសង្គមជាតិក៏មិនអាចកើតមានផងដែរ។ ដូចនេះ ការវិភាគហិរញ្ញវត្ថុ( Financial analysis) និងសេដ្ឋកិច្ច (Economic analysis) ប្រៀបបាននឹងកាក់មួយមានមុខពីរ ដែលជួយបំពេញឱ្យគ្នាទៅវិញទៅមក។

បន្ទាប់ពីធ្វើការកំណត់អថេរចំណាយ និងចំណូល ដើម្បីធ្វើការវិភាគផ្នែកហិរញ្ញវត្ថុ និងការវិភាគផ្នែកសេដ្ឋកិច្ចរួចរាល់មក យើងនឹងប្រើប្រាស់វិធីសាស្ត្រវិភាគប្រៀបធៀបផលចំណេញ-ខាត (Cost-Benefit Analysis) ដើម្បីវាស់វែង ថាតើការវិនិយោគរបស់គម្រោងមួយអាចមានប្រសិទ្ធិភាពសេដ្ឋកិច្ចកម្រិតណា។ វិធីសាស្ត្រវិភាគប្រៀបធៀបផលចំណេញ-ខាត (Cost-Benefit Analysis) គឺជាសេដ្ឋម៉ែត្រដ៏សាមញ្ញមួយ ត្រូវបានប្រើប្រាស់ជាញឹកញាប់ ដើម្បីវិភាគលើប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ចនៃគម្រោងអភិវឌ្ឍន៍ ហើយត្រូវបានគេប្រើប្រាស់ដើម្បីធ្វើការសម្រេចចិត្តទៅលើគម្រោងណាមួយ ដើម្បីស្វែងយល់ឱ្យច្បាស់ថាតើគម្រោងវិនិយោគនោះអាចប្រព្រឹត្តិទៅបាន ឬក៏យ៉ាងណាដោយផ្អែកលើផលចំណេញផ្នែកហិរញ្ញវត្ថុ និងសេដ្ឋកិច្ចជាតិដែលអាចទទួលបានពីសកម្មភាពគម្រោង។

នៅក្នុងការសិក្សាហេតុប៉ះពាល់បរិស្ថាន (EIA) នេះ យើងក៏ប្រើប្រាស់វិធីសាស្ត្រវិភាគប្រៀបធៀបផលចំណេញ-ខាតផងដែរ ដើម្បីកំណត់ឱ្យឃើញ ថាតើការវិនិយោគរបស់ ក្រុមហ៊ុនម៉េង ស៊ីន ហុង ហ្វា ផ្តល់ផលចំណេញសេដ្ឋកិច្ច និងជួយលើកកំពស់សេដ្ឋកិច្ចជាតិក្នុងកម្រិតណា។ លើសពីនេះទៀត យើងក៏ប្រើប្រាស់វិធីសាស្ត្រវិភាគរកតម្លៃនៃអត្រាចំណូលវិនិយោគខាងក្នុង (IRR) ដែលជាវិធីសាស្ត្រមួយ បង្ហាញឱ្យយើងឃើញពីអត្រានៃការទទួលបានផលចំណេញមកវិញ ដោយធៀបនឹងអត្រាការប្រាក់ ឬអត្រាអប្បហារ។

ការវិភាគផលចំណេញ-ខាត (CBA) គឺជាផលធៀបនៃផលបូកសរុបនៃតម្លៃចំណេញបច្ចុប្បន្ន (Total Present Value benefit) និងផលបូកសរុបនៃតម្លៃចំណាយបច្ចុប្បន្ន (Total Present Value cost)

ក្នុងរយៈពេល២០ឆ្នាំដូចគ្នា។ បច្ចុប្បន្ន អត្រាការប្រាក់ ឬអត្រាអប្បហារ ប្រែប្រួលពី១០% ទៅ១៥%ក្នុងមួយឆ្នាំ ដោយអាស្រ័យទៅតាមប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍។ ដូចនេះ ការជ្រើសរើសយកអត្រាការប្រាក់ ឬអត្រាអប្បហារ គឺជាចំនុចដ៏សំខាន់ក្នុងការវិភាគផលចំណេញ-ខាត (CBA) របស់គម្រោង ដោយសារតែការប្រែប្រួលនៃតម្លៃបច្ចុប្បន្ន (Present Value) របស់ចំណាយ និងចំណូលនៃការវិនិយោគ គឺអាស្រ័យលើអត្រាអប្បហារ (Discout rate)។

ការគណនាតម្លៃបច្ចុប្បន្ន (Present Value) ត្រូវបានអនុលោមយកតាម អត្រាការប្រាក់ ឬអត្រាអប្បហារ (Discount rate) លើសពីអាត្រាលើទីផ្សារធនាគារពាណិជ្ជកម្មត្រឹម ១០% ក្នុងមួយឆ្នាំ ដោយសន្មត់ថាស្ថិតក្នុងប្រភេទគណនីមានកាលកំណត់។ ការគណនាតម្លៃបច្ចុប្បន្ន (Present Value) គឺផ្អែកលើរូបមន្តដូចខាងក្រោមៈ

$$PV = \frac{FV}{(1+i)^N}$$

PV=តម្លៃបច្ចុប្បន្ន FV=តម្លៃប៉ាន់ស្មាននាពេលអនាគត i=អត្រាការប្រាក់ ឬអត្រាអប្បហារ N=រយៈពេលនៃលំហូរសាច់ប្រាក់របស់គម្រោងគឺ២០ឆ្នាំ។

សន្ទស្សន៍ផលចំណេញ (Benefit/Cost Ratio) គឺ CBA=Total PV Benefit/Total PV Cost ហើយយើងអាចទាញបានសម្មតិកម្មដូចខាងក្រោមៈ

សម្មតិកម្មទី១ៈ ប្រសិនបើ តម្លៃ CBA > ១ នោះមានន័យថាគម្រោងធ្វើអាជីវកម្មរ៉ែទង់ដែង របស់ក្រុមហ៊ុន ម៉េង ស៊ីន ហុង ហ្វា គឺអាចទទួលយកបាន។

សម្មតិកម្មទី២ៈ ប្រសិនបើ តម្លៃ CBA = ០ នោះមានន័យថាគម្រោងធ្វើអាជីវកម្មរ៉ែទង់ដែង របស់ក្រុមហ៊ុន ម៉េង ស៊ីន ហុង ហ្វា គឺគ្រាន់តែបានរួចខ្លួនតែប៉ុណ្ណោះ។

សម្មតិកម្មទី៣ៈ ប្រសិនបើតម្លៃ CBA < ១ នោះមានន័យថាគម្រោងធ្វើអាជីវកម្មរ៉ែទង់ដែង របស់ក្រុមហ៊ុនម៉េង ស៊ីន ហុងហ្វា មិនគួរបើកឱ្យដំណើរការបានទេ ដោយសារការចំណាយរ ច្រើនជាងកំណូល។

## ២.៤ ដ្យាក្រាមសង្ខេបពីវិធីសាស្ត្រសិក្សា



#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

# ជំពូកទី៣៖ ក្របខណ្ឌច្បាប់ដែលពាក់ព័ន្ធ

Draft

# ជំពូកទី៣៖ ក្របខណ្ឌច្បាប់ពាក់ព័ន្ធ

ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងរបាយការណ៍ទាំងឡាយត្រូវចងក្រង នឹងធ្វើឡើងដោយគោរពតាម ក្របខ័ណ្ឌច្បាប់និងអនុក្រឹត្យនានាដែលពាក់ព័ន្ធ ដូចខាងក្រោម៖

## ៣.១ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

ច្បាប់ស្តីអំពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិត្រូវបានអនុម័តដោយរដ្ឋសភាជាតិ ហើយត្រូវបានប្រកាសឲ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស,រកម១២៩៦,៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ច្បាប់នេះមានគោលដៅ៖

- ការពារលើកកម្ពស់គុណភាពបរិស្ថាន និងសុខភាពពលរដ្ឋដោយធ្វើការទប់ស្កាត់កាត់បន្ថយ និងការត្រួតពិនិត្យការបំពុល។
- វាយតំលៃហេតុប៉ះពាល់បរិស្ថាន មុននឹងចេញនូវសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលចំពោះរាល់គម្រោងដែលបានស្នើឡើង។
- ធានាឲ្យមានការអភិរក្ស ការអភិវឌ្ឍន៍ ការគ្រប់គ្រងនិងការប្រើប្រាស់ដោយសមហេតុផលនិងប្រកបដោយនិរន្តរភាពនិងភាពស្ថិតស្ថេរនូវធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា
- លើកទឹកចិត្ត និងផ្តល់លទ្ធភាពឲ្យសាធារណៈជនចូលរួមក្នុងកិច្ចការពារបរិស្ថាននិងការគ្រប់គ្រង ធនធានធម្មជាតិ។
- បង្ក្រាបរាល់អំពើទាំងឡាយដែលធ្វើឲ្យប៉ះពាល់ដល់បរិស្ថាន។

ទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិ ច្បាប់នេះបានតំរូវឲ្យបណ្តាក្រុមហ៊ុនទាំងអស់ត្រូវរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង (IEIA) ឬរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ (EIA)។ ផ្អែកលើច្បាប់នេះបានចែងនៅក្នុងមាត្រាទី៦ និង៧ នៃជំពូកទី៣ ដែលមានសេចក្តីដូចខាងក្រោម៖

**<u>មាត្រា៦៖</u>**

ការវាយតំលៃហេតុប៉ះពាល់បរិស្ថានត្រូវអនុវត្តលើគម្រោង និងសកម្មភាពរបស់ឯកជនឬសាធារណៈ ហើយត្រូវបានត្រួតពិនិត្យនិងវាយតំលៃដោយក្រសួងបរិស្ថានមុននឹងដាក់ជូនរាជរ

ដ្ឋាភិបាលសំរេច។ ការវាយតំលៃនេះត្រូវអនុវត្តផងដែរចំពោះសកម្មភាព ដែលមានស្រាប់និងកំពុងដំណើរការ ហើយដែលពុំទាន់បានវាយតំលៃហេតុប៉ះពាល់បរិស្ថាននៅឡើយ។ ប្រភេទទំហំគម្រោង និងសកម្មភាពដែលបានស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់និងកំពុងដំណើរការទាំងឯកជន និងសាធារណៈដែលត្រូវការវាយតំលៃហេតុប៉ះពាល់បរិស្ថាននេះត្រូវកំណត់ ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន។

**មាត្រា៧៖**

ចំពោះពាក្យស្នើសុំធ្វើគម្រោងវិនិយោគ និងរាល់គម្រោងដែលរដ្ឋស្នើឡើងត្រូវមានការវាយតំលៃហេតុប៉ះពាល់ បរិស្ថានដំបូង (IEIA) ការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ (EIA)ដូចមានចែងក្នុងមាត្រា៦នៃច្បាប់នេះ។ ក្រសួងបរិស្ថានត្រូវត្រួតពិនិត្យនិងផ្តល់យោបល់លើ IEIA ឬ EIA ទៅអង្គភាពមានសមត្ថកិច្ចក្នុងរយៈពេលដូចបានកំណត់ក្នុងច្បាប់ស្តីពីវិនិ យោគនៃព្រះរាជាណាចក្រកម្ពុជា។

## ៣.២ ច្បាប់ស្តីពីអាជីវកម្មរ៉ែ

ច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មរ៉ែដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ខែឧសភាឆ្នាំ២០០១ នាសម័យប្រជុំពេញអង្គលើកទី៦ នីតិកាលទី២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទំរង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០១ នាសម័យប្រជុំពេញអង្គលើកទី៥ នីតិកាលទី១។ មាត្រាសំខាន់ៗនៃច្បាប់នេះមានសេចក្តីដូចខាងក្រោម៖

**មាត្រា១៖**

ច្បាប់នេះមានគោលដៅកំណត់ការគ្រប់គ្រង និងការធ្វើអាជិវកម្មធនធានរ៉ែ ការប្រើប្រាស់អណ្តូងរ៉ែ ព្រមទាំងរាល់ សកម្មភាព ទាំងឡាយដែលទាក់ទងទៅនឹងប្រតិបត្តិការធនធានរ៉ែនៅព្រះរាចជាណាចក្រកម្ពុជា។ លើកលែងតែប្រតិបត្តិការប្រេងកាត និងឧស្ម័នត្រូវស្ថិតនៅក្រោមច្បាប់មួយដោយឡែក។

**មាត្រា២៖**

ធនធានរ៉ែទាំងអស់ដែលឋិតនៅក្នុងដី លើដី ឬក្រោមដីនៃដែនគោក ភ្នំ ខ្ពង់រាប ដែនទឹក ដែនសមុទ្រ កោះ បាតសមុទ្រ ក្រោម បាតសមុទ្រ ក្នុងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជាជាសម្បត្តិរដ្ឋ។

**មាត្រា៣៖**

Draft

ធនធានរ៉ែ គឺជាសារធាតុទាំងឡាយណា ទោះជាក្នុងទម្រង់រឹង រាវ ឧស្ម័ន ដែលកើតឡើងដោយធម្មជាតិតាមដំណើរវិវត្តភូគព្ភសាស្ត្រ ឬជាលទ្ធផលនៃការជីកយកពីក្នុងដី លើដី ក្នុងសមុទ្រ ក្រោមបាតសមុទ្រ មានជាអាទិ៍ត្បូងថ្ម ធ្យូងថ្ម រ៉ែអលោហៈ ទឹកខនិជ ថ្ម ក្រួស ខ្សាច់ ដី ឥដ្ឋ ប្រេងកាត និងឧស្ម័ន។

ប្រតិបត្តិការធនធានរ៉ែ គឺជាការធ្វើសកម្មភាពបុរេសនា ស្វែងរុករក និងអាជីវកម្មធនធានរ៉ែ។

បុរេសនា គឺជាការស្វែងរុករកជំហានដំបូងនៅស្រទាប់ដីលើ ដោយប្រើប្រាស់ឧបករណ៍សាមញ្ញ ហើយមានការប៉ះពាល់បន្តិចបន្តួចដល់ផ្ទៃដី ដើម្បីកំណត់វត្តមានធនធានរ៉ែ ដែលមានតំលៃពាណិជ្ជកម្ម និងអាចជាទិសដៅសម្រាប់ការ ស្នើសុំអាជ្ញាប័ណ្ណស្វែងរុករក និងអាជីវកម្មធនធានរ៉ែ។

ការស្វែងរុករក គឺជាការសិក្សាស្រាវជ្រាវក្នុងបំណងរកឲ្យឃើញ ធ្វើតេស្តសន្នស្សន៍រ៉ែ ដើម្បីកំណត់សក្តានុពល ទំហំគុណភាព បរិមាណ ព្រមទាំងលទ្ធភាពសេដ្ឋកិច្ច អាជីវកម្មតាមរយៈការធ្វើបុរេសនា ការស្រាវជ្រាវភូគព្ភសាស្ត្រ រូបភូគព្ភសាស្ត្រ និងគីមីភូគព្ភសាស្ត្រ ការជីកកកាយ ការខួង ការដឹកជញ្ជូន និងការធ្វើវិភាគដី ដីល្បាប់ ទឹក ថ្ម និងគំរូរ៉ែផ្សេងៗទៀត។

អាជីវកម្មធនធានរ៉ែ គឺជាប្រតិបត្តិការជីកយកធនធានរ៉ែដែលក្នុងនោះធនធានរ៉ែ ត្រូវបានយកចេញពីជម្រករ៉ែធ្វើប្រព្រឹត្តកម្ម ដឹកជញ្ជូន លក់ដូរ ឬការនាំចេញក្នុងគោលបំណងពាណិជ្ជកម្ម។ ដោយឡែកការលក់ដូរ ការនាំចេញការនាំចូលលោហា ធាតុមានតំលៃ ត្បូងថ្មមានតំលៃដែលមិនទាន់ច្នៃនិងកែច្នៃរួចហើយត្រូវស្ថិតនៅក្រោមបញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជាដែលមានជាធរមាន។

**<u>មាត្រា៨៖</u>**

អាជ្ញាប័ណ្ណធនធានរ៉ែ គឺជាលិខិតអនុញ្ញាតដែលផ្តល់នូវសិទ្ធិឲ្យទៅសម្បទានិកដោយស្ថាប័នមានសមត្ថកិច្ចដើម្បីអនុវត្តសកម្មភាពប្រតិបត្តិការធនធានរ៉ែ។

**<u>មាត្រា៩៖</u>**

គ្មានរូបវន្តបុគ្គល ឬនីតិបុគ្គលណាអាចធ្វើការស្វែងរុករក ឬធ្វើអាជីវកម្មធនធានរ៉ែដោយគ្មានអាជ្ញាប័ណ្ណធនធានរ៉ែ ដែលចេញឲ្យដោយស្ថាប័នមានសមត្ថកិច្ចឡើយ លើកលែងតែម្ចាស់កម្មសិទ្ធឬអ្នកកាន់កាប់ស្របច្បាប់លើដី ធ្លីដែលជាឯកជនអាចប្រើប្រាស់ ក្រួស ខ្សាច់ ឬ ដីឥដ្ឋ ដោយមិនចាំបាច់មានអាជ្ញាប័ណ្ណ តែមិនអនុញ្ញាតឲ្យដឹកជញ្ជូនចេញផុតពីព្រំដែនដី ធ្លី ជាកម្មសិទ្ធិ ដើម្បីធ្វើអាជីវកម្មនោះទេ។

ប្រជាពលរដ្ឋខ្មែរអាចធ្វើបុរេសនានៅលើដីរបស់រដ្ឋ ឲ្យតែដីនោះរដ្ឋនោះមិនទាន់ចេញអាជ្ញាប័ណ្ណធនធានរ៉ែទៅបុគ្គលដទៃ។

**<u>មាត្រា៦៖</u>**

រូបវន្តបុគ្គល ឬនីតិបុគ្គលអាចនឹងទទួលអាជ្ញាប័ណ្ណធនធានរ៉ែបានទៅតមការពិនិត្យពិច័យនៅ លើសមត្ថភាពបច្ចេកទេស ហិរញ្ញវត្ថុ និងការចុះបញ្ជីពាណិជ្ជកម្ម។

**<u>មាត្រា៧៖</u>**

មុននឹងចូលទៅក្នុងដីដែលជាកម្មសិទ្ធិឯកជនដើម្បីធ្វើការស្វែងរុករក និងជីកយករ៉ែ សម្បតានិកត្រូវមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយម្ចាស់កម្មសិទ្ធិដីធ្លី ស្តី ពីការមិនជ្រៀតជ្រែង មិនប៉ះពាល់ដល់ទ្រព្យសម្បត្តិ និងការងារព្រមទាំងធ្វើការទូទាត់សងលើការខូចខាតដែលកើតមាននៅលើផ្ទៃដី ដែលបណ្តាលមកពីសកម្មភាព ប្រតិបត្តិការធនធានរ៉ែ។

មុននឹងចូលក្នុងតំបន់ដែលជាកម្មសិទ្ធិរបស់រដ្ឋដែលកំណត់ថា ជាតំបន់ការពារ តំបន់បំរុងទុក ឬតំបន់ហាមឃាត់ដើម្បីស្វែងរុករក និងជីកយករ៉ែ សម្បទានិកត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីស្ថាប័នមានសមត្ថកិច្ច ឬស្ថាប័នអន្តរក្រសួងដែលមានតួនាទីគ្រប់គ្រងលើតំបន់នោះ។

**<u>មាត្រា៨៖</u>**

ការធ្វើបុរេសនា ការស្វែងរុករក និងធ្វើអាជីវកម្មធនធានរ៉ែនៅលើដីជាកម្មសិទ្ធិរដ្ឋដែលបានកំណត់ជាតំបន់វប្បធម៌ទីតាំងប្រវត្តិសាស្ត្រ តំបន់បិតិកភ័ណ្ឌជាតិត្រូវហាមឃាត់។

**<u>មាត្រា៩៖</u>**

មិនអាចចេញអាជ្ញាប័ណ្ណធានធានរ៉ែឲ្យត្រួតគ្នានៅ តំបន់ណាមួយដែលឋិតនៅ ក្រោមការកាន់កាប់របស់សម្បទានិកមួយផ្សេងទៀតរួចទៅហើយដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែដែលបញ្ជាក់ថា សិទ្ធិផ្តាច់មុខរបស់សម្បទានិកមុនពុំមានលក្ខណៈគ្រប់គ្រាន់តាមផ្លូវច្បាប់ឡើយ។

**<u>មាត្រា១០៖</u>**

រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែគ្រប់គ្រង ត្រួតពិនិត្យរាល់ប្រតិបត្តិការធនធានរ៉ែដើម្បីការអនុវត្តន៍បទប្បញ្ញត្តិ និងនីតិវិធីទាំងឡាយនៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែមានប្រសិទ្ធិភាព។

រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែរក្សាទុកសំណុំឯកសារ និងកំណត់ត្រាក្នុងបញ្ជីឯកសារចំពោះរាល់អាជ្ញាប័ណ្ណដែលចេញឲ្យព្រមទាំងឯកសារដែលពាក់ព័ន្ធនឹងអាជ្ញាប័ណ្ណ។

**<u>មាត្រា១១៖</u>**

អាជ្ញាប័ណ្ណធនធានរ៉ែត្រូវបានរៀបចំជាប្រាំមួយប្រភេទ ដើម្បីសម្រួលដល់អ្នកពាក្យសុំក្នុងគោលដៅសម្រួលការគ្រប់គ្រងលើការងារស្វែងរុករក និងធ្វើអាជិវកម្មធនធានរ៉ែ នៅក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យមានប្រសិទ្ធិភាព។

១. **អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ** អាចផ្តល់ឲ្យចំពោះតែប្រជាពលរដ្ឋខ្មែរប៉ុណ្ណោះ ក្នុងគោលបំណងអនុវត្តការងារស្វែងរុករក និងធ្វើអាជីវកម្មធនធានរ៉ែដោយប្រើប្រាស់ឧបករណ៍សម្ភារៈសមញ្ញ ដែលមាននៅក្នុងមូលដ្ឋាន ហើយប្រើប្រាស់កម្លាំងផ្ទាល់ខ្លួន ឬជាលក្ខណៈគ្រួសារដែលមានចំនួនមិនលើសពី ៧(ប្រាំពីរ)នាក់។

សិប្បកម្មធនធានរ៉ែអាចធ្វើការស្វែងរុករកនិងធ្វើអាជីវកម្មធនធានរ៉ែបានចំពោះតែធនធានរ៉ែដែលរកឃើញក្នុងសភាពជាធនធានរ៉ែរាយប៉ាយនៅក្នុងដីល្បាប់ ខ្សាច់ ក្រួស សិលាក្នុងផ្ទៃដីកំណត់មួយមានទំហំមិនលើសពី១ (មួយ) ហិចតា និងជម្រៅមិនហួសពី ៥(ប្រាំ) ម៉ែត្រ។

២. **អាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម** អាចផ្តល់ឲ្យរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានលក្ខណសម្បត្តិ និងសមត្ថភាពគ្រប់គ្រាន់ ក្នុងបំណងអនុវត្តការងារស្វែងរុករក ធ្វើអាជីវកម្មធានធានរ៉ែសំណង់ និងធានធានរ៉ែឧស្សាហកម្មណាមួយបម្រើឲ្យការសាងសង់ ឧស្សាហកម្មគីមី ឧស្សាហកម្មកែច្នៃហើយជីកយកពីអណ្តូងរ៉ែបើក ឬការដ្ឋានវាយថ្ម។

ធនធានរ៉ែសំណង់ និងធនធានរ៉ែឧស្សាហកម្មមានជាអាទិ៍ ខ្សាច់ ក្រួស ថ្ម សំណង់ ឡាតេរីត ដីឥដ្ឋ ដីឥដ្ឋធ្វើស៊ីម៉ង់ត៍ ថ្មសីលផ្ការថ្ម ហ្វូស្វរីត ថ្មកំបោរ ដូឡូមីត ថ្មម៉ាប កៅឡាំ ប៉ាហ្គោឌីត អំបិល ប៉ូតាស ម្នាងសិលា ត្បូងភក់ ត្បូងថ្ម ខ្សាច់ទីតាន ខ្សាច់ស៊ីលីស ឬសមាសធាតុធនធានរ៉ែផ្សេងទៀតដែលប្រើប្រាស់ក្នុងគោលដៅដូចគ្នា។

៣. **អាជ្ញាប័ណ្ណអណ្តូងរ៉ែត្បូងថ្មមានតំលៃ** អាចផ្តល់ដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានលក្ខណសម្បត្តិ និងសមត្ថភាពគ្រប់គ្រាន់ក្នុងបំណងស្វែងរុករក និងធ្វើអាជីវកម្មធនធានរ៉ែត្បូងថ្មមានតំលៃ ពាក់កណ្តាលមានតំលៃ និងថ្មសំអាង។

ត្បូងថ្មមានតំលៃមានជាអាទិ៍ពេជ្រ ត្បូងទទឹម កណ្តៀង មរកត និងរ៉ែត្បូងថ្ម ទាំងឡាយដែលមានគុណភាពប្រហាក់ប្រហែល។

ត្បូងថ្មពាក់កណ្តាលមានតំលៃមានជាអាទិ៍ សៀកកុន អាមេទីស តូប៉ាស និងរ៉ែត្បូងថ្មទាំងឡាយដែលមានគុណភាពប្រហាក់ប្រហែល។

Draft

ថ្មសំអាងគឺ ជាថ្មដែលមានកំរិតថ្លាឆ្លុះទាប ឬមិនថ្លាឆ្លុះត្រូវបានគេយកទៅប្រើប្រាស់ជាគ្រឿងលំអផ្សេងៗមានជាអាទិ៍ កាល់សេដូន អាស្វីត អូប៉ាល់ធម្មតា អាហ្គាត ហ្សេត ម៉ាឡាស៊ីក ឈើថ្ម ថ្មីថ្លើមអណ្ដើក និងថ្មទាំងឡាយដែលមានគុណភាពប្រហាក់ប្រហែល។

៤. **អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ** អាចផ្ដល់ឲ្យចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងគោលបំណងកែច្នៃត្បូងថ្មមានតំលៃ ពាក់កណ្ដាលមានតំលៃ ឬថ្មសំអាង។

៥. **អាជ្ញាប័ណ្ណស្វែងរុករក** អាចផ្ដល់ឲ្យចំពោះរូបវន្តបុគ្គល ឬណីតិបុគ្គលដែលមានលក្ខណសម្បត្តិ និងសមត្ថភាពគ្រប់គ្រាន់ដើម្បីធ្វើការស្វែងរុករក និងសិក្សាអំពីសក្ដានុពលធនធានរ៉ែ។

៥. **អាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ** ត្រូវបានផ្ដល់ឲ្យចំពោះតែសម្បទានិកដែលមានអាជ្ញាប័ណ្ណស្វែងរុករកប៉ុណ្ណោះ ក្នុងគោលបំណងស្វែងរុករក និងជីកយករ៉ែណាដែលមានជម្រករ៉ែមានប្រសិទ្ធិភាពសេដ្ឋកិច្ច ហើយឋិតនៅតែក្នុងរង្វង់ព្រំដែននៃអាជ្ញាប័ណ្ណស្វែងរុករក។

សម្បទានិកស្វែងរុករកត្រូវដាក់ឲ្យពីនិត្យនូវការវិភាគបច្ចេកទេសហិរញ្ញវត្ថុបរិស្ថាន សេដ្ឋកិច្ច និងសង្គមក្នុងគោលបំណងកំណត់លទ្ធភាពសេដ្ឋកិច្ចសង្គមនៃទម្រង់ប្រតិបត្តិការជីកយករ៉ែដើម្បីសុំការយល់ព្រមពីរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ។

បែបបទ និងមាតិការនៃរបាយការណ៍ ការសិក្សាសមិទ្ធិលទ្ធភាពចុងក្រោយ និងឯកសារយោងព្រមទាំងលក្ខខណ្ឌទាំងឡាយនៃការចេញអាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែនឹងមានចែងក្នុងអនុក្រឹត្យ។

Draft

**<u>មាត្រា១២៖</u>**

ក្នុងករណីដែលរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែកំណត់ថា ពាក្យសុំអាជ្ញាប័ណ្ណស្វែងរុករក ឬអាជីវកម្មធនធានរ៉ែជាគំរោងមានទ្រង់ទ្រាយធំ និងមានផលប្រយោជន៍ពិសេសដល់ប្រទេសជាតិ រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែត្រូវធ្វើការចរចាជាមួយអ្នកស្នើសុំ ដើម្បីឈានទៅដល់កិច្ចព្រមព្រៀងវិនិយោគទុនធានធានរ៉ែ ដែលត្រូវបន្ថែមទៅលើអាជ្ញាប័ណ្ណធានធានរ៉ែ។

**<u>មាត្រា១៣៖</u>**

ចំពោះតំបន់ដែលដឹងពីសក្ដានុពលធនធានរ៉ែ ហើយដែលមិនទាន់ចេញអាជ្ញាប័ណ្ណ រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែអាចកំណត់តាមការប្រកាសជាសារធារណៈថាជាតំបន់រក្សាទុកសម្រាប់ដេញថ្លៃដោយរៀបចំឲ្យមានការវាយតំលៃការចរចាជាផ្លូវការដើម្បីចេញអាជ្ញាប័ណ្ណធនធានរ៉ែ

សមស្របមួយ ឬតម្រូវអោយមានការចរចាធ្វើកិច្ចព្រមព្រៀងធនធានរ៉ែបន្ថែមដូចមានចែងក្នុងមាត្រា ១២។

**មាត្រា១៤៖**

ប្រជាពលរដ្ឋខ្មែរអាចដាក់ពាក្យសុំអាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែដោយខ្លួនឯងផ្ទាល់តាមន្ទីរជំនាញរបស់ក្រសួងទទួលបន្ទុកវិស័យនៅតាមបណ្តាខេត្ត ក្រុងដែលតំបន់អាជ្ញាប័ណ្ណនោះស្ថិតនៅ។

**មាត្រា១៥៖**

រូបវន្តបុគ្គល ឬនីតិបុគ្គល ត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណធនធានរ៉ែទាំងឡាយផ្សេងទៀតក្រោមអំណាចនៃច្បាប់នេះទៅរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ។

**មាត្រា១៦៖**

រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរពីការយល់ព្រម ឬការបដិសេធន៍លើការស្នើសុំអាជ្ញាប័ណ្ណធនធានរ៉ែ ក្នុងរយៈពេលយ៉ាងយូរ ៤៥ (សែសិបប្រាំ) ថ្ងៃក្រោយពី ថ្ងៃបានទទួលសំណុំលិខិតស្នើសុំគ្រប់គ្រាន់តាមបែបបទបច្ចេកទេស។

**មាត្រា១៧៖**

លើកលែងតែអាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ សម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែផ្សេងទៀត ក្រោមអំណាចនៃច្បាប់នេះអាចសុំបន្ត កែប្រែ ប្រគល់ជូនវិញ ដាក់បញ្ចាំ ផ្ទេរសិទ្ធិ ឬបន្តជាមរតកបានដោយមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ។

Draft

**មាត្រា១៨៖**

អាជ្ញាប័ណ្ណធនធានរ៉ែក្រោមអំណាចនៃច្បាប់នេះ អាចព្យួរ ឬលុបចោលចំពោះសម្បទានិកណាដែលបំពានច្បាប់នេះនីតិវិធីនៃការព្យួរទុក ការដកហូតអាជ្ញាប័ណ្ណ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១៩៖**

សម្បទានិកដែលបានទទយលអាជ្ញាប័ណ្ណធនធានរ៉ែ ក្រោមអំណាចនៃច្បាប់នេះត្រូវដាក់ជូនរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែពិនិត្យនូវលិខិតស្នើសុំរបាយការណ៍ ផែនការ និងលិខិតជូនដំណឹងតាមវេលាកំណត់ហើយត្រូវរក្សាទុកសៀវភៅកំណត់ត្រានិងឯកសារ។

**មាត្រា២០៖**

ការរក្សារការសំងាត់លើឯកសារ ពត៌មានទាំងឡាយដូចមានចែងក្នុងមាត្រា ១៩នៃច្បាប់នេះត្រូវធ្វើរហូតដល់ចុងបញ្ចប់នៃអាជ្ញាប័ណ្ណធនធានរ៉ែឬរហូតដល់មានការអនុញ្ញាតពី សម្បទានិកឲ្យធ្វើការផ្សព្វផ្សាយជាចំហរលើកលែងតែ:

- ពត៌មានដែលទាក់ទងនឹងបរិស្ថាន និងសង្គមអាចផ្សព្វផ្សាយជាសាធារណៈបានដោយគ្រាន់តែរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែជូនដំណឹងដល់សម្បទានិកនោះប៉ុណ្ណោះ
- ក្រសួងទទួលបន្ទុកវិស័យរ៉ែចងក្រងបោះពុម្ពផ្សាយនូវស្ថិតិដែលស្រង់ចេញពីឯកសារ និងពត៌មានទាំងឡាយរបស់សម្បទានិកឲ្យតែមានការទាក់ទងនឹងការវិភាគផ្នែកធនធានរ៉ែរបស់ជាតិ។

**មាត្រា២១៖**

សម្បទានិក ឬអ្នកចុះ កិច្ចសន្យាបន្តនីមួយៗ ត្រូវទទួលខុសត្រូវលើការដឹកនាំប្រតិបត្តិការស្វែងរុករក និងធ្វើអាជីវកមមកមធនធានរ៉ែ នឹងត្រូវអនុវត្តទៅតាមការកំណត់ដូចខាងក្រោមនេះ៖

១. ដំណើរការប្រតិបត្តិការឲ្យបានត្រឹមត្រូវ និងមានប្រសិទ្ធិភាពតាមលក្ខណៈបច្ចេកទេស និងហិរញ្ញវត្ថុ ដែលនឹងលំអិតក្នុងកម្មវិធីការងារស្វែងរុករក ឬការសិក្សាអំពីសមិទ្ធិលទ្ធភាពអណ្តូងរ៉ែ

២. ការពារបរិស្ថានដូចមានលំអិតក្នុងច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន ផែនការគ្រប់គ្រងបរិស្ថាន ផែនការលុបអណ្តូងរ៉ែនិងការធានាផ្នែកហិរញ្ញវត្ថុ

៣. ធានាការការពារសុខភាព និងសុវត្ថិភាពពលករដែលនឹងលំអិតក្នុងកម្មវិធីផែនការអណ្តូងរ៉ែ រាប់បញ្ចូលទាំងការការពារគ្រោះថ្នាក់ បែបបទរាយការណ៍ស្តីពីគ្រោះថ្នាក់នេះ

៤. ការពារសុវត្ថិភាពដល់សារធារណជននៅក្នុង និងជុំវិញតំបន់អណ្តូងរ៉ែដែលនឹងលំអិតក្នុងផែនការអណ្តូងរ៉ែ

៥. ធ្វើការអប់រំ បណ្តុះបណ្តាល និងផ្តល់ការងារដល់ប្រជាពលរដ្ឋខ្មែរដែលនឹងលំអិតក្នុងកម្មវិធិផ្តល់ការងារអប់រំបណ្តុះបណ្តាល

៦. ប្រើប្រាស់ឲ្យអស់លទ្ធភាពនូវទំនិញ និងសេវាកម្មក្នុងព្រះរាជាណាចក្រកម្ពុជានៅតាមទីកន្លែង និងពេលវេលាសមស្រប។

រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ អាចកំណត់ភាពចាំបាច់បន្ថែមសម្រាប់ការងារខាងលើដោយយោងទៅតាមប្រភេទអាជ្ញាប័ណ្ណធនធានរ៉ែ និងទំហំប្រតិបត្តិការនោះ។



Draft

**មាត្រា២២៖**

ការណែនាំលើបែបបទ ការបង្កើន ការពង្រីកផែនការ និងមាតិកានៃរាល់សំណុំលិខិតចាំបាច់ និងកម្មវិធីការងារ ការធានាផ្នែកហិរញ្ញវត្ថុសម្រាប់អនុវត្តឲ្យបានត្រឹមត្រូវនោះ នឹងមានចែងនៅក្នុងប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ។

**មាត្រា២៣៖**

ក្នុងករណីចាំបាច់នីមួយៗ រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែត្រូវចាត់តាំងមន្ត្រីមានសមត្ថកិច្ចដើម្បីពិនិត្យការអនុវត្តន៍ច្បាប់នេះ។ មន្ត្រីដែលត្រូវបានចាត់តាំងត្រូវ:

១. ទទួលខុសត្រូវចំពោះរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែលើរបៀបរបបគ្រប់គ្រងស្របតាមបទប្បញ្ញត្តិ នៃច្បាប់នេះ

២. រៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីសកម្មភាពជាប្រចាំ លើការងារស្វែងរុករកនិងជីកយករ៉ែតាមឆ្នាំ បន្តបន្ទាប់ ហើយដាក់របាយការណ៍នោះជូនរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ

៣. ប្រមូលផ្តុំពត៌មាន និងរក្សាទុកឯកសារប្រតិបត្តិការស្វែងរុករក ជីកយករ៉ែការដឹកជញ្ជូនប្រព្រឹត្តកម្ម ការរកទីផ្សារ និងការនាំចេញធនធាន និងផលិតផលរ៉ែ

៤. ធ្វើការតាមដាន និងពិនិត្យ ដើម្បី បញ្ជាក់ពីការអនុវត្តន៍បទប្បញ្ញត្តិទាំងអស់នៃច្បាប់នេះ

៥. ត្រួតពិនិត្យការអនុវត្តន៍បទបញ្ជាឲ្យបានត្រឹមត្រូវលើសុខភាពនិងសុវត្ថិភាព របស់ពលករ និងសារធារណជនទូទៅ និងការពារបរិស្ថាន

៦. ទទួលតួនាទីផ្សេងៗទៀតតាមការកំណត់របស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ។

អំណាច និងតួនាទី របស់មន្ត្រីដែលត្រូវបានចាត់តាំងដើម្បីត្រួតពិនិត្យធ្វើអធិការកិច្ច និងរាយការណ៍ពីសកម្មភាពការងារស្វែងរុករក ជីកយករ៉ែ ស្រាវជ្រាវ ការវិភាគពាក់ព័ន្ធនឹងរបៀបរបបគ្រប់គ្រងក្រោមអំណាចនៃច្បាប់នេះនឹងមានចែងនៅក្នុងអនុក្រឹត្យ។

**មាត្រា២៤៖**

តាមការសម្របសម្រួលរបស់ក្រសួងទទួលបន្ទុកវិស័យរ៉ែ សម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែត្រូវសុំ យោបល់ពីក្រសួងពាក់ព័ន្ធ ដើម្បី អនុវត្តប្រតិបត្តិការស្វែងរុករក និងធ្វើអាជីវកម្មធនធានរ៉ែនៅ ក្នុងមូលដ្ឋាន ខេត្ត ក្រុង ស្រុង ខ័ណ្ឌ តាមគោលការណ៍អភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

## មាត្រា២៥៖

សម្បទានិកដែលមានអាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវសងទោម្ចាស់កម្មសិទ្ធិទាំងក្នុង និងក្រៅតំបន់អាជ្ញាប័ណ្ណធនធានរ៉ែ ចំពោះការខូចខាតទាំងឡាយដែលបណ្តាលមកពីប្រតិបត្តិការអាជីវកម្មធនធានរ៉ែរបស់ខ្លួនដោយមិនគិតថាការខូចខាតនោះជាឧបទ្ទវហេតុ ឬជាការដឹងមុន។

ក្នុងករណីការខូចខាតណាដែលបណ្តាលមកពីប្រតិបត្តិការអាជីវកម្មធានធានរ៉ែរបស់សម្បទានិកចាប់ពីពីររូបឡើងទៅ សម្បទានិកទាំងនោះត្រូវរួបគ្នាសងទៅតាមការខូចខាត។

សំណាងទាំងនោះ ត្រូវអនុវត្តត្រូវអនុវត្តដូចខាងក្រោមៈ

- ប្រសិនបើជាតំបន់ប្រតិបត្តិការធនធានរ៉ែដែលមានកំណត់នៅ ក្នុងអាជ្ញាប័ណ្ណធនធានរ៉ែ ប៉ះពាល់ទៅលើដីកម្មសិទ្ធិ ម្ចាស់ដីត្រូវអនុញ្ញាតឲ្យសម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែធ្វើប្រតិបត្តិការធនធានរ៉ែនៅលើដីនោះដោយមានការព្រមព្រៀងគ្នាទៅវិញទៅ មកជាមុន ដែលក្នុងនោះម្ចាស់ដី ត្រូវបានទទួលសំណាងសមរម្យ និងយុត្តិធមិ
- សំណាងនោះត្រូវសងតាមពេលវេលា ឬសងផ្តាច់តែម្តងតាមការព្រមព្រៀងរវាងម្ចាស់ដី និងសម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែ
- ក្នុងករណីម្ចាស់ដី និងសម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែមិនអាចស្រុះស្រួលគ្នាលើសំណាងបានទេនោះ រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែត្រូវសំរួលដោះស្រាយបើមិនបានសំរេចទេ ត្រូវធ្វើសំណើរទៅរាជរដ្ឋាភិបាលដើម្បីបង្កើតគណៈកម្មការចំរុះមួយសម្រាប់ដើស្រាយករណីនេះ
- ក្នុងករណីដែលភាគីទាំងអស់មិនយល់ព្រមតាមដំណោះស្រាយរបស់គណៈកម្មការចំរុះទេនោះ សេចក្តីសំរេចជាំសមត្ថកិច្ចរបស់តុលាការ។

## មាត្រា២៦៖

ក្នុងករណីដែលផ្ទៃដីទាំងមូល ឬចំណែកណាមួយនៃតំបន់ប្រតិបត្តិការធនធានរ៉ែ ដែលមានកំណត់នៅ ក្នុងអាជ្ញាប័ណ្ណធនធានរ៉ែ មិនទាន់បានផ្តល់កម្មសិទ្ធិជូនទៅ បុគ្គលណាម្នាក់ទេនោះ អាជ្ញាធរមានសមត្ថកិច្ចមិនអាចចេញកម្មសិទ្ធិផ្ទៃដី ទាំងមូល ឬចំណែកណាបួយនៃតំបន់ប្រតិបត្តិការធនធានរ៉ែ ដែលមានកំណត់នៅក្នុងអាជ្ញាប័ណ្ណធនធានរ៉ែ ទៅឲ្យបុគ្គលណាម្នាក់បានឡើយលើកលែងតែមានការអនុញ្ញាតពីរាជរដ្ឋាភិបាលតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ។

ប្រសិនបើតំបន់ប្រតិបត្តិការធនធានរ៉ែនោះ មានប្រជាពលរដ្ឋកំពុងរស់នៅមុនកាលបរិច្ឆេតនៃការចេញអាជ្ញាប័ណ្ណ សម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវអនុវត្តសំណាងដូចមានចែងក្នុងមាត្រា ២៥ ដែរ។

**មាត្រា២៧៖**

អ្នកដាក់ពាក្យសុំ ឬសម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវបង់ជូនរដ្ឋនូវថ្លៃចុះបញ្ជី ពាក្យសុំការពន្យារបន្តការផ្ទេរផ្សេងៗ និងឈ្នួលដី ប្រចាំឆ្នាំ។

**មាត្រា២៨៖**

សម្បទានិកដែលទទួលអាជ្ញាប័ណ្ណធនធានរ៉ែទាំងអស់ លើកលែងតែសម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណស្វែងរុករក និងសម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែត្រូវបង់ជូនរដ្ឋនូវសួយលសាលើតំលៃធនធានរ៉ែ ដែលទាញយកបាន។

សម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើត្រូវរក្សាទុកបញ្ជី គណនេយ្យហើយត្រូវផ្តល់ជូនរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែនូវរបាយការណ៍ ឬបញ្ជីដែលទាក់ទងនឹងពត៌មាននេះ។

**មាត្រា២៩៖**

រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែអាចធ្វើសេចក្តីប្រកាសដល់សម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែ ដើម្បីផ្តល់ពត៌មានបន្ថែមពីកិច្ចសន្យាលក់ អង្កេត និងតាមដានត្រួតពិនិត្យរាល់បញ្ជីគណនេយ្យ និងពិគ្រោះជាមួយសម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែដើម្បីកំណត់ថ្លៃផលិតផលរ៉ែ។

**មាត្រា៣០៖**

ត្រូវហាមដាច់ខាតក្នុងការដឹកជញ្ជូនធនធានរ៉ែចេញ ក្នុងករណីដែលធនធានរ៉ែនោះមិនទាន់បានបង់សួយសារ ឬគ្មានលិខិតអនុញ្ញាតជាលាយលក្ខណ៍អក្សរពី រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ។

**មាត្រា៣១៖**

យោងតាមច្បាប់ដែលមានជាធរមាន របបពន្ធអាករពិសេសមួយនឹងត្រូវបានបង្កើតឡើងសម្រាប់អនុវត្តលើផលិតផល និងប្រាក់ចំណូលពីប្រភេទអាជ្ញាប័ណ្ណធនធានរ៉ែទាំង ៦ (ប្រាំមួយ) ដូចមានចែងក្នុងមាត្រា ១១។

**មាត្រា៣២៖**

អត្រាសួយសារលើតំលៃធនធានរ៉ែ នីតិវិធីនៃការបង់សួយសារជូនរដ្ឋ និងការលើកទឹកចិត្តដល់មន្ត្រីមានសមត្ថកិច្ចដែលចែងក្នុងមាត្រា២៣ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង។

ពន្ធអាករ ពន្ធគយ ពន្ធលើចំនែកភាគហ៊ុន ពន្ធប្រាក់ចំណែកផ្ទាល់ខ្លួន សំវិធានធន បែបបទចំណាយ របៀបបង់ពន្ធគោលការណ៍ និងការអនុវត្តន៍គណនេយ្យ និងហិរញ្ញកិច្ច ការកំណត់ការខាតបង់ ការលើកលែងពន្ធ និងការលើកទឹកចិត្តដល់ការវិនិយោគទុនលើវិស័យរ៉ែ ត្រូវអនុវត្តតាមច្បាប់ដែលមានជាធរមាន។

**<u>មាត្រា៣៣៖</u>**

បុគ្គលណាដែលធ្វើប្រតិបត្តិការស្វែងរុករកធនធានរ៉ែ ដោយគ្មានអាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវពិន័យជាប្រាក់ចំនួនពី ៥០០.០០០ (ហាសិបម៉ឺន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល។

ក្នុងករណីមិនរាងចាលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ (មួលាន)រៀល ទៅ ២.០០០.០០០ (ពីរលាន)រៀល ឬផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ខែ ទៅ ១(មួយ)ឆ្នាំ ឬត្រូវផ្តន្ទាទោសទាំងពីរ។

**<u>មាត្រា៣៤៖</u>**

បុគ្គលណាដែលធ្វើប្រតិបត្តិការស្វែងរុករក ល្មើស នឹងមាត្រា ៧ វាក្យខ័ណ្ឌទី ២ ឬមាត្រា ៨នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ៥.០០០.០០០ (ប្រាំ)រៀល ទៅ ១០.០០០.០០០ (ដប់លាន)រៀលឬផ្តន្ទាទោសដាក់ពន្ធនាគារពី ៦(ប្រាំមួយ)ខែទៅ ២(ពីរ)ឆ្នាំ ឬត្រូវផ្តន្ទាទោសទាំងពីរ។

**<u>មាត្រា៣៥៖</u>**

បុគ្គលណាដែលធ្វើប្រតិបត្តិការជីកយករ៉ែ ដោយគ្មានអាជ្ញាប័ណ្ណធនធានរ៉ែ ឬ ល្មើសនឹងមាត្រា ៧ ឬមាត្រា ៨ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនស្មើនឹង ៣ (បី)ដង នៃតំលៃប៉ាន់ស្មាន តាមរយៈពេលដែលផលរ៉ែត្រូវបានជីកយកដោយផ្អែកលើទំហំឧបករណ៍ គ្រឿងចក្រផលិតកម្មប្រើប្រាស់ និងបរិមាណដែលមានក្នុងទីតាំងនោះ ហើយ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន)រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀលក្នុងមួយថ្ងៃដោយគិតចាប់ពីថ្ងៃដែលបុគ្គលនោះប្រព្រឹត្តិខុសរហូតដល់ថ្ងៃដែលសកម្មភាពប្រតិបត្តិការជីកយករ៉ែនោះត្រូវបានបញ្ឈប់ និងផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ដល់ ៥(ប្រាំ) ឆ្នាំ ដោយមិនទាន់គិតដល់សំណាងនៃ ការខូចខាតផ្សេងទៀត។ រីឯឧបករណ៍គ្រឿងចក្រផលិតកម្មផ្សេងៗទៀតត្រូវរឹបអូសជាសម្បត្តិរដ្ឋ។

**<u>មាត្រា៣៦៖</u>**

បុគ្គលណាដែលធ្វើប្រតិបត្តិការជីកយករ៉ែដោយអាជ្ញាប័ណ្ណធនធានរ៉ែអស់សុពលភាព ត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា ៣៥ នៃច្បាប់នេះ។

Draft

**មាត្រា៣៧៖**

សម្បទានិកណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៣០នៃច្បាប់នេះ ត្រូវពិន័យជាប្រាក់ដែលមានចំនួនទ្វេជាពីរនៃតំលៃធនធានរ៉ែដែលបានដឹកចេញ ឬត្រូវដកហូតអាជ្ញាប័ណ្ណធនធានរ៉ែ ឬត្រូវទទួលទោសទាំងពីរ។

**មាត្រា៣៨៖**

សម្បទានិកដែលមិនអនុញ្ញាតឲ្យមន្ត្រីដែលមានសមត្ថកិច្ចចុះត្រួតពិនិត្យដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់នេះ ចូលធ្វើការត្រួតពិនិត្យនៅ ក្នុងការដ្ឋានប្រតិបត្តិការធនធានរ៉ែរបស់ខ្លួន នឹងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ឬត្រូវព្យួរទុកអាជ្ញាប័ណ្ណធនធានរ៉ែ រយៈពេលមិនលើសពី ៦(ប្រាំមួយ) ខែ។

ក្នុងករណីមិនរាងចាល ត្រូវដកហូតអាជ្ញាប័ណ្ណធនធានរ៉ែជាស្ថាពរ។

**មាត្រា៣៩៖**

បុគ្គលណាដែលមិនមែនជាម្ចាស់កម្មសិទ្ធិដី ស្របច្បាប់ ហើយធ្វើឲ្យរាំងស្ទះដល់ប្រតិបត្តិការធនធានរ៉ែរបស់សម្បទានិកដែលមានអាជ្ញាប័ណ្ណធនធានរ៉ែ ត្រឹមត្រូវតាមច្បាប់នោះ នឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ)ថ្ងៃ ដល់ ១ (មួយ) ខែ។

**មាត្រា៤០៖**

មន្ត្រីមានសមត្ថកិច្ចនៃក្រសួងទទួលបន្ទុកវិស័យរ៉ែដែលបានឃុបឃិត ឬប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ ត្រូវទទួលទោសរដ្ឋបាល ដោយពុំទាន់គិតដល់បទល្មើសព្រហ្មទណ្ឌផ្សេងៗទៀត។

**មាត្រា៤១៖**

រូបវន្តបុគ្គល ឬនីតិបុគ្គលណាដែលបានចាប់ផ្តើមស្វែងរុករក ឬធ្វើអាជីវកម្មធនធានរ៉ែ ហើយមានលិខិតអនុញ្ញាជាផ្លូវការមុនពេលច្បាប់នេះចូលជាធរមាន អាចបន្តសកម្មភាពការងារបាន ប៉ុន្តែតម្រូវឲ្យដាក់ពាក្យបំពេញបែបបទសុំអាជ្ញាប័ណ្ណធនធានរ៉ែថ្មី ទៅតាមបញ្ញត្តិនៃច្បាប់នេះយ៉ាងយូរ ៩០ (កៅសិប)ថ្ងៃ។

**មាត្រា៤២៖**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់ចនេះ ត្រូវទុកជានិរាករណ៍។

Draft

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

## ៣.៣ ច្បាប់ស្តីពីព្រៃឈើ

ច្បាប់ស្តីពីព្រៃឈើត្រូវបានអនុម័តដោយរដ្ឋសភាជាតិនិងប្រកាស ឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៨០២/០១៦/៣១អនុម័តនៅថ្ងៃទី៣០ខែកក្កដាឆ្នាំ២០០២។ មាត្រាដែលពាក់ព័ន្ធនឹងការវាយតំលៃហេតុប៉ះពាល់បរិស្ថានៃគម្រោងវិនិយោគនេះមានដូចខាងក្រោម៖

**<u>មាត្រា១</u>៖**

- ច្បាប់នេះកំណត់អំពីក្របខ័ណ្ឌនៃការគ្រប់គ្រងការប្រមូលផលការប្រើប្រាស់ ការធ្វើអាជីវកម្មការអភិវឌ្ឍន៍និងការអភិរក្សព្រៃឈើនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ គោល បំណងនៃច្បាប់នេះគឺធានានូវការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាពដើម្បីផលប្រយោជន៍សង្គម-សេដ្ឋកិច្ចនិងបរិស្ថានរួមទាំងការអភិរក្សជីវៈចំរុះនិងមរតកវប្បធម៌។

**<u>មាត្រា៣</u>៖**

- ការគ្រប់គ្រងព្រៃឈើត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅ នៃក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ។ ការគ្រប់គ្រងព្រៃលិចទឹកស្ថិតនៅក្រោមច្បាប់មួយដោយឡែក។ រដ្ឋផ្តល់សិទ្ធគ្រប់គ្រងតំបន់ការពារធម្មជាតិដល់ក្រសួងបរិស្ថានក្រោមបទបញ្ញាតិទាំងឡាយ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធម្មជាតិចុះថ្ងៃទី 24 ខែវិច្ឆិកា ឆ្នាំ១៩៩៦ ព្រះរាជក្រឹត្យស្តីពីការបង្កើតនិងកំណត់តំបន់ការពារធម្មជាតិចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ1993 និងលិខិតបទដ្ឋានច្បាប់ផ្សេងៗទៀត។
- ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ មានសិទ្ធិសហការធ្វើសកម្មភាពពង្រឹងការអនុវត្តន៍ច្បាប់ចំពោះរាល់បទល្មើសព្រៃឈើដែលកើតមាននៅក្នុងតំបន់ការពារធម្មជាតិ ក្រោមការសំរបសំរួលជាមួយក្រសួងបរិស្ថាន ស្របតាមបទបញ្ញតិ ដូចមានចែងនៅក្នុងជំពូកទី១៤ នៃច្បាប់នេះ។
- សកម្មភាពនេះមិនធ្វើឱ្យប៉ះពាល់ដែលសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ដូចចែងក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឡើយ។

**<u>មាត្រា៤</u>៖**

- ក្នុងការអនុវត្តន៍ច្បាប់នេះ រាល់ការសំរេចរបស់រដ្ឋាភិបាល ដែលមានសក្តានុភាពចំពោះហេតុប៉ះពាល់ធ្ងន់ធ្ងរទៅលើសហគមន៍មូលដ្ឋាន និងលើធនធានព្រៃឈើនៃព្រះរាជាណាចក្រកម្ពុជាត្រូវមានការចូលរួមជាសាធារណៈ។

➢ សកម្មភាពចំបងៗ ដែលពាក់ព័ន្ធមជ្ឈដ្ឋានព្រៃឈើ ដែលអាចបណ្តាលឱ្យមានការប៉ះពាល់អាក្រក់ដល់សង្គម និងបរិស្ថាន ចាំបាច់ត្រូវមានការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងហេតុប៉ះពាល់ សង្គម ដោយផ្អែកលើក្រុមបច្ចេកទេសគ្រប់គ្រងព្រៃឈើកម្ពុជា និងស្របតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។

➢ ឯកសារវាយតំលៃហេតុប៉ះពាល់បរិស្ថាននិងសង្គម ត្រូវផ្តល់ជូនសម្រាប់ការចូលរួមផ្តល់មតិជាសាធារណៈរាល់ការសម្រេចចុងក្រោយលើសកម្មភាពចំបងៗពាក់ព័ន្ធទៅនឹងប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ រាជរដ្ឋាភិបាល ត្រូវពិចារណាលើអនុសាសន៍ចុងក្រោយនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។ ការសំរេចចុងក្រោយ ណាមួយក្រោមមាត្រានេះរាជរដ្ឋាភិបាលអាចជូនដំណឹងជាសាធារណៈ។

**មាត្រា៧៖**

➢ សហគមន៍មូលដ្ឋានដែលប្រកបរបរចំការពនេរចរមានលក្ខណៈប្រពៃណី អាចអនុវត្តលើដីកម្មសិទ្ធិសហគមន៍ជនជាតិភាគតិចដែលបានចុះបញ្ជីការួចហើយជាមួយរដ្ឋ។ ផ្នែករដ្ឋបាលព្រៃឈើនៃមូលដ្ឋាននេះត្រូវផ្តល់ការអនុញ្ញាតិការគ្រប់គ្រង និងការត្រួតពិនិត្យនៃសកម្មភាពនេះ ដែលជាផ្នែកមួយនៃ ផែនការគ្រប់គ្រងព្រៃសហគមន៍នោះ។ ការអនុវត្តន៍ចំការពនេចរ ត្រូវហាមឃាត់ចំពោះព្រៃធម្មជាតិមិនទាន់ប៉ះពាល់ក្នុងដែនព្រៃបំរុងទុកអចិន្ត្រៃយ៍។ ដីព្រៃឈើដែលរៀបចំសម្រាប់ចំការពនេចរ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៣៩៖**

➢ គ្មានរូបវន្តបុគ្គលណាមួយមានសិទ្ធិផ្តល់ការអនុញ្ញតិ ទោះបីដោយផ្ទាល់ក្តី ឬដោយប្រយោលក្តីឲ្យកាន់កាប់ដីក្នុងដែនព្រៃបំរុងទុកអចិន្ត្រៃយ៍ផ្ទុយនឹងបទបញ្ញតិនៃច្បាប់នេះឡើយ។

**មាត្រា៩៤៖**

➢ បុគ្គលណាដែលបានប្រព្រឹត្តបទល្មើសព្រៃឈើ ធ្វើឲ្យប៉ះពាល់ខូចខាតដល់មជ្ឈដ្ឋានព្រៃឈើត្រូវចេញថ្លៃស្តារ ឬជួសជុលការខូចខាតមានលក្ខខណ្ឌដូចដើមឡើងវិញ។

## ៣.៤ ច្បាប់ស្តីពីជលផល

ច្បាប់ស្តីពីជលផល ត្រូវបានអនុម័តដោយរដ្ឋសភាជាតិដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម ០៥០៦/ ០១១ ចុះថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០០៦។

**ប្រការ១៖**

បានចែងថា "ច្បាប់នេះមានគោលបំណងធានានូវការគ្រប់គ្រងជលផល និងធនធានជលផលជំរុញកិច្ចអភិវឌ្ឍន៍វារីវប្បកម្មផលិតកម្ម និងការកែច្នៃលើកស្ទួយជីវភាពរស់នៅរបស់ពលរដ្ឋក្នុងសហគមន៍មូលដ្ឋាន ដើម្បីផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន រួមទាំងការអភិរក្សជីវចម្រុះផង ទាំងមរតកវប្បធម៌ធម្មជាតិផង ប្រកបដោយនិរន្តរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។"

**ប្រការ៣៖**

បានចែងថា "ការគ្រប់គ្រងជលផល ត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ការគ្រប់គ្រង ព្រៃលិចទឹក និងព្រៃកោងកាងដែលពាក់ព័ន្ធនឹងវត្ថុជីវិតធនធាន ជលផលត្រូវស្ថិតនៅក្រោមវិសាលភាពនៃច្បាប់នេះ។

រដ្ឋផ្ដល់សិទ្ធិគ្រប់គ្រងតំបន់ការពារធម្មជាតិដល់ក្រសួងបរិស្ថាន ក្រោមបទបញ្ញតិទាំងឡាយនៃច្បាប់ស្ដីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ និងច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗទៀត។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិសហការធ្វើសកម្មភាពពង្រឹកការអនុវត្តច្បាប់ ចំពោះរាល់បទល្មើសជលផលដែលកើតមានចែងក្នុងជំពូកទី១៤នៃច្បាប់នេះ។ សកម្មភាពនេសាទនេះនឹងមិនធ្វើឲ្យប៉ះ ពាល់ដល់ដែនសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ដូចមានចែងក្នុងច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឡើយ"។

**ប្រការ២២៖**

បានចែងថា "ហាមឃាត់ ការចាក់ចោល ការបោះចោល ការបង្ហូរ ឬការបាចពង្រាយទៅក្នុងដែននេសាទនូវកាកសំណល់រឹង ឬរាវ ឬសារធាតុពុលដែលបានកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនៃព្រះរាជាណាចក្រកម្ពុជា និងអនុសញ្ញា ឬសន្ធិសញ្ញាអន្តរជាតិស្ដីពីការបំពុលបរិស្ថាន ឬការប្រព្រឹត្តិសកម្មភាពដែលធ្វើឲ្យពុល ឬការបង្កគ្រោះថ្នាក់ដល់វារីសត្វ និងវារីរុក្ខជាតិ។"

## ៣.៥ ច្បាប់ភូមិបាល

ច្បាប់ភូមិបាលនេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានអនុម័តនៅថ្ងៃទី២០ ខែកក្កដាឆ្នាំ២០០១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី២។ មាត្រាសំខាន់ៗដែលពាក់ព័ន្ធទៅនឹងគម្រោង គឺមានសេចក្ដី ដូចខាងក្រោម៖

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

**មាត្រា១៖** ច្បាប់នេះមានគោលដៅកំណត់អំពីរបបកម្មសិទ្ធិលើអចលនវត្ថុទាំងឡាយ នៅព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងធានាការពារសិទ្ធិនៃកម្មសិទ្ធិនិងសិទ្ធិផ្សេងៗទៀតលើអចលនវត្ថុស្របតាមបទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣៖** ជនគ្រប់រូបត្រូវគោរពទ្រព្យសម្បត្តិរបស់រដ្ឋ និងកម្មសិទ្ធិឯកជនស្របច្បាប់លើអចលនវត្ថុ។ ការគ្រប់គ្រងផ្នែក រដ្ឋបាលសុរិយោដីលើអចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋនិងការចេញប័ណ្ណកម្មសិទ្ធិលើអចលនវត្ថុទូទាំង ព្រះរាជាណាចក្រកម្ពុជា ជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ បទបញ្ញា និងនីតិវិធី នៃការគ្រប់គ្រងអចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋនឹងត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៧៖** របបកម្មសិទ្ធិលើអចលនវត្ថុមុនឆ្នាំ១៩៧៩ មិនត្រូវបានទទួលស្គាល់។

**មាត្រា៨៖** មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីនៃព្រះរាជាណាចក្រកម្ពុជា។ អ្នកមានឧបនិស្ស័យជាកម្មសិទ្ធិលើដីនៅកម្ពុជាគឺពលរដ្ឋខ្មែរទាំងអស់ សម្ព័ហភាព ដែនដី សាធារណៈ គ្រឹះស្ថានសាធារណៈ សហគមន៍ឬសមាគមកម្ពុជា សហគ្រាសសាធារណៈ និងក្រុមហ៊ុនស៊ីវិល ឬ ពាណិជ្ជកម្មកម្ពុជា និងគ្រប់អង្គការកម្ពុជា ដែលបានទទួលស្គាល់ដោយច្បាប់ថាជានីតិបុគ្គល។ ជនបរទេសដែលបានក្លែងបន្លំប័ណ្ណសញ្ជាតិដើម្បីឲ្យក្លាយជាកម្មសិទ្ធិករលើដីនៅកម្ពុជានឹងត្រូវផ្តន្ទាទោស ដូចចែង ក្នុងមាត្រា២៥១ នៃច្បាប់នេះ។ ទ្រព្យដែលបានមកក្នុងលក្ខខណ្ឌនេះ ត្រូវរឹបអូសយកទុកជាសម្បត្តិរដ្ឋ ដោយរដ្ឋ មិនចេញសំណងឲ្យឡើយ។

**មាត្រា១២៖** រដ្ឋជាកម្មសិទ្ធិករនៃទ្រព្យសម្បត្តិទាំងឡាយក្នុងដែលដីនៃព្រះរាជាណាចក្រកម្ពុជាដែលបានចែងក្នុងមាត្រា ៥៨ នៃ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ និងទ្រព្យនិទាឃាទភាពទាំងអស់ ឬទ្រព្យដែលម្ចាស់ប្រគល់ឲ្យរដ្ឋ ដោយស្ម័គ្រចិត្ត ឬទ្រព្យ ដែលមិនមែនជាកម្មវត្ថុនៃការយកធ្វើជារបស់ឯកជនតាមច្បាប់ ឬមិនមែនជាទ្រព្យ ដែលកំពុងកាន់កាប់ជារបស់ឯកជនស្របតាមបទបញ្ញត្តិនៃជំពូកទី៤ នៃច្បាប់នេះ។

**មាត្រា១៥៖** រាប់ចូលក្នុងសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ៖

- ទ្រព្យទាំងឡាយដែលបង្ហាញនូវការកើតឡើងពីធម្មជាតិដូចជា ព្រៃឈើ ផ្លូវទឹកដែលនាវាឬក្បូន ចេញចូលបានបណ្តែត បឹងធម្មជាតិ ច្រាំងទន្លេដែលនាវាឬក្បូនចេញចូលបានបណ្តែតបាននិងត្រើយសមុទ្រ។
- ទ្រព្យទាំងឡាយដែលជាកម្មវត្ថុ នៃការរៀបចំពិសេស សម្រាប់ប្រយោជន៍ទូទៅ ដូចជាទីឋាន កំពង់ផែ ផ្លូវដែក ស្ថានីយ៍រថភ្លើង និងព្រលានយន្តហោះ។

Draft

- ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឲ្យប្រើជាសាធារណៈតាមស្ថានភាពពីកំណើតឬក្រោយពីបានរៀបចំដូចជា ផ្លូវថ្នល់ ផ្លូវលំ ផ្លូវរទេះ ផ្លូវដើរ សួនច្បារ និងឧទ្យានសាធារណៈ និងដីចំណី។
- ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឲ្យដំណើរការសម្រាប់សេវាសាធារណៈដូចជាសាលារៀនឬអគារសិក្សា សាធារណៈ អគាររដ្ឋបាល មន្ទីរពេទ្យសាធារណៈទាំងឡាយ។
- ទ្រព្យទាំងឡាយដែលបង្កើតជាដែនបំរុងធម្មជាតិការពារដោយច្បាប់
- បេតិកភណ្ឌបុរាណវិទ្យា វប្បធម៌និងប្រវត្តិសាស្ត្រ។
- អចលនវត្ថុជាព្រះរាជទ្រព្យដែលមិនមែនជាទ្រព្យសម្បត្តិឯកជនរបស់ព្រះរាជវង្សានុវង្ស។
- អចលនវត្ថុជាព្រះរាជទ្រព្យត្រូវបានចាត់ចែងដោយព្រះមហាក្សត្រកំពុងគ្រងរាជ។

**មាត្រា១៦៖** ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមិនអាចលក់ដូរបានឡើយហើយកម្មសិទ្ធិនៃទ្រព្យទាំងនោះ មិនអាចកំណត់អាយុកាលបានទេ។ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មិនអាចឋិតនៅក្រោមការកាន់កាប់ដោយ លទ្ធកម្មពិសេសនៃ ជំពូកទី៤ នៃច្បាប់នេះបានទេ។ ប៉ុន្តែទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋអាចជាកម្មវត្ថុនៃការអនុញ្ញាតឲ្យកាន់កាប់ ឬប្រើប្រាស់ជាបណ្តោះអាសន្នមិនទៀង ហើយអាចដកហូតវិញបាន បើមិនបានបំពេញកាតព្វកិច្ចបង់ពន្ធផ្សេងៗ លើកលែងតែបានអនុញ្ញាតតាម ជំពូកទី៣នៃច្បាប់នេះ។ ការអនុញ្ញាតទាំងនេះមិនអាចប្រែក្លាយទៅជាកម្មសិទ្ធិ ឬជាសិទ្ធភណ្ឌិកជាប្រយោជន៍ដល់ អ្នកកាន់កាប់ទ្រព្យទាំងនេះបានឡើយ។ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ នៅពេលបាត់បង់ផលប្រយោជន៍សាធារណៈ អាចត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋតាមរយៈច្បាប់អនុបយោគ។

**មាត្រា១៨៖** ត្រូវទុកជាមោឃៈនិងគ្មានអានុភាព ហើយមិនអាចត្រូវបានធ្វើនិយ័តកម្ម ទោះតាមរូបភាពណាក៏ដោយនូវ៖

- រាល់ការចូលកាន់កាប់ទ្រព្យសម្បត្តិសាធាណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ និងរាល់ការបំប្លែងការកាន់កាប់ ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋទៅជាសិទ្ធិកម្មសិទ្ធិ ទោះបីការកាន់កាប់និងការបំប្លែងនេះ កើតឡើងនៅពេលណាក៏ដោយ ដែលមិនសមស្របតាមលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីដែលបាន កំណត់កន្លងមក។
- រាល់ការបំប្លែងទៅជាសិទ្ធិកម្មសិទ្ធិនៃដីសម្បទាន ទោះជាការបំប្លែងនោះកើតឡើងមុនពេលច្បាប់នេះ ចូលជាធរមាន ក៏ដោយ លើកលែងតែសម្បទានដែលឆ្លើយតបទៅនឹងប្រយោជន៍សង្គម។
- រាល់សម្បទានមិនស្របនឹងបញ្ញត្តិទាំងឡាយនៃជំពូកទី៥។
- រាល់ការចូលកាន់កាប់ទ្រព្យសម្បត្តិ ឯកជនរបស់រដ្ឋ ទោះជាតាមរូបភាពណាក៏ដោយដែលបានកើតឡើងក្រោយច្បាប់នេះចូលជាធរមាន។

**មាត្រា៣០៖** បុគ្គលទាំងឡាយដែលបានអាស្រ័យផលនៃភោគៈដោយសន្តិវិធីនិងមិនមានការជំទាស់ចាប់ពី ៥(ប្រាំ)ឆ្នាំយ៉ាងតិចគិតមកដល់ការបរិច្ឆេទនៃការប្រកាសឲ្យ ប្រើច្បាប់នេះលើអចលនវត្ថុ ដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់ក្នុង ការកាន់កាប់ជាឯកជន មានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិស្ថាពរ។ ក្នុងករណីមានការជំទាស់ដល់ការផ្តល់ប័ណ្ណកម្មសិទ្ធិ ស្ថាពរនេះ អ្នកតវ៉ាត្រូវយកភស្តុតាងមកបញ្ជាក់ថាខ្លួនឯងផ្ទាល់បានបំពេញលក្ខខណ្ឌនៃភោគៈ ដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី៥(ប្រាំ) ឆ្នាំនៅលើអចលនវត្ថុដែលមានទំនាស់ ឬយកភស្តុតាង ដែលថាខ្លួនបានទិញ អចលនវត្ថុនោះពីភាគីដើម ឬពីសិទ្ធិវន្តស្របច្បាប់ឬអ្នកទទួលផ្ទេរកម្មសិទ្ធិពីសន្តតិជនរបស់ខ្លួន។

**មាត្រា៣៣៖** ក្នុងករណីមានការដកហូតអចលនវត្ថុដោយហឹង្សា រឺដោយប្រើអំណាចរំលោភរបស់អាជ្ញាធរ អចលនវត្ថុនោះត្រូវ បានបង្វិលមករដ្ឋវិញហើយមិនអាចជាកម្មវត្ថុនៃការកាន់កាប់ថ្មីបានឡើយ ប្រសិនបើគ្មានបណ្តឹងទាមទារពីភាគី ស្របច្បាប់នៃអចលនវត្ថុ ដែលត្រូវបានដកហូត។បណ្តឹងទាមទារនេះមានរយៈពេល ០៣ ឆ្នាំ ចាប់ពីថ្ងៃដែលរដ្ឋ ប្រកាសដកហូត។

**មាត្រា៣៤៖** អ្នកកាន់កាប់ថ្មីលើអចលនវត្ថុរបស់នីតិបុគ្គលសាធារណៈ ឬរបស់បុគ្គលឯកជនដោយគ្មានប័ណ្ណ ក្រោយច្បាប់នេះចូលជាធរមានត្រូវចាត់ទុកជាអ្នកកាន់កាប់ដោយខុសច្បាប់ហើយត្រូវទទួលទោសដូចមានចែងក្នុងមាត្រា ២៥៩ នៃច្បាប់នេះ។

**មាត្រា៣៥៖** មានតែអាជ្ញាធរមានសមត្ថកិច្ចក្នុងនាមរដ្ឋ និងនីតិបុគ្គលសាធារណៈប៉ុណ្ណោះ ដែលអាចឲ្យអ្នកកាន់កាប់អចលនវត្ថុ គ្មានប័ណ្ណ ឬមានប័ណ្ណមិនគ្រប់គ្រាន់ចាកចេញពីទីតាំងអចលនវត្ថុនោះ។ សាមញ្ញជន ឬ អាជ្ញាធរដែលមិនតាងនាម រដ្ឋ ឬនីតិបុគ្គលសាធារណៈគ្មានសមត្ថកិច្ចដេញអ្នកកាន់កាប់ដោយសន្តិភាព មានប័ណ្ណត្រឹមត្រូវដោយប្រើកម្លាំងបានឡើយ។ ការដេញអាចធ្វើបានតាមការបង្គាប់របស់តុលាការ យោងតាមបណ្តឹងរបស់បុគ្គលដែលបានប្តឹង ទាមទារទ្រព្យ។តុលាការត្រូវពិនិត្យបញ្ជាក់រូបភាព ប្រភព កាលបរិច្ឆេទ និងលក្ខខណ្ឌទាំងឡាយនៃប័ណ្ណដែលបានបង្ហាញ។ តុលាការមិនអាចប្រកែកក្នុងការបង្គាប់ឲ្យចាកចេញ ដើម្បីជាប្រយោជន៍ដល់បុគ្គល ដែលបង្ហាញប័ណ្ណត្រឹមត្រូវ និង ពេញលេញរបស់សុរិយោដីបានឡើយ។

**មាត្រា៣៩៖** ក្នុងការរងចាំដើម្បីឲ្យបានទៅចាកម្មសិទ្ធិពេញលេញ ភោគៈដែលស្របតាមបញ្ញាតិនៃច្បាប់នេះ បង្កើតបានជាសិទ្ធិ ភណ្ឌិកលើអចលនវត្ថុ។ ភោគៈនេះអាចជាកម្មវត្ថុនៃការផ្លាស់ប្តូរផ្ទេរសិទ្ធិ ឬជាកម្មវត្ថុនៃកិច្ចការជំនួយ។

**មាត្រា៤២៖** បុគ្គលទាំងឡាយណាដែលមិនបានចុះបញ្ជីភោគៈស្របច្បាប់របស់ខ្លួនដោយហេតុមិនបានដឹង ឬដោយធ្វេសប្រហែស អ្នកនោះនៅតែមានសិទ្ធិត្រូវបានការពារតាមអំណាចនៃមាត្រា ២៩ មាត្រា៣០ និង មាត្រា ៣១ នៃច្បាប់នេះ។

Draft

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

**មាត្រា៤៨៖** ក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចមិនព្រមចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ អ្នកកាន់កាប់អចលនវត្ថុ នោះអាចធ្វើពាក្យប្តឹងទៅក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់។

**មាត្រា៤៧៖** វិវាទរវាងភោគីចំពោះអចលនវត្ថុមួយ នឹងត្រូវដាក់ឲ្យធ្វើការស៊ើបអង្កេតនិងដោះស្រាយតាមនីតិវិធីកំណត់។ លទ្ធផលនៃការស៊ើបអង្កេតត្រូវដាក់ជូនគណៈកម្មាការសុរិយាដីដែលបង្កើតឡើង នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ គណៈកម្មាការនេះត្រូវធ្វើសេចក្តីសំរេចលើបដិវាទកម្មនោះ។ ក្នុងករណីមិនសុខចិត្ត គូវិវាទអាចប្តឹងទៅតុលាការបាន។ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការនេះដោយអនុក្រឹត្យ។

**មាត្រា៦៦៖** បុគ្គលដែលមានសញ្ជាតិខ្មែរ និងមានសមត្ថភាពចុះកិច្ចសន្យាអាចលក់ ឬទិញទ្រព្យជាអចលនវត្ថុបាន។ បុគ្គលដែលមិនអាចលក់បានគឺ៖

- បុគ្គលដែលមិនមែនជាកម្មសិទ្ធករនៃទ្រព្យដែលត្រូវលក់
- កម្មសិទ្ធករនៃទ្រព្យអវិភាគដោយគ្មានការយល់ព្រមពីកម្មសិទ្ធករអវិភាគផ្សេងទៀត
- បុគ្គលដែលមានអចលនវត្ថុជាកម្មវត្ថុនៃការរឹបអូស។

បុគ្គលដែលមិនអាចទិញបានគឺ ៖

- អាណាព្យាបាលមិនអាចទិញទ្រព្យរបស់បាលិតខ្លួន
- ហិតូបត្ថម្ភក:មិនអាចទិញទ្រព្យដែលខ្លួនគ្រប់គ្រង
- ចៅក្រម ឬភ្នាក់ងាររដ្ឋបាលមិនអាចទិញទ្រព្យដែលយុត្តាធិការរបស់ខ្លួន ឬដែលខ្លួនមានបេសកម្មលក់
- បុគ្គលដែលមានទ្រព្យត្រូវរឹបអូសមិនអាចទិញទ្រព្យនោះវិញបានទេ។

**មាត្រា៨៦៖** កម្មសិទ្ធិករនៃទ្រព្យមិនអាចប្រើប្រាស់ទ្រព្យនោះក្នុងគោលដៅព្យាបាទ រំរំខានដល់តតិយជន និងជាពិសេសដល់ អ្នកជិតខាងរបស់ខ្លួនបានឡើយ។ ការប្រើប្រាស់ទ្រព្យជាធម្មតាដែលមានចរិកធម្មានរូបមិនអាចចាត់ទុកជាការរំខាន ដែលបណ្តាលឲ្យរាំងស្ទះដល់ការប្រើប្រាស់ទ្រព្យនោះបានឡើយ។

**មាត្រា៨៧៖** កម្មសិទ្ធិករនៃដីអាចធ្វើនៅលើដី រាល់ការដាំដុះ ការរៀបចំ និងការសាងសង់តាមបំណង របស់ខ្លួនលើកលែង តែមានច្បាប់ហាមឃាត់។ ការរៀបចំឬការសាងសង់ទាំងនោះជាកម្មសិទ្ធិរបស់ខ្លួនទាំងអស់ ស្របតាមបញ្ញត្តិនៃ ផ្នែកទី៣នៃជំពូកនេះ។

**មាត្រា១១៨៖** បែបបទសំណង់ និងលក្ខខណ្ឌទាំងឡាយនៃការរៀបចំដែនដី និងនគររូបនីយកម្មចំពោះកម្មសិទ្ធិករ នឹងកំណត់ ដោយអនុក្រឹត្យ។

**<u>មាត្រា១៧៥៖</u>** សហកម្មសិទ្ធិ គឺជាកម្មសិទ្ធិលើទ្រព្យជាអចលនវត្ថុរបស់បុគ្គលច្រើននាក់បែងចែកតាមឡូត៍ ដែលម្នាក់ៗបានមួយ ចំណែកជាឯកជនហើយមួយចំណែកទៀតជាផ្នែកនៃទ្រព្យរួម។

**<u>មាត្រា១៧៦៖</u>** សហកម្មសិទ្ធិករទាំងឡាយអាចរៀបចំបទបញ្ជាផ្ទៃក្នុងដែលកំណត់របៀបគ្រប់គ្រង និងវិធានការនៃការថែទាំព្រម ទាំងកាតព្វកិច្ចរបស់សហកម្មសិទ្ធិករ ជាពិសេសចំពោះផ្នែករួម ដោយគោរពតាមបទបញ្ញត្តិទាំងឡាយនៃច្បាប់នេះ។ ក្នុងករណីដែលគ្មានបទបញ្ជាផ្ទៃក្នុងនេះទេ សហកម្មសិទ្ធិត្រូវស្ថិតនៅក្រោមបទបញ្ញត្តិទាំងឡាយដែលបានកំណត់ ពីមាត្រា ១៧៧ ដល់មាត្រា១៨៥ នៃច្បាប់នេះ។

**<u>មាត្រា១៧៩៖</u>** រាល់ចំណែកនៃអាគារឬដីសម្រាប់ការប្រើប្រាស់ ឬជាប្រយោជន៍នៃសហកម្មសិទ្ធិករទាំងឡាយ ឬសហកម្មសិទ្ធិករ ខ្លះក្នុងចំណោមនោះបង្កើតបានជាចំណែករួម។ ទ្រព្យរួមមានជាអាទិ៖

- ដី ទីធ្លា ឧទ្យាន និងសួនច្បារ ផ្លូវ ច្រកចេញចូល
- ជញ្ជាំងសសរទ្រទ្រង់សំខាន់ៗនៃអគារ ឧបករណ៍រួមរាប់បញ្ចូលចំណែកនៃបណ្ដាញទឹកភ្លើង បណ្ដាញ ឧស្ម័នដែលអាច ឆ្លងកាត់ចំណែកឯកជន
- ទូរួម បំពង់ និងក្បាលបំពង់ផ្សេង
- ទីកន្លែងនៃសេវារួម។

សិទ្ធិបន្តបន្ទាប់ខាងក្រោមនេះក៏ត្រូវទុកជាកម្មសិទ្ធិរួមដែរ៖

- សិទ្ធិជីករុករកវត្ថុធាតុដែលមានក្នុងដី
- សិទ្ធិស្ថាបនាអគារថ្មីក្នុងទីធ្លា ឧទ្យានឬសួនច្បារដែលជាចំណែករួម
- សិទ្ធិជីករុករកក្នុងទីធ្លា ឧទ្យានឬសួនច្បារទាំងនេះ
- សិទ្ធិនៃអឡ្លសិទ្ធិភាពដែលជាប់ទៅនឹងចំណែករួមទាំងឡាយ
- សិទ្ធិលើកបន្តឲ្យខ្ពស់នូវអគារសម្រាប់ប្រើប្រាស់រួម ឬដែលមានកន្លែងច្រើន បង្កើតបានជាចំណែកឯកជន ផ្សេងគ្នា។ គ្មានករណីណាមួយដែលកម្មសិទ្ធិករនៃអគារសហកម្មសិទ្ធិជាន់លើបំផុត អាចលើកបន្តសម្រាប់តែខ្លួនឯងផ្ទាល់ ឬលក់សិទ្ធិនៃការលើកនេះឡើយ។
- បទបញ្ញត្តិនេះមានលក្ខណៈជាសណ្ដាប់ធ្នាប់សាធារណៈ។

**<u>មាត្រា១៨៥៖</u>** អាជ្ញាធរមានសមត្ថកិច្ចអាចដាក់វិធានការឲ្យសហកម្មសិទ្ធិករ រ៉ាប់រងការថែទាំឲ្យល្អលើចំណែករួម។ សោហ៊ុយនៃ ការថែទាំជាបន្ទុកនៃសហកម្មសិទ្ធករ ដោយគិតតាមសមាមាត្រទៅនឹងតំលៃនៃចំណែករៀងៗខ្លួន។ សហកម្ម សិទ្ធិករដែលមិនព្រមរួមទទួលបន្ទុកនេះឬ មិនគោរពតាមលក្ខខណ្ឌនៃសណ្ដាប់ធ្នាប់សាធារណៈ ត្រូវទទួលទណ្ឌកម្ម ដូចមានចែងក្នុងមាត្រា ២៥៨ នៃច្បាប់នេះ។

**<u>មាត្រា២៥៨៖</u>** ត្រូវចាត់ទុកជាការប៉ះពាល់កម្មសិទ្ធិ និងសិទ្ធិស្របច្បាប់ផ្សេងៗទៀតលើអចលនវត្ថុជាបទល្មើសព្រហ្មទ័ណ្ឌក្នុងន័យ នៃច្បាប់នេះមាន៖

- រាល់អំពើប្រព្រឹត្តដោយជាក់ស្តែង រំលោភកាន់កាប់អចលនវត្ថុដោយចេតនា ដោយមិនទទួលស្គាល់ប័ណ្ណចេញដោយរដ្ឋបាលសុរិយោដី។
- រាល់អំពើប្រព្រឹត្តដោយជាក់ស្តែង រារាំងអ្នកកាន់កាប់ដោយសន្តិភាពឬភាគីនៃទ្រព្យមួយនៅក្នុងតំបន់ មិនទាន់មាន ប្លង់សុរិយោដី ដែលរបបកម្មសិទ្ធិមិនទាន់បានពង្រឹងជាស្ថាពរតាមបញ្ញត្តិនៃច្បាប់នេះ។
- រាល់ការចូលកាន់កាប់មិនត្រឹមត្រូវតាមច្បាប់ឬមិនប្រក្រតីលើអចលនវត្ថុ ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឬទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដែលមិនស្របតាមមាត្រា ១៧ មាត្រា១៨ និងមាត្រា១៩ នៃច្បាប់នេះ។
- រាល់ការបំប្លែងពីសម្បទានមកជាកម្មសិទ្ធិ លើកលែងសម្បទានឆ្លើយតបទៅនឹងប្រយោជន៍សង្គម។

**<u>មាត្រា២៥៩៖</u>** ការប៉ះពាល់កម្មសិទ្ធិក្នុងន័យនៃមាត្រាខាងលើ អាចជាទង្វើរបស់អាជ្ញាធរមានសមត្ថកិច្ច ឬទង្វើរបស់សមញ្ញជន ដែលធ្វើដោយម្នាក់ឯងឬដោយផ្សំគំនិតជាមួយភ្នាក់ងាររបស់អាជ្ញាធរ។

**<u>មាត្រា២៥០៖</u>** មន្ត្រី ឬអាជ្ញាធរមានសមត្ថកិច្ច ដែលបានធ្វើឲ្យប៉ះពាល់ដល់សិទ្ធិស្របច្បាប់លើអចលនវត្ថុត្រូវទទួលទោសរដ្ឋបាល បន្ថែមលើទោសព្រហ្មទណ្ឌ និងសំណាង់រដ្ឋប្បវេណី។

**<u>មាត្រា២៥១៖</u>** ជនណាដែលបានក្លែងប័ណ្ណក្នុងគោលបំណងយកទៅប្រើប្រាស់ជាផ្លូវការ ទោះជាក្នុងរូបភាពអ្វីក៏ដោយ ត្រូវផ្តន្ទា ទោសដាក់ព័ន្ធនាគារពី ០១ (មួយ) ឆ្នាំ ដល់ ០៥ (ប្រាំ) ឆ្នាំ។

**<u>មាត្រា២៥៣៖</u>** ជនណាដែលប្រើអំពើហឹង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ទោះជាមិនទាន់ធ្វើប័ណ្ណ ឬកំពុងមាន ទំនាស់ក៏ដោយ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ១.៥០០.០០០(មួយលានប្រាំសែន) រៀលដល់ ២៥.០០០.០០០ (ម្ភៃប្រាំលាន)រៀល ឬនិងដាក់ពន្ធនាគាពី ៦ (ប្រាំមួយ)ខែ ដល់២ (ពីរ) ឆ្នាំដោយពុំទាន់គិតបញ្ចូលនូវទោស ប្រព្រឹត្តអំពើហិង្សាប្រឆាំងនិងមនុស្ស។ បន្ថែមលើទោសខាងលើ អ្នកប្រព្រឹត្តអំពើហឹង្សាត្រូវទទួលខុសត្រូវចំពោះ សំណាង់រដ្ឋប្បវេណីដល់ជនរងគ្រោះដែលបណ្តាលមកពីអំពើហិង្សារបស់ខ្លួន។ បើអំពើហិង្សាខាងលើត្រូវបញ្ជាពី ជនដទៃទៀតក្រៅពីអ្នកបង្កហើយជននោះមិនបានចូលរួមផ្ទាល់ក្តី អ្នកបញ្ជានោះក៏ត្រូវទទួលការផ្តន្ទាទោសដូច អ្នកប្រព្រឹត្តអំពើហិង្សាផ្ទាល់ដែរ។

**<u>មាត្រា២៥៨៖</u>** សហកម្មសិទ្ធិករ ដែលមិនព្រមចូលរួមទទួលបន្ទុកថែរទាំចំណែករួម នៃសហកម្មសិទ្ធិខ្លួន ឬ មិនគោរពតាមលក្ខខណ្ឌ នៃសណ្តាប់ធ្នាប់សាធារណៈដូចមានចែងនៅក្នុងមាត្រា១៨៥ នៃ

ច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០០.០០០ (ប្រាំសែន)ដល់ ៣.០០០.០០០ (បីលាន) រៀល។

**មាត្រា២៦១៖** មន្ត្រីឬអាជ្ញាធរដែលបានប្រើអំណាចដោយរំលោភ ទោះមានបញ្ញាត្តិឬគ្មានបញ្ញាត្តិ ដើម្បីដកហូតអចលនវត្ថុពី អ្នកកាន់កាប់ដោយសន្តិភាព ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន)រៀល ដល់ ២៥.០០០.០០០(ម្ភៃប្រាំលាន)រៀល និងត្រូវទទួលទោសរដ្ឋបាលថែមទៀត។ ចាត់ទុកជាការរំលោភ មានការក្លែងបន្លំ ការកសាងប័ណ្ណដោយបំពានការកៀបសង្កត់ ឬវិធានការសម្ពារៈ ដើម្បីបណ្តេញចេញធ្វើឡើង ចំពោះអ្នកកាន់កាប់អចលនវត្ថុ។ បើការដកហូតអចលនវត្ថុបានប្រព្រឹត្តទៅដោយអំពើហិង្សាចារីត្រូវផ្តន្ទាទោស ដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ដល់២ (ពីរ) ឆ្នាំថែមទៀត។ អ្នកបញ្ជាដោយរំលោភត្រូវផ្តន្ទាទោសដូចគ្នានឹង អ្នកប្រព្រឹត្តផ្ទាល់ដែរ។

**មាត្រា២៦៣៖** អាជ្ញាធរមានសមត្ថកិច្ចដែលព្រងើយកន្តើយ ឬបណ្តោយឲ្យសមញ្ញជនប្រព្រឹត្តដោយរំលោភសិទ្ធិរបស់កម្មសិទ្ធិករ របស់ភោគី ឬរបស់អ្នកកាន់កាប់ដោយសន្តិភាពត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០(មួយលាន)រៀលដល់ ១០.០០០.០០០(ដប់លាន)រៀល និងត្រូវទទួលទោសរដ្ឋបាលថែមទៀត។

## ៣.៦ ច្បាប់ការងារ

### ៣.៦.១ ប្រាក់ឈ្នួល

**មាត្រា ១០២៖**

- តាមន័យនៃច្បាប់នេះពាក្យថាប្រាក់ឈ្នួល ទោះបីការកំណត់ ឬរបៀបគិតយ៉ាងណាក៏ដោយមានន័យថា ឈ្នួលការងារ ឬឈ្នួលសេវាដែលអាគិតជាប្រាក់បាន ឬកំរិតបានដោយការព្រមព្រៀងគ្នា ឬដោយច្បាប់ជាតិដែលនិយោជក ត្រូវបើកឲ្យកម្មករនិយោជកតាមកិច្ចសន្យាជួលការងារ ឬសេវាដោយលាយល័ក្ខណ៍អក្សរឬដោយមាត់ទទេ ទោះចំពោះការងារដែលបានធ្វើក្តី ឬដែលត្រូវធ្វើក្តីចំពោះសេវាដែលបានបំពេញ ឬត្រូវបំពេញក្តី។

**មាត្រា ១៦១៖**

- រៀងរាល់ឆ្នាំក្រសួងទទួលបន្ទុកវិស័យការងារ ចេញប្រកាសកំណត់ថ្ងៃបុណ្យដែលត្រូវមានប្រាក់ឈ្នួលសម្រាប់កម្មករនិយោជិកនៃសហគ្រាសទាំងអស់។ ថ្ងៃបុណ្យឈប់សំរាកមានប្រាក់ឈ្នួលទាំងឡាយនេះ មិនផ្តាច់ចិរវេលាធ្វើការដែលត្រូវគិតដើម្បីឲ្យឈប់សំរាកប្រចាំថ្ងៃ ឆ្នាំនោះដែរ។

**មាត្រា ១៦២៖**

- ក្នុងករណីថ្ងៃបុណ្យដែលត្រូវបានឈប់សំរាកចំថ្ងៃអាទិត្យនោះ កម្មករនិយោជិកនឹងត្រូវបានឈប់សម្រាកមួយថ្ងៃ (០១ថ្ងៃ) បន្តទៀត។ ការឈប់សំរាកថ្ងៃបុណ្យមិនមែនជាហេតុនាំបន្ថយប្រាក់ឈ្នួលប្រចាំខែ ប្រចាំអឌ្ឍមាស ឬប្រចាំសប្តាហ៍គឡើយ។

**មាត្រា ១៦៣៖**

- កម្មករនិយោជិកធ្វើការតាមម៉ោងប្រចាំថ្ងៃ ឬតាមបរិមាណផលិតផលត្រូវមានសិទ្ធិ បានប្រាក់បំណាច់ស្មើនឹងប្រាក់ឈ្នួលដែលបង់ខាតមកពីការឈប់បុណ្យ មានចែងក្នុងមាត្រា ១៦១ ខាងលើ។ ប្រាក់បំណាច់ នេះត្រូវនៅក្នុងបន្ទុកនៃនិយោជក។

**មាត្រា ១៦៤៖**

- នៅក្នុងគ្រឹះស្ថានសហគ្រាសណាដែលមិនអាចបញ្ឈប់ការងារបាន ដោយសារសកម្មភាពរបស់ខ្លួនតម្រូវឲ្យកម្មករ និយោជិក ទាំងឡាយដែលជាប់ធ្វើការក្នុងថ្ងៃឈប់បុណ្យ ត្រូវមានសិទ្ធិទទួលក្រៅអំពីប្រាក់ឈ្នួលនៃការងារដែលខ្លួនបានធ្វើនូវប្រាក់បំណាច់ដែលនៅលើបន្ទុកនិយោជកដែរ ហើយដែលកំរិតក្នុងប្រការក្រសួងទទួលបន្ទុកវិស័យការងារ។

Draft

### ៣.៦.២ ការឈប់សំរាកពិសេស

**មាត្រា ១៧១៖**

- និយោជកមានសិទ្ធិអនុញ្ញាត្តិឲ្យកម្មករនិយោជិកខ្លួន ឈប់សំរាកជាពិសេសក្នុងឱកាសមានព្រឹត្តិការណ៍ដែលប៉ះពាល់ផ្ទាល់ដល់គ្រួសារនៃកម្មករនិយោជិក។
- ក្នុងករណីដែលកម្មករនិយោជិកមិនទាន់អនុវត្តការឈប់សំរាកប្រចាំឆ្នាំទាំងអស់របស់ខ្លួនទេ និយជកអាធ្វើការកាត់កងការឈប់សំរាកពិសេសខាងលើ ពីការឈប់សំរាកប្រចាំឆ្នាំរបស់កម្មករនិយោជិកបានទេ។
- ក្នុងករណីដែលកម្មករនិយោជិកបានអនុវត្ត ការឈប់សំរាកប្រចាំឆ្នាំរបស់ខ្លួនរួចអស់ហើយនិយោជកមិនអាចធ្វើការកាត់កងការឈប់សំរាកពិសេសខាងលើពិការឈប់សំរាកប្រចាំឆ្នាំសម្រាប់ឆ្នាំខាងមុខរបស់កម្មករ និងនិយោជិកបានទេ។
- ម៉ោងធ្វើការដែលបង់ក្នុងឪកាសឈប់សំរាកពិសេសនេះ អាចនឹងបំពេញវិញបានតាមល័ក្ខខ័ណ្ឌដូចមានក្នុងកំរិតប្រកាសពីក្រសួងទទួលបន្ទុកក្នុងវិស័យការងារ។

### ៣.៦.៣ អនាម័យ និងសន្តិសុខនៃកម្មករនិយោជិក

**មាត្រា ២៣៨៖**

- សហគ្រាស និងគ្រឹះស្ថានដែលចង្អុលក្នុងមាត្រា១ នៃច្បាប់នេះត្រូវរៀបចំឲ្យមានការព្យាបាលបឋមសម្រាប់កម្មករនិយោជិករបស់ខ្លួន។

**មាត្រា ២៤០៖**

- ក្រុមពេទ្យការងារអាចមានជាពិសេសសម្រាប់សហគ្រាសនិយមៗ ឬមានក្រុមពេទ្យការងារមួយសម្រាប់សហគ្រាសច្រើនប្រើប្រាស់រួមគ្នាសារៈសំខាន់នៃសហគ្រាស។
- គិលានុប្បដ្ឋាននេះត្រូវមានគ្រូពេទ្យកាន់កាប់ផ្ទាល់ ដោយមានគិលានុប្បដ្ឋាក ឬគិលានុប្បដ្ឋាកយិកាម្នាក់ ឬច្រើននាក់ជួយធ្វើការផងគិតតៅតាមចំនួនកម្មករនិយោជិក។
- ក្នុងម៉ោងធ្វើការ ទាំងថ្ងៃទាំងយប់ ត្រូវមានគិលានុប្បដ្ឋាក ឬគិលានុប្បដ្ឋាកយិកាយ៉ាងតិចម្នាក់នៅយាមប្រចាំការជាអចិន្ត្រៃយ៍។

**មាត្រា ២៤៣៖**

- កាលណាដែលសហគ្រាសដែលចង្អុលក្នុងមាត្រា២២៨ មានសាខា ឬការដ្ឋានមួយ ឬច្រើនដែលមានប្រើកម្មករនិយោជិកយ៉ាងតិចហាសិប (៥០នាក់) ហើយស្ថិតនៅចម្ងាយលើសពីប្រាំ (០៥) គីឡូម៉ែត្រពីការដ្ឋានធំ និយោជកត្រូវតែផ្តល់ចំពោះសាខា ឬការដ្ឋានទាំងនោះឲ្យដូចចំពោះការដ្ឋានធំដែរនូវមធ្យោបាយសង្គ្រោះ និងព្យាបាលកម្មករនិយោជិកខ្លួនឲ្យបានសព្វគ្រប់ដូចជា បុគ្គលិកពេទ្យសំណាង់ សំភារៈវត្ថុរបួស និងថ្នាំព្យាបាល។

**មាត្រា ២៤៤៖**

- ក្រៅពីវិធានការណ៍ដែលចែងក្នុងកាត្រាខាងលើនិយោជក ត្រូវចាត់ចែងដោយចេញសោហ៊ុយខ្លួននូវ
  - ១- ក្រុមគីមីបង្ការរោគ នៅក្នុងការដ្ឋានខ្លួន
  - ២- ការចាក់ថ្នាំការពារជំងឺទាំងឡាយ។
- ក្នុងពេលមានជម្ងឺឆ្លង ក្រសួងសុខាភិបាលអាចតម្រូវឲ្យមានចាត់វិធានការការពារជាពិសេស នៅក្នុងការដ្ឋានទាំងអស់។

Draft

### ៣.៧ ច្បាប់ស្តីពីការវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា១៖** ច្បាប់នេះមានវិសាលភាពគ្របដណ្តប់លើការវិនិយោគនានា ដែលអនុវត្តនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដោយអ្នកវិនិយោគជាជនជាតិខ្មែរនិង /ឬជនបរទេស។

**មាត្រា២៖** អ្នកវិនិយោគទាំងអស់ត្រូវស្ថិតនៅក្រោមច្បាប់នេះ ហើយអាចជារូបវន្តបុគ្គលឬជានីតិបុគ្គល។

**មាត្រា៣៖** ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាអង្គការមានសមត្ថកិច្ច និងជាច្រកចេញចូលតែមួយគត់ក្នុងការទទួលបន្ទុកការងារនីតិសម្បទា អភិវឌ្ឍន៍និងការវិនិយោគ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការពិនិត្យនិងសំរេចការងារនីតិសម្បទាននិងអភិវឌ្ឍន៍ និងការវិនិយោគនានា។

**មាត្រា៤៖** ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានគណៈកម្មាធិការពីរសម្រាប់ជំនួយការគឺ៖

១.គណៈកម្មាធិការនីតិសម្បទា និង អភិវឌ្ឍន៍

២.គណៈកម្មាធិការវិនិយោគកម្ពុជា។

**មាត្រា៥៖** ការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវកំណត់ដោយអនុក្រិត្យ។

**មាត្រា៦៖** អ្នកវិនិយោគត្រូវដាក់ពាក្យសុំនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដើម្បីពិនិត្យ និងសំរេច។

**មាត្រា៧៖** ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវឆ្លើយតបអំពីការសំរេចរបស់ខ្លួនទៅអ្នកវិនិយោគ ក្នុងរយៈពេល៤៥ថ្ងៃយ៉ាងយូរ គិតពីថ្ងៃទទួលពាក្យសុំដែលបានបំពេញបែបបទត្រឹមត្រូវនិងគ្រប់គ្រាន់។ បើគ្មានមូលហេតុត្រឹមត្រូវ មន្ត្រីរាជការណាដែលប្រកែកមិនព្រមពិនិត្យនិងឆ្លើយតបអំពីការសំរេចរបស់ខ្លួនទៅអ្នកវិនិយោគវិញ ហួសកាលកំណត់ខាងលើ ត្រូវផ្តន្ទាទោសតាមបញ្ញត្តិច្បាប់។

**មាត្រា៨៖** អ្នកវិនិយោគត្រូវបានទទួលស្គាល់និងចាត់ទុកដោយស្មើភាពគ្នាចំពោះមុខច្បាប់ គ្មានការរើសអើងអំពីសញ្ជាតិឬពូជសាសន៍ទេ លើកលែងតែចំពោះកម្មសិទ្ធិលើដីធ្លី ដូចដែលមានចែងក្នុងបទបញ្ញត្តិនៃ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៩៖** រាជរដ្ឋាភិបាលនិងមិនធ្វើជាតូបនីយកម្ម ដែលនាំឲ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់អ្នកវិនិយោគក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ។

**មាត្រា១០៖** រាជរដ្ឋាភិបាលមិនត្រួតពិនិត្យលើថ្លៃផលិតផលឬថ្លៃសេវានានារបស់អ្នកវិនិយោគដែលបានទទួលការអនុញ្ញាតរួចហើយនោះឡើយ។

**មាត្រា១១៖** ដោយអនុលោមទៅតាមច្បាប់ទាំងឡាយដែលពាក់ព័ន្ធ ព្រមទាំងបទបញ្ញត្តិទាំងឡាយដែលបានកំណត់និងប្រកាសផ្សាយដោយធនាគារជាតិកម្ពុជា រាជរដ្ឋាភិបាលអនុញ្ញាតដល់អ្នកវិយោគ មានសិទ្ធិទិញរូបិយប័ណ្ណបរទេសតាមរយៈប្រព័ន្ធធនាគារ សម្រាប់បង្វិលទៅបរទេសវិញ ដើម្បីទូទាត់កាតព្វកិច្ចខាងហិរញ្ញវត្ថុដែលពាក់ព័ន្ធនិងការវិនិយោគរបស់ខ្លួន។
ការទូទាត់ខាងលើនេះរួមមាន៖

Draft

១.ការទូទាត់ខាងការនាំចូលការបង្វិលទៅក្រៅប្រទេសទាំងដើមទាំងការនូវប្រាក់ចងការ។

២.ការទូទាត់ចំនាយសួយសារនិងថ្លៃសេវាគ្រប់គ្រង។

៣. ការផ្ទេរប្រាក់ចំណេញ។

៤. ការបង្វិលដើមទុនវិនិយោគទៅក្រៅប្រទេសវិញ ដូចមានចែងក្នុងជំពូកទី៨។

**<u>មាត្រា១២៖</u>** រាជរដ្ឋាភិបាលលើកទឹកចិត្ត ដើម្បីជំរុញការវិនិយោគលើវិស័យសំខាន់ៗដូចតទៅ៖

១. ឧស្សាហកម្មនាំមុខ ឬ ឧស្សាហកម្មដែលមានបច្ចេកវិទ្យាខ្ពស់

២. ការបង្កើតការងារ

៣. ការបង្កើនការនាំចេញ

៤. ឧស្សាហកម្មទេសចរណ៍

៥. ការផលិតទំនិញកសិ-ឧស្សាហកម្ម និងឧស្សាហកម្មកែច្នៃ

៦. ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការផលិតថាមពល

៧. អភិវឌ្ឍន៍ខេត្ត និងជនបទ

៨. ការការពារបរិដ្ឋាន

៩. ការវិនិយោគក្នុងតំបន់អភិវឌ្ឍន៍ពិសេស ដែលនឹងត្រូវបង្កើតឡើងដោយច្បាប់។

**<u>មាត្រា១៣៖</u>** ការលើកទឹកចិត្តមាន ការលើកលែងទាំងស្រុង ឬមួយផ្នែកនៃពន្ធគយនិងពន្ធអាករ។

**<u>មាត្រា១៤៖</u>** ការលើកទឹកចិត្តទាំងឡាយ រួមមានដូចខាងក្រោមនេះ៖

១. អត្រាពន្ធលើប្រាក់ចំណេញសុទ្ធ៩% លើកលែងតែអត្រាពន្ធផ្សេងៗលើការរុករក និងអាជីវកម្មធនធានធម្មជាតិ ព្រៃឈើ ប្រេងកាត រ៉ែ មាស ត្បូងថ្មមានតំលៃ។ល។ ដែលត្រូវចែងក្នុងច្បាប់ដោយឡែក។

២. ពន្ធលើប្រាក់ចំណេញអាចលើកលែងបានរហូតដល់រយៈពេល ៨ឆ្នាំ គឺអាស្រ័យលក្ខណៈសម្បត្តិរបស់វិនិយោគនីមួយៗនិងអាទិភាព ដែលរាជរដ្ឋាភិបាលនិងកំណត់ដោយអនុក្រឹត្យ។ ការលើកលែងពន្ធលើប្រាក់ចំណេញនឹងត្រូវអនុវត្តចាប់ពីឆ្នាំដែលទទួលបានប្រាក់ចំណេញលើកទីមួយ។ ការខាតបង់រយៈពេល៥ឆ្នាំបន្តបន្ទាប់ ត្រូវបានអនុញ្ញាតឲ្យយកមកទូទាត់គិតប្រាក់ចំណេញ។ ក្នុងករណីយកប្រាក់ចំណេញមកធ្វើវិនិយោគបន្ត ប្រាក់ចំណេញត្រូវបានអនុញ្ញាតឲ្យរួចពន្ធទាំងស្រុង។

៣. មិនយកអាករលើការបែងចែកប្រាក់ចំណេញនៃការវិនិយោគ នទជាប្រាក់ទាំងនោះត្រូវផ្ទេរទៅបរទេសក្តី ឬបែងចែកក្នុងប្រទេសក្តី។

៤. ការលើកលែងពន្ធគយ និងពន្ធអាករ ១០០% ក្នុងការនាំចូលសម្ភារៈសំណង់មធ្យោបាយផលិតកម្ម គ្រឿងសម្ភារៈបរិក្ខារ ទំនិញពាក់កណ្តាលសំរេច វត្ថុធាតុដើម និងគ្រឿងបន្លាស់សម្រាប់ប្រើប្រាស់ ត្រូវមានលក្ខខ័ណ្ឌណាមួយដូចតទៅ៖

ក. ការវិនិយោគដែលមានទិសដៅសម្រាប់បំរើឲ្យការនាំចេញ ក្នុងកំរិតអប្បបរមា ៨០% នៃផលិតផលសរុប។

ខ. មានទីតាំងនៅក្នុងតំបន់អភិវឌ្ឍន៍ពិសេស ដែលមានក្នុងបញ្ជីអាទិភាពសម្រាប់អភិវឌ្ឍន៍ប្រកាសដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

គ. ឧស្សាហកម្មទេសចរណ៍

ឃ. ឧស្សាហកម្មប្រើប្រាស់កម្លាំងពលកម្មច្រើន ឧស្សាហកម្មកែច្នៃ កសិ-ឧស្សាហកម្ម។

ង. ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងការផលិតថាមពល។

ការលើកលែងពន្ធគយ និងពន្ធអាករ ១០០% ខាងលើនេះ ត្រូវអនុវត្តជារៀងរហូតស្របតាមរយៈពេលដែលកំណត់ក្នុងកិច្ចសន្យា ឬ សៀវភៅបន្ទុក សម្រាប់ការវិនិយោគដែលផលិតផលទំនិញនាំចេញក្នុងកំរិតអប្បបរមា ៨០% នៃផលិតកម្មសរុប ដូចមានចែងក្នុងចំណុច (៤)ក ខាងលើ និងសម្រាប់ការវិនិយោគដែលមានទីតាំងក្នុងតំបន់អភិវឌ្ឍន៍ពិសេស ដូចមានចែងក្នុងចំណុច (៤)ខ។

ក្រៅពីប្រភេទការវិនិយោគដែលមានចែងក្នុងចំណុច (៤)ក និង (៤)ខ ខាងលើនេះ ការលើកលែងពន្ធគយ និងពន្ធអាករ ១០០% ត្រូវបានអនុញ្ញាតិឲ្យសម្រាប់តែក្នុងរយៈពេលនៃការរៀបចំកសាងសហគ្រាស រោងចក្រ អាគារនិងការចាប់ដំណើរការអាជីវកម្ម ផលិតកម្មនៅឆ្នាំដំបូងប៉ុណ្ណោះ។

៥. ការលើកលែងពន្ធគយ ១០០% ក្នុងការនាំចេញផលិតផលទៅក្រៅប្រទេស។

៦. ការអនុញ្ញាតឲ្យយកចូលមកក្នុងព្រះរាជាណាចក្រកម្ពុជានូវជនបរទេសណាដែលជា៖

- បុគ្គលិក និង អ្នកជំនាញការខាងគ្រប់គ្រង
- បុគ្គលិកបច្ចេកទេស
- កម្មករជំនាញ
- សហព័ទ្ធនិងអ្នកក្នុងបន្ទុករបស់ខ្លួន ដែលអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាហើយស្របទៅ តាមច្បាប់អន្តោប្រវេសន៍និងច្បាប់ការងារ។

**<u>មាត្រា១៥៖</u>** ការអនុញ្ញាតនិងការលើកទឹកចិត្តដែលបានផ្តល់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមិនអាចផ្ទេរឬលក់បានឡើយ។

**<u>មាត្រា១៦៖</u>** អនុលោមតាមរដ្ឋធម្មនុញ្ញ ច្បាប់និងបទបញ្ញត្តិទាំងឡាយ ដែលពាក់ព័ន្ធទៅ និងកម្មសិទ្ធិ និងការប្រើប្រាស់ដីធ្លី៖

១. កម្មសិទ្ធិដីធ្លីសម្រាប់បំរោះឲ្យគោលដៅនៃសម្មភាពវិនិយោគ ត្រូវបានប្រគល់ជូនចំពោះអ្នកវិនិយោគដែលជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ញាតិជាខ្មែរ។ នីតិបុគ្គលមាន

សញ្ជាតិជាខ្មែរ គិជានីតិបុគ្គលដែលភាគហ៊ុនចាប់តាំងពី ៥១% ឡើងទៅ នៃដើមទុនសរុបជាកម្មសិទ្ធិនៃរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរ។

២. អ្នកវិនិយោគអាចប្រើប្រាស់ដី ធ្លីតាមរយៈ ការជួលសម្រាប់រយៈពេលវែងរហូតដល់ ៧០ឆ្នាំ ហើយអាចស្នើសុំជួលបន្ត។ ការប្រើប្រាស់ដី ធ្លីនេះ រាប់បញ្ចូលទាំងសិទ្ធិនៃកម្មទាំងឡាយនៅ លើផ្ទៃដីនោះ ត្រូវអនុវត្តស្របតាមច្បាប់។

**មាត្រា១៧៖** អ្នកវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិធ្វើការជ្រើសរើស និងជួលនិយោជិតខ្មែរ និងបរទេសបានដោយសេរី ផ្អែកលើមូលដ្ឋាននៃច្បាប់ការងារ និងច្បាប់អន្តោប្រវេសន៍។

**មាត្រា១៨៖** អ្នកវិនិយោគត្រូវបានអនុញ្ញាតឲ្យជួលនិយោជិតបរទេស ដូចមានចែងក្នុងមាត្រា១៤ (៦) ក្នុងលក្ខខ័ណ្ឌដូចតទៅ៖

១. គុណភាព សមត្ថភាព និងជំនាញមិនអាចរកបាននៅ ព្រះរាជាណាចក្រកម្ពុជាក្នុងចំណោមប្រជាំពលរដ្ឋខ្មែរ។ បើមានការជួលនិយោជិតប្រភេទនេះ ត្រូវភ្ជាប់មកជាមួយនូវសេចក្ដីចម្លងលិខិតឆ្លងដែន សញ្ញាប័ត្រ និងប្រវត្តិរូបសង្ខេបរបស់និយោជិតនោះ។

២.អ្នកវិនិយោគមានកាតព្វកិច្ចធ្វើការបណ្ដុះបណ្ដាលជាប្រចាំ និងសមស្របជូននិយោជិតខ្មែរ។

៣. ការជំរុញលើកកំពស់ដល់និយោជិតខ្មែរ ដើម្បីអាចក្លាយទៅជាអ្នកមានឋានៈខ្ពស់ត្រូវធ្វើជាប្រចាំ។

**មាត្រា១៩៖** និយោជិតបរទេស ត្រូវបានអនុញ្ញាតអោយផ្ទេរទៅក្រៅប្រទេសនូវប្រាក់បៀវត្ស ដែលទទួលបាននៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈប្រព័ន្ធធនាគារ ក្រោយពីបង់ពន្ធរួចហើយ។

**មាត្រា២០៖** វិវាទដែលទាក់ទងទៅនិងកិច្ចការវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជារបស់អ្នកវិនិ-យោគ ដែលពាក់ព័ន្ធទៅនិងសិទ្ធ និងកាតព្វកិច្ចដែលមានចែងក្នុងច្បាប់នេះអាច៖

១. ដោះស្រាយសម្រុះសម្រួលតាមរយៈការពិគ្រោះគ្នារវាងភាគីជំលោះទាំងឡាយ។

២. ក្នុងអំឡុងពេលពីរខែ បើវិវាទមិនបានដោះស្រាយតាមការសម្រុះសម្រួលគ្នាទេវិវាទនេះអាច

- លើកយកមកដាក់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាផ្ដល់យោបល់
- ដោះស្រាយតាមផ្លូវតុលាការនៃព្រះរាជាណាកច្រកម្ពុជា
- ឬដោះស្រាយតាមនីតិវិធីអន្តរជាតិណាមួយ តាមការព្រមព្រៀងនៃភាគី។

**មាត្រា២១៖** ក្នុងករណីអ្នកវិនិយោគមានបំណងចង់បញ្ចប់សកម្មភាពរបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា អ្នកវិនិយោគនោះ ត្រូវជូនពត៌មានទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាតាមរយៈលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃ ដោយមានបញ្ជាក់ថាបានទទួលត្រឹមត្រូវ។ លិខិតខាងលើនេះ ត្រូវ

ចុះហត្ថលេខាដោយអ្នកវិនិយោគឬអ្នកតំណាងសិទ្ធិរបស់ក្រុមហ៊ុនហើយត្រូវបញ្ជាក់អំពីមូលហេតុនៃការបញ្ចប់សកម្មភាពនោះផង។

**មាត្រា២២៖** ក្នុងករណីដែលមានការសុំរំលាយក្រៅផ្លូវតុលាការ អ្នកវិនិយោគត្រូវជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នូវលិខិតបញ្ជាក់ពីម្ចាស់បំណុល ពីអ្នកប្តឹងរបស់ខ្លួន និងពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ថាបញ្ហាទាំងឡាយត្រូវបានដោះស្រាយចប់ជាស្ថាពរហើយ ទើបអ្នកវិនិយោគនោះអាចត្រូវបានអនុញ្ញាតអោយរំលាយក្រុមហ៊ុន ឬ សហគ្រាសរបស់ខ្លួនជាផ្លូវការបាន តាមបែបបទនៃច្បាប់ពាណិជ្ជកម្ម។

**មាត្រា២៣៖** ក្នុងករណីដែលអ្នកវិនិយោគត្រូវបានអនុញ្ញាតអោយរំលាយក្រុមហ៊ុន ឬសហគ្រាសរបស់ខ្លួនជាផ្លូវការ ទោះតាមផ្លូវតុលាការក្តី ឬក្រៅផ្លូវតុលាការក្តី អ្នកវិនិយោគអាចផ្ទេរនូវទ្រព្យសម្បត្តិដែលសេសសល់ទៅក្រៅប្រទេស ឬមួយប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ចំពោះគ្រឿងម៉ាស៊ីន និងសម្ភារៈបរិក្ខារដែលបានការអនុញ្ញាតអោយនាំចូលដោយរួចពន្ធហើយបានប្រើប្រាស់ក្នុងអំឡុងពេលតិចជាងប្រាំឆ្នាំ (៥ឆ្នាំ) អ្នកវិនិយោគត្រូវបង់ពន្ធតាមច្បាប់ជាធរមាន។

**មាត្រា២៤៖** ការវិនិយោគទាំងឡាយ ដែលបានទទួលការអនុញ្ញាត ក្រោមច្បាប់ស្តីពីការវិនិយោគនៅរដ្ឋកម្ពុជា និងអនុក្រិត្យស្តីពីការវិនិយោគរបស់បរទេសនៅ រដ្ឋកម្ពុជា ត្រូវបានទទួលផលប្រយោជន៍ និងកាតព្វកិច្ចដូចមានចែងក្នុងច្បាប់នេះដែរ ប៉ុន្តែច្បាប់នេះពុំមានអានុភាពប្រតិសកម្មទេ។

**មាត្រា២៥៖** ក្នុងករណីដែលអ្នកវិនិយោគរំលោភ ឬមិនអនុញ្ញាតតាមលក្ខខ័ណ្ឌទាំងឡាយដែលបានកំណត់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមានសិទ្ធិអំណាចដកហូតសិទ្ធិផ្សេងៗនិងផលប្រយោជន៍ទាំងអស់ ឬមួយផ្នែកដែលបានជូនអ្នកវិនិយោគកន្លងមក។

**មាត្រា២៦៖** ច្បាប់នេះត្រូវប្រកាសជាប្រញាប់។

## ៣.៨ ច្បាប់ការពារបេតិកភ័ណ្ឌពិភពលោក

**មាត្រា១៖** ច្បាប់នេះមានគោលដៅ ថែរក្សាការពារបេតិកភណ្ឌ វប្បធម៌ និងសម្បត្តិវប្បធម៌ ទូទៅប្រឆាំងនឹងការបំផ្លិចបំផ្លាញ ការប្រែក្លាយ ការប្តូររូបរាង ការជីករុករក ការផ្ទេរកម្មសិទ្ធ ការនាំចេញ និងការនាំដោយខុសច្បាប់។

**មាត្រា២៖** បេតិកភណ្ឌវប្បធម៌ជាតិគឺជា សម្បត្តិវប្បធម៌ ដែលត្រូវបានបង្កើតឡើង ឬក៏បានរកឃើញ នៅក្នុងទឹកដីនៃមាតុភូមិ។

**មាត្រា៣៖** ច្បាប់នេះអនុវត្តទៅលើសម្បត្តិវប្បធម៌ជាចលនៈ និងអចលនៈ ទោជាកម្មសិទ្ធសាធារណៈក្តី ឬក៏ជាឯកជនក្តី ហើយកិច្ចការពារនេះគឺជាផលប្រយោជន៍សាធារណៈ។ លើកលែងតែមានបទបញ្ញត្តិ ផ្ទុយពីច្បាប់នេះ ច្បាប់នេះអនុវត្តទៅលើសម្បត្តិវប្បធម៌ ដែលជាចំណែកនៃបេតិកភណ្ឌវប្បធម៌ជាតិតែប៉ុណ្ណោះ។

**មាត្រា៤៖** តាមន័យនៃច្បាប់នេះ សម្បត្តិវប្បធម៌គឺរាល់ស្នាដៃរបស់មនុស្ស និងរាល់ផលិតផលរបស់ធម្មជាតិ ដែលមានចរិតវិទ្យាសាស្ត្រ ប្រវត្តិសាស្ត្រ សិល្បៈឬសាសនា ដែលឆ្លុះបញ្ចាំងពីដំណាក់កាលនៃការវិវត្តន៍អារ្យធម៌របស់ធម្មជាតិ ហើយដែលកិច្ចការពារសម្បត្តិវប្បធម៌ទាំងនោះ បំរើផលប្រយោជន៍សាធារណៈ។ សម្បត្តិវប្បធម៌ដែលបានរៀបរាប់ក្នុងមាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៥៖** ការលើកគោលនយោបាយទូទៅ ក្នុងវិស័យសម្បត្តិវប្បធម៌ជាតិជាពិសេស ដើម្បីការពារថែរក្សា និងលើកតម្លៃបេតិកភណ្ឌវប្បធម៌ជាតិ គឺជាភារកិច្ចរបស់ក្រុមប្រឹក្សាជាន់ខ្ពស់ ផ្នែកវប្បធម៌ជាតិ (ក.ជ.វ.ជ) ដែលមានក្រសួងវប្បធម៌ និងវិចិត្រសិល្បៈជាស្ថាប័នប្រតិបត្តិ។

ដោយឡែកនៅតំបន់សៀមរាបអង្គរ ការការពារថែរក្សា និងលើកតម្លៃបេតិកភណ្ឌវប្បធម៌ជាតិ ត្រូវប្រគល់ឲ្យអាជ្ញាធរ ដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរហៅថា អាជ្ញាធរអប្សរា។

ការសម្របសម្រួលភារកិច្ចរវាងក្រសួងវប្បធម៌ និងវិចិត្តសិល្បៈ និងស្ថាប័នពាក់ព័ន្ធដទៃទៀត ត្រូវកំណត់ដោយអនុក្រឹត្យ។

Draft

**មាត្រា៦៖** រមណីយដ្ឋានដែលត្រូវការពាររួមមាន៖

- ឧទ្យានដែលមានបុរាណវត្ថុ ឬរមណីយដ្ឋានដទៃទៀត ដែលមានអត្ថប្រយោជន៍ សម្រាប់បុរាណវិទ្យា នរវិទ្យា ឬប្រវត្តិវិទ្យាអាចធ្វើការកំណត់ព្រំដែនបាន។
- ព្រំដែននៃបរិវេណរមណីយដ្ឋានដែលត្រូវការពារ ត្រូវកំណត់ដោយព្រះរាជក្រឹត្យតាមសំណើររបស់ ក.ជ.វ.ជ។

**មាត្រា៧៖** ការចុះបញ្ជីសារពើភណ្ឌ គឺជាការកត់ត្រាបញ្ចូលនូវសម្បត្តិវប្បធម៌សាធារណៈ ឬឯកជន ដែលមានសារៈសំខាន់ខាងផ្នែកវិទ្យាសាស្ត្រ ប្រវត្តិសាស្ត្រ សិល្បៈ ឬសាសនា ទោជាសម្បត្តិទាំងនោះមិនតម្រូវឲ្យចាត់ថ្នាក់ជាប្រញាប់ក៏ដោយ។

**មាត្រា៣៧៖** នៅពេលកំពុងដំណើរការងារផ្សេងៗ ឬសកម្មភាពផ្សេងៗទៀត ហើយបានជួបប្រទះសម្បត្តិវប្បធម៌ ដូចជាប្រសាទបាក់បែក វត្ថុបុរាណ សំណល់ផ្ទះសំបែងបុរាណ ទីបញ្ចុះសពបុរាណ សិលាចារឹក ឬសម្បត្តិវប្បធម៌ ដែលទាក់ទងដល់បុរេប្រវត្តិវិទ្យា បុរាណវិទ្យា ជាតិពន្ធុវិទ្យា

បាសាណីភូតវិទ្យា ឬក៏សាខាដទៃទៀតនៃវិទ្យាសាស្ត្រ ដែលសិក្សាពីអតីតកាល ឬមនុស្សសាស្ត្រ អ្នកដែលបានប្រទះឃើញ សម្បត្តិទាំងនេះ និងម្ចាស់អចលវត្ថុ ត្រូវតែបញ្ឈប់ការងារ ឬសកម្មភាពនោះ រួចរាយការណ៍ជាបន្ទាន់ជូនភ្នាក់ងារនគរបាលក្នុងតំបន់។ ភ្នាក់ងារនគរបាលនោះត្រូវបញ្ជូនរបាយការណ៍នេះយ៉ាងប្រញាប់ជូនទៅអភិបាលខេត្ត ក្រុង។ អភិបាលខេត្ត ក្រុងត្រូវជូនពត៌មាននេះដល់អាជ្ញាធរមានសមត្ថកិច្ចដើម្បីចាត់វិធានការចាំបាច់ដើម្បីធានាសង្គ្រោះសម្បត្តិវប្បធម៌ និងរមណីយដ្ឋានវប្បធម៌នោះ។

## ៣.៩ ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាអនុម័តនៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៧ នាសម័យប្រជុំរដ្ឋភាលើកទី៦ នីតិកាលទី៣។

**មាត្រា១៖**

ច្បាប់នេះមានគោលដៅជុំរុញ ឱ្យមានការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធិភាព និងនិរន្តភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីសំរេចបាននូវការងារអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងសុខមាលភាពរបស់ប្រជាពលរដ្ឋ។ ច្បាប់នេះកំណត់អំពី:

- សិទ្ធិ និងកាតព្វកិច្ចនៃអ្នកប្រើប្រាស់ទឹក
- គោលការណ៍គ្រឹះសំខាន់ៗ សម្រាប់ការគ្រប់គ្រងធនធានទឹក
- ការចូលរួមរបស់សហាគមន៍អ្នកប្រើប្រាស់ទឹក ក្នុងការអភិវឌ្ឍន៍ធនធានទឹកប្រកបដោយនិរន្តភាព។

**មាត្រា២៖**

ក្នុងច្បាប់នេះ ពាក្យបច្ចេកទេសមួយចំនួនមានន័យថា៖

- ទឹក គឺទឹកលើដី ទឹកក្រោមដី និងទឹកក្នុងអាកាស។
- ធនធានទឹកគឺទឹកសមុទ្រ ទន្លេ ស្ទឹង ព្រែក ជ្រោះ ជ្រលងជងអូរ បឹងបួ ត្រពាំង ថ្លុក អាងទឹក
- ទឹកក្រោមដី គឺទឹកដែលហូរនៅក្រោមដីក្នុងចន្លោះថ្មតូចធំ និងភាគល្អិតនៃដីដែលផ្លាស់ទីពីកន្លែង មួយទៅកន្លែងមួយទៀត។
- ល្អាងទឹកក្រោមដី គឺទឹកក្រោមដីដែលស្ថិតនៅជាអចិន្ត្រៃយ៍ក្នុងល្អាងធម្មជាតិក្រោមដី។
- អាងទន្លេ គឺតំបន់ភូមិសាស្ត្រដែលកំណត់ដោយព្រំប្រទល់ទីជម្រាលនៃប្រព័ន្ធទឹកហូរ ដោយរាប់បញ្ចូលទាំងទឹកលើដី និងទឹកក្រោមដី។
- អាងទន្លេរង គឺផ្នែកមួយនៃអាងទន្លេ។
- ទន្លេអន្តរជាតិ គឺទន្លេដែលមានភូមិសាស្ត្រពាក់ព័ន្ធដល់ទឹកដីប្រទេសចាប់ពីពីរឡើងទៅ។

- ច្រាំងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹក គឺចំណែកដីដែលធម្មតាលិចដោយទឹក នៅក្នុងទន្លេ ស្ទឹង ព្រែក អូរ បឹងបួ និងអាងទឹក ដោយរាប់បញ្ចូលទាំងដី ថ្ម ឬអង្គធាតុដទៃទៀត ដែលនៅឆ្ងាយពីច្រាំង និងលិចទឹកម្តងម្កាលនោះ។
- ឆ្នេរសមុទ្រ ទន្លេ ស្ទឹង គឺចំណែកដី ឬខ្សាច់ដែលមានសណ្ឋានជម្រាល និងលិចទឹកម្តងម្កាល
- បាតទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹក គឺផ្នែកមួយនៃដីដែលកំណត់ដោយច្រាំងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាតទឹកដែលគ្របដណ្តប់ដោយទឹក។
- តម្រូវការសាធារណៈ គឺការផ្គត់ផ្គង់ទឹកនៅតាមទីក្រុងនិងជនបទ ការផលិតស្បៀង ការផលិតថាមពលវារីអគ្គីសនី ការបំរើវិស័យកកសិកម្ម វិស័យឧស្សាហកម្ម វិស័យនាវាចរ និងការរក្សាឲ្យមានធារាទឹកអប្បរមា ដើម្បីថែរក្សាបរិស្ថាន ជីវិតមនុស្សជីវិតមច្ឆាជាតិ និងរុក្ខជាតិនានា។
- ការងារទឹក គឺសំណង់ទំនប់ធំ តូច ទំនប់បង្វៀរ ទំនប់បញ្ចាល់ទឹក ទំនប់ទឹកការពារទឹកជំនន់ ប្រឡាយដោះទឹកធំ តូច ប្រព័ន្ធស្រោចស្រព អាងទឹកតូចធំ ប្រឡាយនាំទឹក អណ្តូងទឹកគ្រប់ប្រភេទ ទំនប់វារីអគ្គីសនី និងសំណង់ដទៃទៀត ដែលបានសាងសង់ក្នុងគោលបំណងបង្វែរទឹក រក្សាទឹកទុក នាំទឹកយកទៅប្រើប្រាស់ អភិរក្សការពារធនធានទឹក ដោះទឹកចេញពីតំបន់ដីលិចទឹកការពារកាត់បន្ថយនូវឥទ្ធិពលទឹកជំនន់ និងសង្គ្រោះបន្ទាន់ផ្សេងៗទៀតដែលពាក់ព័ន្ធនឹងទឹក។
- អាជ្ញាប័ណ្ណទឹក គឺប័ណ្ណដែលផ្តល់សិទ្ធិប្រើប្រាស់ទឹក និងធនធានទឹកឲ្យបុគ្គលគ្រប់រូបដើម្បីធ្វើអាជីវកម្ម និងអភិវឌ្ឍន៍។
- បុគ្គល គឺរូបវន្តបុគ្គល ឬនីតិបុគ្គលទោះក្នុងន័យជាឯកជន ឬសាធារណៈក៏ដោយ។

**មាត្រា៣៖** ទឹក និងធនធានទឹក ជាសម្បត្តិរបស់រដ្ឋ។

**មាត្រា១១៖**

បុគ្គលគ្រប់រូបមានសិទ្ធិប្រើប្រាស់ធនធានទឹកក្នុងបរិមាណមួយ មិនលើសពីសេចក្តីត្រូវការចាំបាច់ជាមូលដ្ឋានសម្រាប់ការហូបចុក បោកគក់ ងូត និនងតម្រូវការផ្សេងៗ រួមមានការចិញ្ចឹមសត្វ ការចិញ្ចឹមត្រី ការស្រោចស្រពសួនច្បារ និងដំណាំ ដោយចៀសវាងមិនឲ្យមានការប៉ះពាល់ដល់សិទ្ធិស្របច្បាប់របស់អ្នកដទៃ។ តម្រូវការខាងលើនេះ មិនតម្រូវឲ្យសុំអាជ្ញាប័ណ្ណឡើយ។

**មាត្រា១២៖**

ការបង្វែរទឹក ការយកទឹក ការប្រើប្រាស់ធនធានទឹក ក្នុងគោលបំណងកសិកម្ម ឬឧស្សាហកម្មលើសពីកំរិតដែលមានចែងក្នុងមាត្រា ១១ និងសំណង់ការងារទឹកដែលពាក់ព័ន្ធ តម្រូវឲ្យ

មានការសុំ ជាអាជ្ញាប័ណ្ណទឹក ឬលិចិតអនុញ្ញត។ បែបបទនៃការសុំនេះ មិនមានចែងក្នុអនុក្រិត្យ។ ការយកខ្សាច់ដី ឬគ្រួសប្រេងកាត និងឧស្ម័នពីបាត ច្រាំង ឆ្នេរ សមុទ្រ ឆ្នេរទន្លេ ស្ទឹង ព្រែក អូរ បឹងបួតម្រូវឲ្យមានការសុអាជ្ញាប័ណ្ណទឹក។ បែបបទបច្ចេកទេសជលសាស្រ្តដែលពាក់ព័ន្ធនឹងការងារនេះ នឹងមានចែងលំអិតនៅក្នុង អនុក្រិត្យ។ ការលប់ទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ អាងទឹក និងអាងធម្មជាតិតម្រូវឲ្យមានការសុំអាជ្ញាប័ណ្ណទឹក ឬលិខិតអនុញ្ញាតិ។ បែបបទនៃការសុំនេះនឹងមានចែងនៅក្នុងអននុក្រឹត្យ។ ការសាងសង់ ស្ពានតូចធំ កាត់ទន្លេ ស្ទឹង កំពង់ផែ ឬ សំណង់អាគារតូចធំ លើច្រាំង និងឆ្នេរទន្លេតម្រូវឲ្យមានការឯភាពផ្នែកបច្ចេកទេសជាមុនពីក្រសួងធនធានទឹក និងឧតុនិយម។ការបង្វែរទឹកពីប្រភពដើមចេញពីទឹកដីនៃព្រះរាជាណាចក្រកម្ពុជាត្រូវមានការអនុញ្ញាតិ និងយល់ព្រមពីរាជរដ្ឋាភិបាលកម្ពុជា ដោយមានការអនុម័តយល់ព្រមពិស្ថាប័ននីតិបញ្ញតិ។

**<u>មាត្រា១៨៖</u>**

មុនពេលផ្តល់អាជ្ញាប័ណ្ណទឹកដល់បុគ្គលណាមួយ ក្រសួងធនធានទឹក និងឧតុនិយម ត្រូវពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានលើការប្រើប្រាស់ទឹក និងការសាងសង់ សំណង់ការងារទឹកដែលបុគ្គលនោះស្នើឡើង។

**<u>មាត្រា២២៖</u>**

រាល់ការបញ្ចេញចោល ការទុកចោល ឬការរក្សាទុកនូវសារធាតុពលដែលអាចធ្វើឱ្យប៉ះពាល់ដល់គុណភាពទឹក និងអាចបង្កគ្រោះថ្នាក់ដល់មនុស្ស សត្វ និងរុក្ខជាតិ ត្រូវតែសុំអាជ្ញាប័ណ្ណទឹក ឬការ អនុញ្ញតិ។ ប្រភេទសារធាតុពុលដែលមានចែងខាងលើ និងស្តង់ដារបច្ចេកទេសនៃការបញ្ចេញទឹក សំណល់នឹងមានកំណត់ដោយអនុក្រឹត្យ។ រាល់កិច្ចដំណើរការក្នុងមរត្រានេះ ក្រសួងធនធានទឹក និងឧតុនិយម ត្រូវពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធនានា។

**<u>មាត្រា២៣៖</u>**

ក្រសួងធនធានទឹក និងឧតុនិមយ អាចប្រកាសទុកជាតំបន់អាសន្ន ឬជាតំបន់ហាមឃាត់ការប្រើប្រាស់ទឹកក្នុងករណីដែល:

- ទឹកលើដី ឬទឹកក្រោមដីត្រូវនបានប៉ះពាល់ផ្នែកបរិមាណ គុណភាព ឬតុល្យភាពអេកូឡូស៊ី។
- ទឹកលើទីជំរាលដែលកំពុងរងការគំរាមគំហែងដោយសកម្មភាពមនុស្ស ឬធម្មជាតិ។
- ទឹកដែលបណ្តាលឲ្យប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋ។

ដែនភូមិសាស្ត្រនៃតំបន់អាសន្ន ឬតំបន់ហាមឃាត់នោះ ត្រូវកំណត់តាមករណីនិមួយៗ ដោយប្រកាសរបស់ក្រសួងធនធានទឹក និងឧតុនិយម។

**មាត្រា៣២៖**

រាល់វិវាទដែលពាក់ព័ន្ធនឹងការបង្កើត និងដំណើរការសេវាក្នុងការប្រើប្រាស់ទឹកត្រូវសម្រួលដោះស្រាយដោយក្រសួងធនធានទឹក និងឧតុនិយម ក្រសួងពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន។

**មាត្រា៣៥៖**

រាជរដ្ឋាភិបាលអាចផ្តល់រង្វាន់លើកទឹកចិត្ត ឬភាពអនុគ្រោះផ្សេងៗដល់បុគ្គលទាំងឡាយដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវ ការបង្កើតបច្ចេកវិទ្យាថ្មីៗ ឬការដំឡើងឧករណ៍ទំនើបដែលជួយ កាត់បន្ថយកាកសំណល់ និងជួយបង្កើនគុណភាពទឹក ដើម្បីឲ្យការប្រើប្រាស់ទឹកមានប្រសិទ្ធភាពខ្ពស់។ លក្ខណៈវិនិច្ឆ័យ និងបែបបទសម្រាប់ការផ្តល់រង្វាន់លើកទឹកចិត្ត ឬភាពអនុគ្រោះផ្សេងៗ ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងធនធានទឹក និងឧតុនិយម។

## ៣.១០ អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

អនុក្រឹត្យលេខ ៧២អនក្រ.បក ស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន បានអនុម័តនៅ ថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩។

**មាត្រា១៖**

អនុក្រឹត្យនេះមានគោលបំណង៖

- កំណត់ការវាយតំលៃហេតុប៉ះពាល់បរិស្ថានលើរាល់គម្រោង និងសកម្មភាពរបស់ឯកជន ឬសាធារណៈ ហើយត្រូវបានពិនិត្យ និងវាយតំលៃហេតុប៉ះពាល់បរិស្ថានលើរាល់គម្រោង និងសកម្មភាពរបស់ឯកជន ឬសាធារណៈ ហើយត្រូវបានពិនិត្យ និងវាយតំលៃដោយក្រសួងបរិស្ថាន មុននឹងដាក់ជូនរដ្ឋាភិបាលសំរេច។
- កំណត់ប្រភេទ និងទំហំនៃគម្រោងសកម្មភាព ដែលបានស្នើឡើងព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការទាំងឯកជន ទាំងសាធារណៈដែលត្រូវវាយតំលៃហេតុប៉ះពាល់បរិស្ថាន។
- បំផុសឲ្យមានការចូលរួម ពីសាធារណៈជន ក្នុងកិច្ច ដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ព្រមទាំងទទួលយកមតិយោបល់មកធ្វើការពិចារណាក្នុងកិច្ចដំណើរការអនុម័តគម្រោង។

Draft

**មាត្រា២៖**

អនុក្រឹត្យនេះមានវិសាលភាព អនុវត្តចំពោះគម្រោងដែលស្នើរឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ ដែលជាបុគ្គលឯកជន ជាក្រុមហ៊ុនឯកជន ជាក្រុមហ៊ុនចំរុះរដ្ឋ ឬជាក្រុមហ៊ុនរដ្ឋ ជាក្រសួង-ស្ថាប័នរដ្ឋ លើកលែងតែគម្រោងដែលមានលក្ខណៈពិសេស និងចាំបាច់បន្ទាន់ ដែឡសំរេចដោយរាជរដ្ឋាភិបាល។

**មាត្រា៣៖**

ក្រសួងបរិស្ថានមានភារៈកិច្ចៈ

ក. ពិនិត្យ និងវាយតំលៃលើ របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ

ខ. តាមដាន ឃ្លាំមើល និងចាត់វិធានការឲ្យម្ចាស់គម្រោងប្រតិបត្តិតាម ផែនការគ្រប់គ្រងបរិស្ថានក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិ និងបញ្ចប់គម្រោង ដូចមានចែងក្នុងរបាយការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ដែលបានអនុម័តរួច។

**មាត្រា៤៖**

ស្ថាប័ន និងក្រសួងដែលមានសិទ្ធអនុម័តលើគម្រោង មានភារៈកិច្ច ពិនិត្យ និងសំរេចលើគម្រោង ដែលក្រសួងបរិស្ថានបានពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន។

**មាត្រា៥៖**

អាជ្ញាធរខេត្ត-ក្រុង ដែលមានសិទ្ធិអនុម័តលើគម្រោង ខេត្ត-ក្រុងមានភារៈកិច្ច

- បញ្ជូននូវរបាយការវាយតំលៃហេតុប៉ះពាល់បរិស្ថាន នៃគម្រោងដែលជាបុគ្គលឯកជនជាក្រុមហ៊ុនឯកជន ជាក្រុមហ៊ុនចំរុះរដ្ឋ ឬជាក្រុមហ៊ុនរដ្ឋ ទៅមន្ទីរបរិស្ថានខេត្ត-ក្រុង
- ពិនិត្យ និងសម្រេចលើគម្រោង បន្ទាប់ពីបានពិចារណាលើយោបល់របស់មន្ទីរបរិស្ថានថ្នាក់ ខេត្ត-ក្រុង ដែលក្រសួងបរិស្ថានបានប្រគល់សិទ្ធជូន ដោយប្រកាសរបស់ក្រសួងបរិស្ថាន។

**មាត្រា៦៖**

ម្ចាស់គម្រោងត្រូវធ្វើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ចំពោះគម្រោងដែលតម្រូវឲ្យ មានការវាយតំលៃហេតុប៉ះពាល់បរិស្ថាន។

**មាត្រា៧៖**

ម្ចាស់គម្រោង ត្រូវដាក់ពាក់សុំពិនិត្យ របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង និងរបាយការណ៍បុរេលិទ្ធភាពទៅក្រសួងបរិស្ថាន។

**មាត្រា៨៖**

ម្ចាស់គម្រោងត្រូវដាក់ពាក្យសុំពិនិត្យរបាយការណ៍ វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ និងរបាយការសិក្សាលទ្ធភាពទៅក្រសួងបរិស្ថាន ចំពោះគម្រោងដែលអាចបង្ករហេតុប៉ះពាល់បរិស្ថានធ្ងន់ធ្ងរ ដល់ធនធានធម្មជាតិ អេកូស៊ីស្តែម សុខភាព និងសុខមាលភាពសាធារណៈ។

**មាត្រា៩៖**

ម្ចាស់គម្រោងត្រូវដាក់ពាក្យសុំពិនិត្យរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ដូចមានចែងក្នុង មាត្រាទី ៧ និងមាត្រាទី ៨ ទៅមន្ទីរបរិស្ថាន ខេត្ត-ក្រុង គម្រោងថ្នាក់ ខេត្ត-ក្រុង។

**មាត្រា១០៖**

គោលការណ៍ណែនាំ ស្តីពីការធ្វើរបាយការ វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង និងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន។

**មាត្រា១១៖**

ម្ចាស់គម្រោងត្រូវបង់ថ្លៃសេវាការងារ សំរាប់ការពិនិត្យលើរបាយការណ៍ វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងតាមដាន ឃ្លាំមើលការអនុវត្តគម្រោង។ តំលៃសេវាការងារនេះ ត្រូវកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើររបស់ក្រសួងបរិស្ថាន ដែលត្រូវបញ្ចូលក្នុងថវិការជាតិ។

**មាត្រា១២៖**

ម្ចាស់គម្រោងត្រូវបង់វិភាគទាន ចូលក្នុងមូលនិធិទាយជ្ជទានបរិស្ថាន សំរាប់កិច្ចការពារបរិស្ថាន ដូចមានចែងក្នុងមាត្រា ១៩ នៃច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។

**មាត្រា១៣៖**

ពាក្យសុំត្រូវបំពេញដោយម្ចាស់គម្រោង និងត្រូវផ្តល់ជូនដោយក្រសួងបរិស្ថាន ចំពោះគម្រោង ថ្នាក់ក្រសួង-ស្ថាប័ន និងត្រូវផ្តល់ជូនដោយមន្ទីរបរិស្ថានខេត្ត-ក្រុង ចំពោះគម្រោងថ្នាក់ ខេត្ត-ក្រុង។

**មាត្រា១៤៖**

ម្ចាស់គម្រោងត្រូវរៀបចំ និងបញ្ជូនរបាយការណ៍ ដូចមានចែងក្នុងមាត្រា ៧ ទៅក្រសួងបរិស្ថាន និងផ្តល់លិខិតចំលង ទៅស្ថាប័នអនុម័តគម្រោង។

Draft

**មាត្រា១៥៖**

ក្រសួងបរិស្ថានត្រូវពិនិត្យរបាយការណ៍ ដូចមានចែងក្នុងមាត្រា ១៤ ព្រមទាំងចាត់បញ្ជូនយោបល់ និងសំណើរទៅម្ចាស់គម្រោង និងស្ថាប័នអនុម័តគម្រោងក្នុងរយៈពេល ៣០ ថ្ងៃ គិតថ្ងៃធ្វើការ ចាប់ពីថ្ងៃដែលក្រសួងបានទទួលរបាយការណ៍សិក្សាបុរេលទ្ធភាព និងរបាយការវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ពីម្ចាស់គម្រោង។

**មាត្រា១៦៖**

ក្នុងករណីដែលក្រសួងបរិស្ថាន តម្រូវឲ្យមានរបាយការណ៍ វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ ម្ចាស់គម្រោងត្រូវរៀបចំ និងបញ្ជូនរបាយការណ៍ ដូចមានចែងក្នុងមាត្រា ៨ ទៅក្រសួងបរិស្ថាន ជាមួយនឹងការដាក់ពាក្យសុំវិនិយោគទៅស្ថាប័នអនុម័តគម្រោង។

**មាត្រា១៧៖**

ក្រសួងបរិស្ថានត្រូវពិនិត្យរបាយការណ៍ ដូចមានចែងក្នុងមាត្រា ១៦ ព្រមទាំងចាត់បញ្ជូនយោបល់ និងសំណើរទៅម្ចាស់គម្រោង និងស្ថាប័នអនុម័តគម្រោងក្នុងរយៈពេល ៣០ ថ្ងៃ គិតថ្ងៃធ្វើការ ចាប់ពីថ្ងៃដែលក្រសួងបានទទួលរបាយការណ៍សិក្សាបុរេលទ្ធភាព និងរបាយការវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ពីម្ចាស់គម្រោង។

**មាត្រា១៨៖**

ក្នុងករណីដែលក្រសួងបរិស្ថានខកខាន មិនបានបញ្ជូនយោបល់ និងសំណើដូចមានចែងក្នុងមាត្រា ១៥ និងមាត្រា ១៧ នោះ ស្ថាប័នអនុម័តគម្រោងអាចកំណត់ថា គម្រោងនោះត្រូវបានបំពេញតាម តម្រូវការនៃអនុក្រឹត្យនេះ។

**មាត្រា១៩៖**

ក្នុងសមត្ថកិច្ច ជាស្ថាប័នអនុម័តគម្រោងផង និងជាម្ចាស់គម្រោងផងនោះ ម្ចាស់គម្រោងត្រូវមានភារៈកិច្ច អនុវត្តតាមកិច្ចដំណើរការ ដូចដែលបានចែងខាងលើ។

**មាត្រា២០៖**

មុនចាប់ដំណើរការអនុវត្តគម្រោង ម្ចាស់គម្រោងត្រូវទទួលយោបល់ឯកភាពពីក្រសួងបរិស្ថាន លើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ។

**មាត្រា២១៖**

ក្នុងរយៈពេលយ៉ាងយូរ ០១ ឆ្នាំ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវ ត្រូវរៀបចំធ្វើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង និងដាក់ពាក្យសុំពិនិត្យរបាយការណ៍នេះ មកក្រសួងបរិស្ថាន ចំពោះសកម្មភាពមានស្រាប់ និងកំពុងដំណើរការ ដែលមានទទួលការអនុម័ត ពីថ្នាក់ក្រសួង-ស្ថាប័ន។

Draft

**មាត្រា២២៖**

ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវ ត្រូវរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ យ៉ាងយូរ ០៦ ខែ ទៅតាមតម្រូវការដែលមានចែង ក្នុងករណីដែលក្រសួងបរិស្ថាន បានពិនិត្យឃើញថា សកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ តម្រូវឲ្យមានការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ។

**មាត្រា២៣៖**

ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវ ត្រូវអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ដែលមានចែងក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ក្នុងរយៈពេល ០៦ ខែ គិតចាប់តាំងពីថ្ងៃ ដែលក្រសួងបរិស្ថាន បានចេញសេចក្តីជូនដំណឹងថា របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន បានបំពេញតាមតម្រូវការ នៃអនុក្រឹត្យនេះ។

**មាត្រា២៤៖**

ក្នុងរយៈពេលយ៉ាងយូរ ០២ ឆ្នាំ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវ ត្រូវរៀបចំធ្វើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង និងដាក់ពាក្យសុំពិនិត្យ របាយការណ៍នេះ មកមន្ទីរបរិស្ថាន ខេត្ត- ក្រុង ចំពោះសកម្មភាពមានស្រាប់ និងកំពុងដំណើរការដែលបានទទួលការអនុម័តពីថ្នាក់ ខេត្ត- ក្រុង។

**មាត្រា២៥៖**

ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវ ត្រូវរៀបចំរបាយការណ៍ វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ យ៉ាងយូរ ០៦ ខែ ទៅតាមតម្រូវការដែលមានចែងកន្លងមក ក្នុងករណីដែលមន្ទីរបរិស្ថាន ខេត្ត- ក្រុង ពិនិត្យឃើញថា សកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការតម្រូវឲ្យមានការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ។

**មាត្រា២៦៖**

ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវ ត្រូវអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ដែលមានចែងក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាននោះ ក្នុងរយៈពេល ០៦ ខែ គិតចាប់ពីថ្ងៃដែលមន្ទីរបរិស្ថាន ខេត្ត- ក្រុងបានចេញសេចក្តីជូនដំណឹងថា របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន បានបំពេញតាម តម្រូវការនៃអនុក្រឹត្យនេះ។

**មាត្រា២៧៖**

ស្ថាប័នអនុម័តគម្រោង ត្រូវណែនាំម្ចាស់គម្រោង ឬម្ចាស់កម្មសិទ្ធ ឲ្យអនុវត្តតាមផែនការគ្រប់គ្រងបរិស្ថាននៃគម្រោង ដូចបានរៀបចំក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ដែលបានអនុម័តដោយក្រសួងបរិស្ថាន។

**មាត្រា២៨៖**

ក្រសួងបរិស្ថាន ត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធ ចេញបញ្ជាឲ្យផ្អាកសកម្មភាពចំពោះម្ចាស់គម្រោង ឬម្ចាស់កម្មសិទ្ធណា ដែលពុំបានអនុវត្តតាម ផែនការគ្រប់គ្រងបរិស្ថាននៃគម្រោង ដូចបានចែងក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ដែលបានឯកភាពរួចហើយ។

**មាត្រា២៩៖**

ម្ចាស់គម្រោង ឬម្ចាស់កម្មសិទ្ធដែលខកខានមិនបានផ្តល់ ឬបកស្រាយខុសនូវពត៌មាន ឬមិនបានអនុវត្តតាមផែនការគ្រប់គ្រងបរិស្ថាន ដូចបានពិពណ៌នានៅក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ឬបំពាននឹងបទប្បញ្ញត្តិណាមួយ នៃអនិក្រឹត្យនេះ ត្រូវផ្តន្ទាទោស ដូចមានចែងក្នុងមាត្រា ២០ ២១ ២២ ២៣ និង ២៥ នៃជំពូកទី ៩ នៃច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។

**មាត្រា៣០៖**

កំណត់ហេតុ និងការធ្វើបណ្តឹងចំពោះជនទាំងឡាយណា ដែលបានប្រព្រឹត្តផ្ទុយ ឬពុំអនុវត្តតាមមាត្រាណាមួយ នៃអនុក្រឹត្យនេះ គឺជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន។

**មាត្រា៣១៖**

មន្ត្រីបរិស្ថានរូបណា ដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជា របស់ក្រសួង ឬរួមគំនិត នឹងអ្នកប្រព្រឹត្តបទល្មើស ឬជួយសម្រួលដល់ការប្រព្រឹត្តបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោស ផ្នែករដ្ឋបាល ឬនឹងត្រូវជាប់បទចោទប្រកាន់ចំពោះមុខតុលាការ។

**មាត្រា៣២៖**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣៣៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះតាមភារៈកិច្ចរៀងៗខ្លួនៗ។

**មាត្រា៣៤៖**

អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

Draft

## ៣.១១ អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក

អនុក្រឹត្យលេខ ២៧ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលទឹក បានអនុម័តនៅថ្ងៃទី ០៦ ខែមេសា ឆ្នាំ១៩៩៩ អនុក្រឹត្យនេះមានចែងដូចតទៅ ៖

**មាត្រា១៖**

អនុក្រឹត្យនេះមានគោលដៅ កំណត់ការត្រួតពិនិត្យការបំពុលទឹក ដើម្បីទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ សំដៅធានាបានការការពារសុខភាពមនុស្ស និងការអភិរក្សជីវៈចំរុះ។

**មាត្រា២៖**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរាល់ប្រភពបំពុល និងរាល់សកម្មភាពទាំងឡាយណាដែលបង្ករឲ្យមានការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ។

**មាត្រា៣៖**

និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានបកស្រាយដូចតទៅ៖

ក. តំបន់ទឹកសាធារណៈ : គឺសំដៅទៅលើតំបន់ទឹកសំរាប់ប្រើប្រាស់ជាសាធារណៈ ដូចជា៖ ទន្លេ ស្ទឹង ជ្រោះ អូរ ព្រែក បឹង ស្រះ អណ្តូង ត្រពាំង ថ្លុក សមុទ្រ ពាម ដោយរាប់បញ្ចូល ទាំងប្រព័ន្ធប្រលាយធារាសាស្ត្រ និងផ្លូវទឹកដទៃទៀតដែលសំរាប់ប្រើប្រាស់ជាសាធារណៈ និងទឹកក្រោមដី។

ខ. ប្រភពបំពុល : គឺសំដៅទៅលើទីតាំងអាគារទាំងឡាយណា រួមទាំងលំនៅស្ថាន និងអាគាររដ្ឋបាលសាធារណៈ ទីបរិវេណ មធ្យោបាយដឹកជញ្ជូន និងតំបន់អាជីវកម្ម ឬសេវាកម្ម ដែលបញ្ចេញសំណល់រាវ សារធាតុបំពុល ឬសារធាតុដែលបង្កអោយមានគ្រោះថ្នាក់ ដោយផ្ទាល់ក្តី ឬមិនផ្ទាល់ក្តី ចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬចូលទៅក្នុងបណ្តាញលូសាធារណៈ។

គ. សំណល់រាវ : គឺសំដៅទៅលើវត្ថុរាវ ដែលបញ្ចេញពីប្រភពបំពុល ចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬចូលទៅក្នុងបណ្តាញលូសាធារណៈ ទោះបានធ្វើប្រព្រឹត្តកម្ម ឬមិនបានធ្វើប្រព្រឹត្តកម្ម ក្តី។

ឃ. ទឹកលូ : គឺសំដៅទៅលើទឹកកខ្វក់ ដែលបញ្ចេញពីលំនៅស្ថាន និងអាគារសាធារណៈ។

ង. សំណល់រឹង: គឺសំដៅទៅលើសារធាតុ ឬរបស់រឹង ដែលលែងប្រើប្រាស់ហើយត្រូវបានបញ្ចេញចោលពីប្រភពបំពុល។

**ច. សំរាម** : គឺសំដៅលើសារធាតុ ឬរបស់រឹងដែលលែងប្រើប្រាស់ ហើយត្រូវបានបញ្ចេញចោលពីលំនៅស្ថាន និងអាគារសាធារណៈ។

**ឆ. សារធាតុបំពុល** : គឺសំដៅទៅលើសារធាតុរឹង រាវ ឬឧស្ម័ន ឬសំណល់គ្រប់ប្រភេទ ដែលធ្វើឲ្យមានការប្រែប្រួលនូវធាតុផ្សំ ឬលក្ខណៈរបស់ទឹក ដូចជា ៖ ធ្វើឲ្យប្រែប្រួលនូវ លក្ខណៈរូប លក្ខណៈគីមី ឬលក្ខណៈជីវសាស្ត្ររបស់ទឹក នៅពេលបញ្ចេញ ឬចាក់វាចូលទៅក្នុងទឹកដោយចេតនាក្តី ឬអចេតនាក្តី។

**ជ. បរិមាណសារធាតុបំពុល** : គឺសំដៅទៅលើបន្ទុក ឬចំណុះសារធាតុបំពុល រួមទាំងកំដៅ ដែលមាននៅក្នុងសំណល់រាវ ដែលត្រូវបានបញ្ចេញចោលពីប្រភពបំពុល ចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬប្រព័ន្ធលូសាធារណៈ។

**ឈ. សារធាតុប្រកបដោយគ្រោះថ្នាក់** : គឺសំខៅទៅសារធាតុ ដែលបណ្តាលឲ្យមានគ្រោះថ្នាក់ទៅដល់សរីរាង្គមានជីវិត ឬធ្វើឲ្យខូច ឬបាក់បែកវត្ថុសំភារៈ អាគារ ឬបណ្តាលឲ្យ ប៉ះពាល់ ឬមហន្តរាយដល់បរិស្ថាន។ ប្រភេទសារធាតុប្រកបដោយគ្រោះថ្នាក់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ១ នៃអនុក្រឹត្យនេះ។

**<u>មាត្រា៤៖</u>**

កំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវពីប្រភពបំពុលទាំងឡាយ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ២ នៃអនុក្រឹត្យនេះ។

**<u>មាត្រា៥៖</u>**

ក្នុងករណីចំបាច់ និងតំរូវការទៅតាមតំបន់នីមួយៗ ក្នុងការការពារសុខភាពមនុស្ស និងការអភិរក្សជីវចំរុះ ក្រសួងបរិស្ថាន ត្រូវរៀបចំកំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវដោយឡែកសំរាប់អនុវត្តលើប្រភពបំពុល ដែលតាំងនៅជុំវិញតំបន់ទឹកសាធារណៈនោះ។

កំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវដោយឡែក ដូចមានចែងនៅក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ៥ នៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយក្រសួងបរិស្ថាន។

**<u>មាត្រា៦៖</u>**

ហាមឃាត់ជាដាច់ខាតនូវរាល់ការចាក់ចោល ឬការបង្ហូរចេញសំណល់រាវពីប្រភពបំពុលណាមួយ ដែលមិនអនុវត្តតាមកំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវ ដូចមានចែងក្នុងមាត្រា ៤ និង មាត្រា ៥ នៃអនុក្រិត្យនេះ ។

**មាត្រា៧ ៖**

ក្រសួងបរិស្ថានត្រូវរៀបចំកំរិតកំណត់ស្តង់ដារបរិមាណសារធាតុបំពុលនៅក្នុងសំណល់រាវ ដែលអាចអនុញ្ញាតឲ្យបញ្ចេញពីប្រភពបំពុលនានា ចូលទៅក្នុងតំបន់ទឹកសាធារណៈ ដែលត្រូវការពារ ដើម្បីធានាបាននូវការការពារសុខភាពមនុស្ស និងការអភិរក្សជីវៈចំរុះ។

**មាត្រា៨ ៖**

ហាមឃាត់ជាដាច់ខាតនូវការចាក់ចោលសំរាម សំណល់រឹង ឬសារធាតុប្រកបដោយគ្រោះថ្នាក់ ទៅក្នុងតំបន់ទឹកសារធារណៈ ឬប្រព័ន្ធលូសាធារណៈ ដែលនាំឲ្យមានការបំពុលទឹកនៅតំបន់ទឹកសាធារណៈ។

**មាត្រា៩ ៖**

ហាមឃាត់ជាដាច់ខាតនូវការបង្ហូរទឹកលូចេញពីលំនៅស្ថាន ឬពីអាគារសាធារណៈ ចូលទៅក្នុងតំបន់ទឹកសាធារណៈ ដោយពុំឆ្លងកាត់ប្រព័ន្ធលូសាធារណៈ ឬប្រព័ន្ធច្រោះសំអាតនានា។

**មាត្រា១០ ៖**

ការបញ្ចេញចោល ឬការដឹកចេញនូវសំណល់រាវពីប្រភពបំពុល ទៅកន្លែងដ៏ទៃ ក្នុងគោលបំណងណាមួយ ត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថានជាមុនសិន និងត្រូវធ្វើសេចក្តីចំលងនៃពាក្យស្នើរសុំនោះ ទៅក្រសួង និងស្ថាប័នពាក់ព័ន្ធ។

**មាត្រា១១ ៖**

ប្រភេទនៃប្រភពបំពុល ដែលតំរូវឲ្យសុំការអនុញ្ញាតពីក្រសួងបរិស្ថាន មុននឹងធ្វើការបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅកន្លែងដ៏ទៃ ដូចមានចែងក្នុងមាត្រាទី ១០ នៃអនុក្រឹត្យនេះ ហើយបានបែងចែកជា ២ ប្រភេទ៖

ក. ប្រភពបំពុលប្រភេទថ្នាក់ទី ១ : តំរូវឲ្យមានការសុំអនុញ្ញាតពីក្រសួងបរិស្ថាន ក្នុងករណីដែលបរិមាណសំណល់រាវរបស់ប្រភពបំពុល នោះមានចំនួនច្រើនជាង ១០ ម៉ែត្រគូបក្នុងមួយថ្ងៃ ដោយពុំគិតបញ្ចូលនូវបរិមាណទឹកដែលប្រើប្រាស់សំរាប់ប្រព័ន្ធត្រជាក់នៃគ្រឿងចក្រ។

ខ. ប្រភពបំពុលប្រភេទថ្នាក់ទី ២ : ចាំបាច់តំរូវឲ្យមានការសុំអនុញ្ញាតពីក្រសួងបរិស្ថាន។

Draft

**មាត្រា១២ ៖**

ការសុំអនុញ្ញាតលើការបញ្ចេញសំណល់ ឬការដឹកសំណល់រាវ ចេញពីប្រភពបំពុលទៅកន្លែងដទៃ ដូចមានចែងនៅក្នុងមាត្រាទី ១០ នៃអនុក្រឹត្យនេះ នឹងត្រូវអនុវត្តទៅលើប្រភពបំពុលទាំងគម្រោងថ្មី និងទាំងគម្រោងកំពុងដំណើរការ លើកលែងតែគម្រោងប្រភពបំពុលថ្មី ដែលរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានរបស់គម្រោងនោះត្រូវបានអនុម័ត នឹងត្រូវបានរួចផុត ពីការតំរូវឲ្យសុំការអនុញ្ញាត លើការបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅកន្លែងដទៃ។

**មាត្រា១៣ ៖**

ម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ដូចមានចែងក្នុងមាត្រា ១១ នៃអនុក្រឹត្យនេះ ដែលមានបំណងធ្វើការបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅកាន់កន្លែងដទៃ ត្រូវដាក់សុំ ការអនុញ្ញាតមកក្រសួងបរិស្ថាន៖

- អោយបានមុន ៤០ ថ្ងៃ សំរាប់គម្រោងនៅភ្នំពេញ និង ៦០ ថ្ងៃសំរាប់គម្រោងនៅតាមខេត្តក្រុង នៃការចាប់ផ្តើមដំណើរការ សំរាប់ប្រភពបំពុលដែលជាគម្រោងថ្មី។
- អោយបានក្នុងរយៈពេល ៣០ ថ្ងៃ សំរាប់ប្រភពបំពុលនៅភ្នំពេញ និង ៥០ ថ្ងៃសំរាប់គម្រោងនៅតាមខេត្តក្រុង ក្រោយពេលទទួលបានការណែនាំពីក្រសួងបរិស្ថាន សំរាប់ប្រភពបំពុលដែលកំពុងដំណើរការ។

**មាត្រា១៤ ៖**

លិខិតអនុញ្ញាតលើការបញ្ចេញចោល ឬដឹកសំណល់ចេញពីប្រភពបំពុលទៅកាន់កន្លែងដទៃ នឹងត្រូវបានផ្តល់ជូន ប្រសិនបើបែបបទនៃការសុំអនុញ្ញាតនោះ ត្រូវបានបំពេញទៅតាមគោលការណ៍ ណែនាំបច្ចេកទេស ដែលកំណត់ដោយក្រសួងបរិស្ថាន។

**មាត្រា១៥ ៖**

ម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ដែលទទួលបានការអនុញ្ញាតពីក្រសួងបរិស្ថាន អោយបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅទីដទៃ ហើយមានបំណងចងធ្វើការផ្លាស់ប្តូរប្រព័ន្ធ បញ្ចេញសំណល់រាវរបស់ខ្លួន ត្រូវដាក់ពាក្យសុំការអនុញ្ញាតថ្មី ទៅក្រសួងបរិស្ថានឲ្យបានមុន ៣០ ថ្ងៃ នៃការចាប់ផ្តើមដំណើរការផ្លាស់ប្តូរ។

**មាត្រា១៦ ៖**

បុគ្គលដែលជួល ឬអ្នកកាន់កាប់បន្តប្រភពបំពុលពីម្ចាស់កម្មសិទ្ធដើម ឬអ្នកទទួលខុសត្រូវ ដើម ដែលបានទទួលការអនុញ្ញាតពីក្រសួងបរិស្ថាន ឲ្យបញ្ចេញ ឬដឹកសំណល់រាវរបស់ខ្លួន

ទៅទីដំទៃត្រូវអនុវត្តបន្តរឲ្យបានត្រឹមត្រូវនូវចំណុច ដែលបានកំណត់នៅក្នុងពាក្យសុំការអនុញ្ញាត ដែលម្ចាស់កម្មសិទ្ធដើម ឬអ្នកទទួលខុសត្រូវដើម បានដាក់ជូនទៅក្រសួងបរិស្ថាន។

ម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវថ្មីនៃប្រភពបំពុល ត្រូវផ្តល់សេចក្តីជូនដំណឹងពីការជួល ឬការកាន់កាប់បន្តរបស់ខ្លួនទៅក្រសួងបរិស្ថាន ក្នុងរយៈពេល ៣០ ថ្ងៃយ៉ាងយូរ ក្រោយពីបានការជួល ឬកាន់កាប់បន្តរនោះ។

**<u>មាត្រា១៧ ៖</u>**

លិខិតអនុញ្ញាតលើការបញ្ចេញចោល ឬដឹកសំណល់រាវចេញពីប្រភពបំពុល ដែលបានផ្តល់ជូនទៅឲ្យម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពបំពុល នឹងត្រូវបានដកហូតជាបណ្តោះអាសន្ន ឬជាស្ថាពរ បន្ទាប់ពីមានការពិគ្រោះយោបល់ជាមុនជាមួយក្រសួង ឬស្ថាប័នពាក់ព័ន្ធ ប្រសិនបើម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវ ប្រភពបំពុលនោះ ប្រព្រឹត្តល្មើសធ្ងន់ធ្ងរ ទៅនឹងមាត្រាណាមួយនៃមាត្រា ១៤ និង១៥ ឬមាត្រា ១៦ នៃអនុក្រឹត្យនេះ។

Draft

**<u>មាត្រា១៨ ៖</u>**

ការត្រួតពិនិត្យនូវរាល់ការចាក់ចោល ឬការបង្ហូរចេញសំណល់រាវពីប្រភពបំពុល ជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន។

**<u>មាត្រា១៩ ៖</u>**

ក្រសួងបរិស្ថាន ត្រូវចុះយកគំរូតាងសំណល់រាវ នៅគ្រប់ចំណុចបញ្ចេញរបស់ប្រភពបំពុល។

ម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ត្រូវចូលរួមសហការ និងបង្ករលក្ខណៈងាយស្រួលដល់មន្ត្រីបរិស្ថាន ដែលចុះយកគំរូតាង ដើម្បីបំពេញការងារតាមលក្ខណៈបច្ចេកទេស។

**<u>មាត្រា២០ ៖</u>**

ការវិភាគគំរូតាងសំណល់រាវ ដែលយកបានមកពីប្រភពបំពុលក្នុងពេលចុះត្រួតពិនិត្យ ឬធ្វើអធិការកិច្ច ត្រូវធ្វើនៅក្នុង មន្ទីរពិសោធន៍ក្រសួងបរិស្ថាន។

**<u>មាត្រា២១ ៖</u>**

ម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ត្រូវបង់ថ្លៃវិភាគសំណល់រាវរបស់ខ្លួនតាមបញ្ជីចំនួនទឹកប្រាក់ ដែលបានកំណត់ជាមុនដោយក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ចំណូលនេះ ត្រូវបញ្ចូលទៅក្នុងថវិការជាតិ ដើម្បីផ្តល់ជយនទៅគណនីមូលនិធិទាយជ្ជទានបរិស្ថាន។

**មាត្រា២២ ៖**

ម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពបំពុល អាចសុំធ្វើការវិភាគគំរូតាងសំណល់រាវរបស់ខ្លួន នៅតាមមន្ទីរពិសោធន៍រដ្ឋ ឬឯកជនដ៏ទៃទៀត ដែលមានការទទួលស្គាល់ជាផ្លូវការ ហើយដែលមន្ទីរពិសោធន៍នោះអនុវត្តវិធីសាស្ត្រវិភាគ ដូចដែលបានអនុវត្តនៅក្នុងមន្ទីរពិសោធរបស់ក្រសួងបរិស្ថាន។

**មាត្រា២៣ ៖**

ចំពោះប្រភពបំពុល ដូចមានចែងក្នុងមាត្រា ១១ នៃអនុក្រឹត្យនេះម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពបំពុលត្រូវ៖

ក. ទទួលខុសត្រូវក្នុងការកំណត់យកនូវវិធីសាស្ត្រធ្វើប្រព្រឹត្តកម្មសំអាត និងបញ្ចេញសំណល់រាវរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹង កំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវ ដូចមានចែងក្នុងមាត្រា ៤ និង មាត្រា ៥ នៃអនុក្រឹត្យនេះ និងកំរិតកំណត់ស្តង់ដារបរិមាណសារធាតុបំពុល ដូចមាន ចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យនេះ។

ខ. មានសំភារៈ និងមធ្យោបាយគ្រប់គ្រាន់សំរាប់រារាំង ឬទប់ស្កាត់ការបំពុល តំបន់ទឹកសាធារណៈ នៅពេលដែលមានគ្រោះថ្នាក់ដោយចៃដន្យបង្កឡើងពីប្រភពបំពុលរបស់ខ្លួន។

គ. ទទួលខុសត្រូវក្នុងការដំឡើងឧបករណ៍ សំរាប់ធ្វើការវាស់នូវចរន្តហូរ កំហាប់ និងបរិមាណសារធាតុបំពុល ដែលមាននៅក្នុងសំណល់រាវរបស់ខ្លួន និងត្រូវរក្សាលទ្ធផលទុកជាឯកសារ។ លទ្ធផលនៃការវាស់ស្ទង់ ត្រូវធ្វើជារបាយការណ៍មកកាន់ក្រសួងបរិស្ថានរៀងរាល់ ៣ ខែម្តង។

**មាត្រា២៤ ៖**

ក្នុងករណីដែលរកឃើញថា ការបញ្ចេញសំណល់រាវពីប្រភពណាមួយ ពុំបានឆ្លើយតបទៅនឹងកំរិតកំណត់ ស្តង់ដារនៃការបញ្ចេញសំណល់រាវ ដូចមានចែងក្នុងមាត្រា ៤ និង មាត្រា ៥ ឬពុំឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារបរិមាណសារធាតុបំពុល ដូចមានចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យនេះ ក្រសួងបរិស្ថានត្រូវ ៖

ក. ចេញបញ្ជាជាលាយល័ក្ខអក្សរ តម្រូវឲ្យម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវប្រភពបំពុលនោះ ធ្វើការកែប្រែសកម្មភាពល្មើសជាបន្ទាន់ក្នុងរយៈពេលជាក់លាក់មួយ ប្រសិនបើសកម្មភាពល្មើសនោះ មិនទាន់បង្កឲ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស ឬប៉ះពាល់ដល់គុណភាពទឹក។

**មាត្រា២៥ ៖**

កំរិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ សំរាប់អភិរក្សជីវៈចំរុះនៅក្នុងទឹក និងសំរាប់សុខភាពសាធារណៈមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៥ នៃអនុក្រឹត្យនេះ។

**មាត្រា២៦ ៖**

ក្រសួងបរិស្ថាន ត្រូវធ្វើការត្រួតពិនិត្យ តាមដានជាប្រចាំពីស្ថានភាពនៃការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីមានវិធាការទប់ស្កាត់ និងកាត់បន្ថយ ការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ។

**មាត្រា២៧ ៖**

ក្រសួងបរិស្ថាន ត្រូវគ្រប់គ្រងទិន្នន័យលទ្ធផលវិភាគគុណភាពទឹក និងវាយតំលៃពីស្ថានភាពគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ នៅទូទាំងប្រទេសកម្ពុជា។

**មាត្រា២៨ ៖**

ក្រសួងបរិស្ថាន ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ ពីស្ថានភាពគុណភាពទឹក និងស្ថានភាពនៃការបំពុលទឹកនៅតាមតំបន់តឹកសាធារណៈ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២៩ ៖**

ក្នុងករណីរកឃើញថា តំបន់ទឹកសាធារណៈត្រូវទទួលរងការបំពុល ដែលបង្កឲ្យមានការគំរាមកំហែងដល់ជីវិតមនុស្ស ឬជីវៈចំរុះ ក្រសួងបរិស្ថាន ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់ពីបញ្ហាគ្រោះថ្នាក់នេះ និងត្រូវចាត់វិធានការទប់ស្កាត់ការបំពុលទឹក និងស្តារនូវគុណភាពទឹកតំបន់ទឹកសាធារណៈ។

**មាត្រា៣០ ៖**

នៅពេលចុះធ្វើអធិការកិច្ចនៅតាមប្រភពបំពុល មន្ត្រីអធិការកិច្ចនៃក្រសួងបរិស្ថាន ត្រូវអនុវត្តតាមនិតិវិធី ដូចមានចែងខាងក្រោម៖

ក. បង្ហាញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកកម្ម របស់ខ្លួននៅពេលចូលក្នុងបរិវេណ ឬទីកន្លែងប្រភពបំពុល ដើម្បីធ្វើអធិការកិច្ច យកគំរូតាង ឬពិនិត្យកំណត់ត្រា

ខ. កំណត់ហេតុ និងរបាយការណ៍ដំបូងនៃការត្រួតពិនិត្យ ឬការយកគំរូតាង ត្រូវធ្វើនៅនឹង កន្លែងដែលធ្វើអធិការកិច្ច ដោយត្រូវមានសាក្សីចូលរួមក្នុងករណីចាំបាច់

គ. មន្ត្រីអធិការកិច្ចអាចសាកសួរ និងតំរូវឲ្យម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពបំពុលផ្តល់នូវពត៌មាន ឬឯកសារនានា ដែលពាក់ព័ន្ធសំរាប់ប្រើប្រាស់ក្នុងការធ្វើរបាយការណ៍ និងកំណត់ហេតុ សំរាប់ប្រើប្រាស់ជាវត្ថុតាង

ឃ. របាយការណ៍ ឬកំណត់ហេតុត្រូវផ្តល់មួយច្បាប់ដល់ម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពបំពុល មួយច្បាប់ជូនតំណាងក្រសួងពាក់ព័ន្ធ និងមួយច្បាប់ទៀតត្រូវរក្សាទុកនៅក្រសួងបរិស្ថាន។

**មាត្រា៣១ ៖**

ក្នុងករណីមានពាក្យបណ្តឹង ឬសេចក្តីរាយការណ៍ថា ប្រភពបំពុលណាមួយបានបង្ហូរបញ្ចេញនូវសំណល់រាវ ដែលមានផ្ទុកសារធាតុពុល បង្ករឲ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្សសត្វ ឬទ្រព្យសម្បត្តិសាធារណៈ ឬបង្កឲ្យមានការបំពុលដល់តំបន់ទឹកសាធារណៈ ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងពាក់ព័ន្ធមានសិទ្ធចូលរួមអធិការកិច្ច នៅក្នុងបរិវេទប្រភពបំពុលនោះ និងយកគំរូតាងមកធ្វើការវិភាគ។

**មាត្រា៣២ ៖**

ក្នុងករណីមានឧប្បទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរណាមួយ នៃការបំពុលទឹកនៅតំបន់ទឹកសាធារណៈ ក្រសួងបរិស្ថាន ត្រូវចុះធ្វអធិការកិច្ចជាបន្ទាន់លើបញ្ហាឧប្បទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរណាមួយនោះ និងត្រូវជូនពត៌មានទៅបណ្តាស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន។

**មាត្រា៣៣ ៖**

ក្នុងករណីបទល្មើសជាក់ស្តែងដែលបង្កឲ្យមានការបំពុលទឹក មន្ត្រីអធិការកិច្ចក្រសួងបរិស្ថានត្រូវ ៖

ក. ធ្វើកំណត់ហេតុ ប្រមូល ឃាត់ទុកវត្ថុតាងនៃបទល្មើស និងធ្វើការពិន័យអន្តរការណ៍ប្រសិនបើបទល្មើសនោះមិនទាន់បង្កឲ្យមានការបំពុលទឹកធ្ងន់ធ្ងរ ឬប៉ះពាល់ទៅដល់ សុខភាពមនុស្ស សត្វ ឬរុក្ខជាតិ ឬទ្រព្យសម្បត្តិសាធារណៈ។

ខ. ប្រមូល និងឃាត់ទុកភស្តុតាងនៃបទល្មើសនោះ ដើម្បីធ្វើកំណត់ហេតុ និងបញ្ជូនសំណុំរឿង ទៅស្ថាប័នមានសមត្ថកិច្ច ប្រសិនបើបទល្មើសនោះបានបង្កឲ្យមានការបំពុលទឹកធ្ងន់ធ្ងរ ឬប៉ះពាល់ទៅដល់សុខភាពមនុស្ស សត្វ ឬរុក្ខជាតិ ឬទ្រព្យសម្បត្តិសាធារណៈ។